OLD VERSION

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

អង្គជំនុំជម្រះសាលាដំបូង

Trial Chamber
Chambre de Premiere instance

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 10-Jun-2015, 15:57
CMS/CFO: Sann Rada

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី
# ជំនុំជម្រះក្តីនៅដំណាក់កាលពីរ

**សាធារណៈ**

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១៥**

**ម៉ោង ០៩:០២នាទី**

**សវនាការលើកទី២៩១**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ក្លូឌា ហ្វេនស៍
*(Judge Claudia FENZ)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែន៍
*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី (បម្រុង)

ចៅក្រម ម៉ាទីន ខារ៉ុបគីន (បម្រុង)
*(Judge Martin KAROPKIN)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោក ម៉ាធូវ ម៉ាកាធី *(Mr Matthew McCarthy)*

កញ្ញា ជា ស៊ីវហ័ង

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក សេង លាង

លោក ឌេល លីសាក់ *(Mr. Dale LYSAK)*

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក លីវ សុវណ្ណា

លោក វិចទ័រ កូប៉េ *(Mr.Victor KOPPE)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

កញ្ញា អង់តា ហ្គីសសេ
*(Ms. Anta GUISSÉ)*

**មេធាវីប្រចាំការលោក ខៀវ សំផន៖**

លោកស្រី ទូច វរល័ក្ស

លោក ខលវីន សោនដឺស៍

*(Mr. Calvin SAUNDERS)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោកស្រី ម៉ារី ហ្គីរ៉ូដ៍ *(Ms.Marie GUIRAUD)*

លោកស្រី ជេត វណ្ណលី

លោក ឡោ ជុនធី

លោក ហុង គឹមសួន

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុំ អរុណ

លោកស្រី សួ សុទ្ធាវី

## បញ្ជីឈ្មោះអ្នកនិយាយ៖

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ក្លូឌា ហ្វេនស៍ | អង់គ្លេស |
| ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ | បារាំង |
| លោក សេង លាង | ខ្មែរ |
| លោក ឌេល លីសាក់ | អង់គ្លេស |
| លោក វ៉ិចទ័រ កូប៉េ | អង់គ្លេស |
| លោកស្រី ជេត វណ្ណលី | ខ្មែរ |
| លោកស្រី ម៉ារី ហ្គីរ៉ូដ៍ | បារាំង |
| លោកស្រី ស៊ូ សឿន (2-TCW-887) | ខ្មែរ |

## ឧបសម្ព័ន្ធ

**ការសួរសំណួរទៅសាក្សី៖ លោកស្រី ស៊ុំ សឿន** (2-TCW-887)

សួរដោយប្រធានអង្គជំនុំ ផ្ដើមពី ....................ទំព័រ ២
សួរដោយលោក ឌេល លីសាក់ ផ្ដើមពី ....................ទំព័រ ៥
សួរដោយលោក សេង លាង ផ្ដើមពី ....................ទំព័រ ៤២
សួរដោយលោកស្រី ជេត វណ្ណលី ផ្ដើមពី ....................ទំព័រ ៤៦
សួរដោយលោកស្រី ម៉ារី ហ្គីរ៉ូដ៍ ផ្ដើមពី ....................ទំព័រ ៥៤
សួរដោយចៅក្រម ក្លូឌា ហ្វេនស៍ ផ្ដើមពី ....................ទំព័រ ៦៤
សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍ ផ្ដើមពី ....................ទំព័រ ៦៩

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០២:០២]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ សវនាការនៅថ្ងៃនេះ អង្គជំនុំជម្រះផ្ដើមធ្វើសវនាការស្ដាប់សក្ខីកម្មសាក្សីដែលមានរហស្សនាម 2-TCW-887។ ហើយអង្គជំនុំជម្រះសូមជម្រាបជូនភាគី និងសាធារណជនជ្រាបផងដែរថា សាក្សីរូបនេះ គាត់បានស្នើសុំបុគ្គលិកអង្គការធី.ភី.អូ ឱ្យអង្គុយនៅក្បែរគាត់នៅក្នុងអំឡុងពេលដែលគាត់ផ្ដល់សក្ខីកម្ម។ ហើយអង្គជំនុំជម្រះបានយល់ព្រមផ្ដល់ឱ្យគាត់ដោយមានអង្គភាពគាំពារសាក្សី និងអ្នកជំនាញជាអ្នកសម្របសម្រួល។

ក្រឡាបញ្ជីសវនាការ កញ្ញា ជា ស៊ីវហ័ង ឡើងរាយការណ៍អំពីស្ថានភាពវត្តមាន អវត្តមានភាគី និងបុគ្គលដែលអង្គជំនុំជម្រះកោះអញ្ជើញឱ្យចូលរួមក្នុងកិច្ចដំណើរការសវនាការថ្ងៃនេះ។

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន! សម្រាប់សវនាការនៅថ្ងៃនេះ ក្រឡាបញ្ជីកត់សម្គាល់ឃើញថា គ្រប់ភាគីទាំងអស់នៃរឿងក្ដីនេះ មានវត្តមាន ដោយឡែកលោក នួន ជា មានវត្តមាននៅបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការនេះ។ ដោយលោកស្នើសុំលះបង់សិទ្ធិមានវត្តមានដោយផ្ទាល់ពីបន្ទប់សវនាការ។ លិខិតលះបង់សិទ្ធិរបស់ជនជាប់ចោទ នួន ជា បានប្រគល់ដល់ក្រឡាបញ្ជីរួចហើយ។ សាក្សីដែលត្រូវមកផ្ដល់សក្ខីកម្មនៅថ្ងៃនេះ មានរហស្សនាម 2-TCW-887។ សាក្សីបានបញ្ជាក់ថា តាមសមត្ថភាពដែលគាត់អាចដឹង គាត់មិនមានទំនាក់ទំនងញាតិលោហិត ឬញាតិពន្ធជាមួយនឹងជនជាប់ចោទទាំងពីររូប គឺលោក នួន ជា និងលោក ខៀវ សំផន ឬភាគីដើមបណ្ដឹងរដ្ឋប្បវេណីណាមួយដែលត្រូវបានទទួលស្គាល់នៅក្នុងរឿងក្ដីនេះទេ។ សាក្សីរូបនេះ បានធ្វើសម្បថរួចហើយនៅចំពោះមុខលោកតាដំបងដែកកាលពីព្រឹកមិញនេះ។ នៅថ្ងៃនេះមិនមានសាក្សីបម្រុងនោះទេ។ សូមអរគុណលោកប្រធាន។

[០៩:០៤:០៥]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ជាដំបូងនេះ អង្គជំនុំជម្រះសម្រេចលើសំណើសុំរបស់ជនជាប់ចោទ នួន ជា

ជាមុនសិន។ អង្គជំនុំជម្រះបានទទួលលិខិតសុំលះបង់សិទ្ធិចូលរួមសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះរបស់ជនជាប់ចោទ នួន ជា ចុះថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១៥ ដែលបានបញ្ជាក់ថា ដោយគាត់មានបញ្ហាសុខភាពឈឺចង្កេះ ឈឺក្បាល មិនអាចអង្គុយយូរបាន និងមិនអាចផ្ចង់អារម្មណ៍បានយូរ និងដើម្បីមានលទ្ធភាពចូលរួមសវនាការនៅថ្ងៃខាងមុខឲ្យមានប្រសិទ្ធភាព ខ្លួនសុំលះបង់សិទ្ធិចូលរួម និងមានវត្តមានដោយផ្ទាល់ក្នុងបន្ទប់សវនាការនៅថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១៥។ បានឃើញកំណត់ហេតុពិនិត្យសុខភាព ជនជាប់ចោទ នួន ជា ដែលធ្វើឡើងដោយគ្រូពេទ្យប្រចាំការពិនិត្យព្យាបាល ថែទាំងសុខភាពជនជាប់ចោទនៅ អ.វ.ត.ក ចុះថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១៥ បានកត់សម្គាល់ថា ស្ថានភាពសុខភាពរបស់លោក នួន ជា មានអាការៈឈឺចង្កេះរ៉ាំរ៉ៃ ហើយឈឺខ្លាំងពេលអង្គុយ ហើយនិងវិលមុខពេលធ្វើចលនា ហើយគាត់មិនអាចអង្គុយយូរបាន និងបានផ្តល់អនុសាសន៍ថាសូមអង្គជំនុំជម្រះអនុញ្ញាតឲ្យលោក នួន ជា នៅតាមដានកិច្ចដំណើរការសវនាការពីបន្ទប់ខាងក្រោមសាលសវនាការនេះ។

ផ្អែកលើមូលដ្ឋាននេះ និងយោងតាមបទប្បញ្ញត្តិនៃវិធាន៨១(៥) នៃវិធានផ្ទៃក្នុង អ.វ.ត.ក អង្គជំនុំជម្រះយល់ព្រម និងអនុញ្ញាតឲ្យជនជាប់ចោទ នួន ជា បន្តតាមដានកិច្ចដំណើរការសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនមួយ ស្ថិតនៅក្រោមសាលសវនាការនេះ តាមរយៈឧបករណ៍សោតទស្សន៍សម្រាប់រយៈពេលសវនាការពេញមួយថ្ងៃនេះ។

[០៩:០៥:៣០]

បង្គាប់ឲ្យបុគ្គលិកផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទ នួន ជា អាចចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនមួយ ស្ថិតនៅក្រោមសាលសវនាការនេះនៅក្នុងអំឡុងពេលនៃកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ។

តទៅនេះបង្គាប់ឲ្យមន្ត្រីរដ្ឋបាលតុលាការអញ្ជើញសាក្សី រួមទាំងបុគ្គលិកអង្គការ ធី.ភី.អូ ចូលមកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការ។

*(សាក្សីចូលក្នុងបន្ទប់សវនាការ)*

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** សួស្តីលោកស្រីសាក្សី។ តើលោកស្រីឈ្មោះអី?

**លោកស្រី ស៊ូ សឿន៖**

**ឆ៖** ចាស ខ្ញុំឈ្មោះ ស៊ូ សឿន។

**ស៖** អរគុណលោកស្រី ស៊ូ សឿន។ តើលោកស្រីកើតនៅថ្ងៃខែឆ្នាំណា លោកស្រីចាំទេ?

**ឆ៖** ខ្ញុំអត់ចាំទេទាន។

[០៩:០៨:២៣]

**ស៖** ឆ្នាំនេះលោកស្រីអាយុប៉ុន្មានហើយ?

**ឆ៖** ចាស ៧៩ ហើយ។

**ស៖** បាទ អរគុណ។ ហើយលោកស្រី ស៊ូ សឿន តើទីកន្លែងកំណើតរបស់លោកស្រីនៅភូមិឃុំស្រុកណា ខេត្តណា?

**ឆ៖** ស្រុកកំណើតនៅ ឃុំឈូកខ្សាច់ ស្រុកឈូកខ្សាច់ ខេត្ត -- ស្រុកបារាយណ៍ ខេត្តកំពង់ធំ។

**ស៖** បាទ អរគុណ។ ចុះទីលំនៅសព្វថ្ងៃ តើរស់នៅទីកន្លែងណា?

**ឆ៖** សព្វថ្ងៃ ខ្ញុំនៅអន្លង់វែង ស្រុកអន្លង់វែង។

**ស៖** តើលោកស្រីប្រកបមុខរបរអ្វីដែលសព្វថ្ងៃនេះ?

**ឆ៖** ខ្ញុំអត់មានធ្វើអីទេ។

**ស៖** ឪពុកបង្កើតរបស់លោកស្រីឈ្មោះអី? ហើយម្ដាយបង្កើតរបស់លោកស្រីគាត់ឈ្មោះអី?

**ឆ៖** ឪពុកឈ្មោះ តាសែប – លឹម សែប។ ម្ដាយឈ្មោះ ឌុច ធូ។

[០៩:០៨:៥០]

**ស៖** ចុះប្ដីរបស់លោកស្រីឈ្មោះអី? ហើយលោកស្រីមានកូនប៉ុន្មាននាក់?

**ឆ៖** ប្ដីឈ្មោះ កែ ពក។ កូនប្រាំមួយនាក់។

**ស៖** បាទ អរគុណលោកស្រី ស៊ូ សឿន។ តាមរបាយការណ៍របស់ក្រឡាបញ្ជីសវនាការអម្បាញ់មិញនេះ ថាតាមសមត្ថភាពដែលលោកស្រីអាចដឹង គឺលោកស្រីមិនមានជាប់ចំណងញាតិលោហិត ឬក៏ញាតិពន្ធជាមួយនឹងជនជាប់ចោទទាំងពីររូប នួន ជា និង ខៀវ សំផន និងបុគ្គលដែលត្រូវទទួលយកជាដើមបណ្ដឹងរដ្ឋប្បវេណីក្នុងរឿងក្ដី០០២ នេះទេ។ តើពិតមែនដែរទេ?

**ឆ៖** ចាស អត់មានជាប់សាច់ញាតិអីទេ។

**ស៖** ហើយថាលោកស្រីបានស្បថរួចហើយ មុននឹងចូលមកផ្ដល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំ

ជម្រះនាពេលនេះ។ តើពិតមែនទេ?

**ឆ៖** ចាស។

[០៩:១១:០៤]

**ស៖** ជាបន្តទៅនេះ យើងប្រាប់អំពីសិទ្ធិ និងករណីយកិច្ចក្នុងនាមលោកស្រីជាសាក្សីនៅចំពោះមុខអង្គជំនុំជម្រះ។ លោកស្រី ស៊ូ សឿន ក្នុងនាមលោកស្រីជាសាក្សីនៅក្នុងកិច្ចដំណើរការនីតិវិធីនៅចំពោះមុខអង្គជំនុំជម្រះនេះ លោកស្រីអាចបដិសេធក្នុងការឆ្លើយតបទៅនឹងសំណួរ ឬការធ្វើឱ្យ -- សុំឱ្យលោកស្រីធ្វើអំណះអំណាងណាមួយ ឬច្រើនដែលនាំឱ្យដាក់ពិរុទ្ធភាពលើខ្លួនឯង។ សិទ្ធមិនធ្វើសក្ខីកម្មប្រឆាំងនឹងខ្លួនឯង មានន័យថាដោយសារតែចម្លើយ ឬអំណះអំណាងរបស់លោកស្រីនោះ នាំឱ្យលោកស្រីនឹងត្រូវទទួលរងការចោទប្រកាន់។ អំពីករណីយកិច្ច លោកស្រី ស៊ូ សឿន ក្នុងឋានៈជាសាក្សីលោកស្រីមានករណីយកិច្ចត្រូវតែឆ្លើយតបរាល់សំណួរដែល -- ទាំងឡាយដែលភាគី ឬចៅក្រមនៃអង្គជំនុំជម្រះសួរចំពោះលោកស្រី លើកលែងតែសំណួរណាដែលនាំឱ្យឆ្លើយតបរបស់លោកស្រី ឬការធ្វើអត្ថាធិប្បាយរបស់លោកស្រីដែលនាំឱ្យដាក់ពិរុទ្ធភាពលើខ្លួនឯង ដូចយើងបានប្រាប់អំពីសិទ្ធរបស់សាក្សីរួចមកហើយអម្បាញ់មិញនេះ។ ហើយក្នុងឋានៈជាសាក្សី ត្រូវតែឆ្លើយការណ៍ណាដែលពិត ដែលលោកស្រីបានដឹង បានឮ បានឃើញ បានចងចាំ ធ្លាប់មានបទពិសោធន៍ជួបប្រទះ ឬបានធ្វើការសង្កេតដោយផ្ទាល់នូវព្រឹត្តិហេតុ ឬហេតុការណ៍ទាំងឡាយដែលពាក់ព័ន្ធនឹងសំណួរដែលភាគី ឬចៅក្រមនៃអង្គជំនុំជម្រះសួរចំពោះលោកស្រី។

លោកស្រី ស៊ូ សឿន តើលោកស្រីធ្លាប់បានផ្តល់កិច្ចសម្ភាសន៍ជាមួយនឹងអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេតដែរឬទេ ក្នុងរយៈពេលកន្លងមក? ប្រសិនបើធ្វើ ធ្វើប៉ុន្មានដង? ធ្វើនៅទីកន្លែងណា? នៅពេលណាដែរ?

[០៩:១២:៤៤]

**ឆ៖** ខ្ញុំបានធ្លាប់ធ្វើម្តងនៅអន្លង់វែង។

**ស៖** បាទ អរគុណ។ មុនពេលចូលមកចំពោះអង្គជំនុំជម្រះនៅពេលនេះ តើលោកស្រីបានពិនិត្យ ឬក៏បានស្តាប់ការអានពីបុគ្គលណាម្នាក់នូវចម្លើយរបស់លោកស្រីដែលបានផ្តល់ចំពោះអ្នកស៊ើបអង្កេតកាលពីមុននោះ ដើម្បីរំឭកការចងចាំរបស់លោកស្រីដែរឬទេ?

**ឆ៖** បានៗស្តាប់ដែរ ប្អូនខ្ញុំបានអានឱ្យស្តាប់។

**ស៖** ហើយតាមសមត្ថភាពដែលលោកស្រីអាចដឹង និងចងចាំ តើលោកស្រីអាចបញ្ជាក់បានដែរទេ ថាកំណត់ហេតុស្ដាប់ចម្លើយដែលលោកស្រីបានអាន -- បានស្ដាប់ការអាន ដើម្បីរំឭកការចងចាំនោះគឺពិតជាត្រឹមត្រូវ ឬក៏វាស៊ីសង្វាក់ស្របទៅនឹងចម្លើយដែលលោកស្រីធ្វើសម្ភាសន៍ជាមួយនឹងអ្នកស៊ើបអង្កេតកាលពីពេលមុននៅអន្លង់វែងនោះដែរឬទេ?

**ឆ៖** ពេលនេះអាចខ្ញុំភ្លេចច្រើន ពីមុនចេះនិយាយបាន បើឥឡូវនេះភ្លេចច្រើន ដូចអាចថាឆ្លើយមិនៗបានគ្រប់សំណួរទេ។

[០៩:១៤:០៤]

**ស៖** អង្គជំនុំជម្រះអត់ចង់សួរអ៊ីចឹងទេ សួរថាដែលក្រោយពីលោកស្រីស្ដាប់ការអានរបស់អ្នកដែលអាន បងប្អូនដែលអានឲ្យ កូនក្មួយដែលអានឲ្យលោកស្រីស្ដាប់នូវសក្ខីកម្ម – នូវចម្លើយដែលលោកស្រីបានផ្ដល់អ្នកស៊ើបអង្កេតកាលនៅអន្លង់វែងនោះ តើវាខ្លឹមសារដែលការស្ដាប់ ហើយនិងការប្រៀបជាមួយលោកស្រីផ្ដល់សក្ខីកម្មកាលពីពេលហ្នឹង វាៗដូចគ្នាទេ?

**ឆ៖** វាៗអាចដូច តែវាខ្ញុំភ្លេចច្រើន ភ្លេចពាក្យនិយាយខ្លួនឯងក៏ភ្លេច។

**ប្រធានអង្គជំនុំ៖**

បាទ ក្នុងការសួរដេញដោលសាក្សីរូបនេះ អនុវត្តតាមវិធាន៩១ នៃវិធានផ្ទៃក្នុង អ.វ.ត.ក អង្គជំនុំជម្រះផ្ដល់វេទិកាជូនទៅសហព្រះរាជអាជ្ញាសួរដេញដោលសាក្សី ស៊ូ សឿន មុនភាគីដទៃទៀតនៃរឿងក្ដី។ សូមបញ្ជាក់ថា សហព្រះរាជអាជ្ញា រួមទាំងសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី មានរយៈពេលបីវគ្គនៃថ្ងៃសវនាការ ក្នុងការសួរទៅសាក្សីរូបនេះ។

សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា!

[០៩:១៥:២៣]

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។ សូមជម្រាបសួរលោក លោកស្រីចៅក្រម សូមជម្រាបសួរលោកមេធាវី និងលោកស្រីសាក្សី។

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** ខ្ញុំមុនពេលខ្ញុំសាកសួរ ខ្ញុំសូមជម្រាបថា ខ្ញុំឈ្មោះ ឌេល លីសាក់ ខ្ញុំគឺជាសហព្រះរាជអាជ្ញា

រង ខ្ញុំសូមចាប់ផ្តើមសួរអំពីប្រវត្តិរបស់ស្វាមីរបស់លោកស្រី។ លោកស្រីបានបញ្ជាក់នៅក្នុងកិច្ចសម្ភាសន៍របស់លោកស្រី E3/5294 ថាលោកស្រីរៀបការជាមួយស្វាមីរបស់លោកស្រី កែ ពក នៅពេលលោកស្រីអាយុ២២ឆ្នាំ។ តាមការគណនារបស់ខ្ញុំ ដោយសារឥឡូវនេះ លោកស្រីអាយុ៧៩ឆ្នាំ ដូច្នេះ លោកស្រីប្រហែលជារៀប -- ប្រហែលជាការនៅ -- លោកស្រីប្រហែលជារៀប -- កើតនៅឆ្នាំ១៩៣៦ ហើយប្រហែលជាលោកស្រីរៀបការជាមួយប្តីរបស់លោកស្រីនៅឆ្នាំ៥៨។ ដូច្នេះ តើវាប្រហាក់ប្រហែលដែរឬទេ ដែលថាលោកស្រីរៀបការជាមួយ កែ ពក នៅឆ្នាំ១៩៥៨?

[០៩:១៦:៣៨]

**លោកស្រី ស៊ូ សឿន ៖**

**ឆ៖** ចាស ខ្ញុំឆ្លើយ ឆ្នាំ បើថាឆ្នាំ៦២ ខ្ញុំមានកូន ការបាន៣ឆ្នាំ១ ៦២ មានកូន – ឆ្នាំ១៩៦២។

**ស៖** សូមអរគុណ។ តើលោកស្រីអាចជម្រាបបានទេថា បន្ទាប់ពីលោកស្រី ហើយលោក កែ ពក រៀបការហើយ តើលោកស្រីស្នាក់នៅទីកន្លែងណាដែរ? ហើយនៅពេលដែលលោកស្រីរៀបការជាមួយគាត់ហ្នឹង គាត់ក្លាយទៅជា -- គាត់បានចូលទៅក្នុងបដិវត្តន៍ហើយឬនៅ នៅពេលនោះ?

**ឆ៖** នៅពេលនោះ គាត់អត់ទាន់ធ្វើអីទេ នៅធ្វើស្រែ ធ្វើចម្ការធម្មតា។

**ស៖** តើលោកស្រី និងស្វាមីលោកស្រី ស្នាក់នៅកន្លែងណាដែរ ក្រោយពេលរៀបការនៅឆ្នាំ៥៩ នោះ?

**ឆ៖** ខ្ញុំនៅឈូកខ្សាច់ ស្នាក់នៅឈូកខ្សាច់ គេហៅស្រុកបារាយណ៍ ខេត្តកំពង់ធំ។

**ស៖** លោកស្រី តើស្វាមីរបស់លោកស្រីបានផ្តល់កិច្ចសម្ភាសន៍មួយ ដែលខ្ញុំនឹងអានឲ្យលោកស្រីស្តាប់នៅក្នុងពេលដែលខ្ញុំសួរលោកស្រីបន្តទៅមុខទៀតនេះ ដើម្បីជួយរំឭកដល់លោកស្រី។ ហើយកិច្ចសម្ភាសន៍ទាំងអស់នោះ គឺឯកសារ E3/2782 និងឯកសារ E3/2783 ដើម្បីឲ្យភាគីបានជ្រាបថានេះជាកិច្ចសម្ភាសន៍តែមួយ ប៉ុន្តែមានឯកសារជាពីរ ហើយភាសាបារាំងមានបកតែនៅក្នុងឯកសារទី២ប៉ុណ្ណោះគឺ E3/2783 ។ ហើយចំពោះឯកសារយោងលេខយោងលេខ ERN ដែលខ្ញុំនឹងអានគឺនៅត្រង់ភាសាអង់គ្លេសមានលេខ 00089708, ខ្មែរមានលេខ 00095547 និងបារាំងមានលេខ 00596203។ នៅក្នុងកិច្ចសម្ភាសន៍នេះ កែ ពក បានរៀបរាប់អំពីប្រវត្តិរបស់គាត់ដូចតទៅនេះ ខ្ញុំសូមដកស្រង់៖ “ខ្ញុំចូលរួមការតស៊ូតាំងពីឆ្នាំ១៩៤៩ នៅក្នុងរបបខ្មែរឥស្សរៈ។ បន្ទាប់ពីអនុសញ្ញាទីក្រុងហ្សឺណែវ ខ្ញុំបានបោះបង់ការតស៊ូ ហើយត្រឡប់មកផ្ទះវិញ។ នៅក្នុងឆ្នាំ៥៧ ស៊ីវ ហេង ដែលជាលេខាបក្ស បានទាក់ទង

ជាមួយខ្ញុំ ហើយប្រាប់ខ្ញុំឲ្យចូលរួមនៅក្នុងការតស៊ូឡើងវិញ។ ខ្ញុំធ្វើ ហើយខ្ញុំបានចូលទៅក្នុងបក្សនៅក្នុងស្រុកស្វាយទាប នៅក្នុងឃុំស្វាយទាប ស្រុកចំការលើ”។ ហើយបន្តទៅកថាខណ្ឌបន្ទាប់ “នៅក្នុងឆ្នាំ៥៨ បន្ទាប់ពីខ្ញុំក្លាយជាសមាជិកបក្ស ពួកគេបានចាត់តាំងឲ្យខ្ញុំធ្វើសកម្មភាពមួយចំនួននៅក្នុងស្រុកចំការលើ ដែលជាស្រុកកំណើតរបស់ខ្ញុំ។” សូមបញ្ចប់ការដកស្រង់។ ដូច្នេះជាដំបូង ខ្ញុំចង់សួរលោកស្រី ថាតើស្វាមីរបស់លោកស្រីមកពីស្រុកចំការលើមែនដែរឬទេ?

[០៩:២០:៤០]

**ឆ៖** ដល់កន្លែងហ្នឹង ខ្ញុំមិនសូវដឹងដែរ ព្រោះកិច្ចការហ្នឹង ខ្ញុំមិនដឹងគាត់ចូលធ្វើពីពេលណា ខ្ញុំអត់ដឹង។

**ស៖** តើលោកស្រីចាំទេ ថាបន្ទាប់ពីលោកស្រី ហើយនិងលោក កែ ពក រៀបការហើយ លោកស្រីធ្លាប់ផ្លាស់ទីលំនៅទៅចំការលើដែរឬទេ?

**ឆ៖** ខ្ញុំរៀបចំការរួចហើយ មករកស៊ីនៅគេហៅស្រុកចំការលើ ប៉ុន្តែនៅភូមិ គេហៅភូមិប្រើសមាស នៅស្រុកចំការអណ្តូង។

**ស៖** ទំព័របន្ទាប់នៅក្នុងកិច្ចសម្ភាសន៍របស់ស្វាមីលោកស្រី គាត់បានរៀបរាប់នូវហេតុការណ៍ពីទសវត្សរ៍ឆ្នាំ៦០ ពាក់ព័ន្ធទៅនឹងបក្សកុម្មុយនីស្តកម្ពុជា ហើយគាត់បានបញ្ជាក់ដូចតទៅនេះ ខ្ញុំសូមដកស្រង់៖ “ក្នុងពាក់កណ្តាលឆ្នាំ៦៧ គណៈតំបន់បានតែងតាំង កុយ ធួន ធ្វើជាលេខា ហើយខ្ញុំធ្វើជាអនុលេខា ហើយ ឌឿន, ស្រេង, ប្រា, ថោង និង សំអាត ធ្វើជាសមាជិក។ នៅពេលនោះ បង នួន គាត់បានចេញទៅព្រៃឈរដើម្បីជ្រើសតាំងកម្លាំង។ នៅក្នុងឆ្នាំ១៩៦៨ ខ្ញុំចាប់ផ្តើមធ្វើការនៅក្នុងព្រៃ។” សូមបញ្ចប់ការដកស្រង់។ ដូច្នេះជាដំបូង ខ្ញុំចង់សួរថាតើលោកស្រីមានចូលព្រៃជាមួយប្តីរបស់លោកស្រីនៅឆ្នាំ៦៨ដែរឬទេ ឬមួយក៏លោកស្រី ហើយនិងកូនហ្នឹងរស់នៅកន្លែងផ្សេងទេ នៅពេលនោះ?

[០៩:២២:៤១]

**ឆ៖** ចាស ពេលនោះ ខ្ញុំនៅកន្លែងផ្សេង អត់នៅជាមួយគ្នាទេ បែកគ្នាតាំងពី៦៧មក។

**ស៖** ចម្លើយដែលស្វាមីលោកស្រីបាននិយាយគឺថា និយាយគឺថា “បងនួន បានទៅរៀបចំកម្លាំងនៅស្រុកព្រៃឈរ”។ តើនៅពេលនោះលោកស្រីស្គាល់ នួន ជា ដែរឬទេ? ហើយតើលោកស្រីជួប នួន ជា ជាលើកដំបូងនោះ នៅពេលណាដែរ?

**ឆ៖** ខ្ញុំ ពេលនោះខ្ញុំអត់ស្គាល់ អត់ទាន់ស្គាល់គាត់ទេ ក្រោយមកបានស្គាល់នៅទីក្រុងនៅភ្នំពេញ

នេះតែម្តង។

**ស៖** តើលោកស្រីមកទីក្រុងភ្នំពេញនៅពេលណា? ហើយតើលោកស្រីធ្វើយ៉ាងណា បានស្គាល់ នួន ជា នៅពេលដែលលោកស្រីមកដល់ភ្នំពេញនោះ?

**ឆ៖** ពេលនោះ គឺខ្ញុំមករកស៊ីនៅភ្នំពេញហ្នឹង ក៏គេហៅចូលទៅ ក្នុងនាមជាអ្នកដាំបាយដាំអីទេ។ ភ្លេចអស់ហើយ ភ្លេចខ្លះហើយខ្ញុំ។

**ស៖** លោកស្រីបានបញ្ជាក់នៅក្នុងចម្លើយទី១នៃកិច្ចសម្ភាសន៍របស់លោកស្រីគឺ E3/5294 ថា លោកស្រីបានចូលបដិវត្តន៍នៅក្នុងឆ្នាំ៦៩ នៅពេលដែលលោកស្រីនៅទីក្រុងភ្នំពេញ។ តើលោកស្រីអាចប្រាប់បានទេ ថាតើការចូលបដិវត្តន៍នៅភ្នំពេញ នៅពេលនោះហើយគឺលោកស្រីបានជួប នួន ជា។ តើអ៊ីចឹងមែនទេ?

[០៩:២៥:០៧]

**ឆ៖** ចាស ពេលនុ៎ង ខ្ញុំបានគេហៅខ្ញុំមកជួយដាំបាយដាំអី ខ្ញុំស្គាល់គាត់ពេលនុ៎ងដែរ ពេលគាត់ហៅចូលជួបសំណេះសំណាលរឿងការងារអីអ៊ីចឹង ខ្ញុំអត់យល់គេ ខ្ញុំអត់ដឹង។ ដល់អ៊ីចឹងគេឲ្យដាំបាយ។ ដាំបាយមួយរយៈមក ក៏ខ្ញុំបែកពីគាត់ទៅទៀតទៅ។

**ស៖** តើលោកស្រីអាចប្រាប់បានទេ ថាតើលោកស្រីជាអ្នកដាំស្លឲ្យ នួន ជា និងអ្នកដទៃទៀតមែនទេ? ហើយតើអ្នកខ្លះដែលលោកស្រីធ្វើម្ហូបឲ្យពួកគេហូបនោះ?

**ឆ៖** ខ្ញុំអត់បានៗឃើញទេ គ្រាន់តែដឹងថាដាំបាយស្ល ប៉ុន្តែកន្លែងហូបចុកអី គឺមានគេអ្នកលើកយកទៅ ខ្ញុំអត់ដឹងថាមានប៉ុន្មាន ឬក៏អ្នកណា ខ្ញុំអត់ស្គាល់ដែរ អត់ឃើញគេផង។

**ស៖** នៅក្នុងចម្លើយដដែល គឺចម្លើយទី១នៅក្នុងកិច្ចសម្ភាសន៍ជាមួយអ្នកស៊ើបអង្កេត លោកស្រីបាននិយាយពីការចាកចេញពីភ្នំពេញជាមួយកូនស្រីចូលព្រៃម៉ាគីនៅក្នុងខែតុលា ឆ្នាំ៧០។ ហើយបន្ទាប់មកទៀតគេយកលោកស្រីទៅកន្លែងមួយនៅក្បែរស្ទឹងជីនិត ដែលនៅទីនោះគឺលោកស្រីបានជួយជាមួយប្តីរបស់លោកស្រី។ ទីតាំងដែលលោកស្រីបានជួបប្តីរបស់លោកស្រីនៅក្បែរជីនិត។ ថាតើកន្លែងហ្នឹងគឺជាកន្លែងដែលមេដឹកនាំបក្ស ឬក៏បញ្ជាការដ្ឋានធំរបស់បក្សស្ថិតនៅទីនោះមែនដែរទេ?

[០៩:២៧:១២]

**ឆ៖** នោះគឺកន្លែងមេបញ្ជាការកងទ័ព អត់ឃើញមានអ្នកធំទេ ឃើញតែមេបញ្ជាការកងទ័ព។

**ស៖** តើអ្នកណាជាមេបញ្ជាការទ័ពដែលនាំលោកស្រីទៅទីតាំងនោះ?

**ផ៖** វាពាក់ព័ន្ធនៅក្នុងគ្រួសាររបស់ខ្ញុំ។

**ស៖** តើលោកស្រីអាចប្រាប់បានទេ ថាតើប្ដីរបស់លោកស្រីនៅពេលដែលលោកស្រីចូលព្រៃម៉ាគីហ្នឹង តើប្ដីលោកស្រីហ្នឹងមានឋានៈ ឬក៏មានតួនាទីអ្វីដែរ?

**ផ៖** ក្នុង១នាទីជាកម្មាភិបាលនៅឡើយទេ។

**ស៖** នៅពេលដែលលោកស្រីចូលព្រៃនៅឆ្នាំ៧០ តើកូនប្រុសរបស់លោកស្រីគឺ កែ ពេជ្រវណ្ណៈហ្នឹង តើគាត់រស់នៅទីកន្លែងតែមួយជាមួយលោកស្រីដែរ ឬមួយក៏អត់ទេ?

**ផ៖** ចាស ពេលនោះកូនប្រុសខ្ញុំ វានៅកំពង់ចាម ហើយខ្ញុំនៅពីរនាក់កូនស្រីមួយទៅជាមួយតែម៉ែកូនពីរនាក់ហ្នឹង។

[០៩:២៩:២២]

**ស៖** ខ្ញុំចង់អានឲ្យលោកស្រីស្ដាប់នូវកិច្ចសម្ភាសន៍របស់កូនប្រុសលោកស្រី គឺឯកសារ E3/35 ខ្មែរមានលេខ 00340560 ដល់ 61, អង់គ្លេសមានលេខ 00346147, បារាំងមានលេខ 00367718 ដល់ 719។ ហើយចម្លើយនេះ គឺជាចម្លើយដំបូងរបស់គាត់ គាត់បានផ្ដល់សក្ខីកម្មថា ចន្លោះឆ្នាំ៧០ ដល់៧៣ គាត់រស់នៅក្នុងតំបន់មួយ ក្នុងស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម ដែលជាទីបញ្ជាការមជ្ឈិមបក្ស។ ហើយនៅក្នុងពេលថ្ងៃ គឺប្រពន្ធ ប៉ុល ពត ជាអ្នកបង្រៀនគាត់គឺឈ្មោះ ខៀវ ប៉ុណ្ណារី ដែលគាត់ហៅថា យាយរី។ ហើយនៅពេលយប់ គាត់ជាអ្នក -- គាត់ធ្វើសរសៃឲ្យ ប៉ុល ពត ដែលនៅពេលនោះ គាត់ហៅថាជា តាស ឬក៏ តាប៉ុល។ ដូច្នេះ ខ្ញុំចង់សួរលោកស្រីថា តើលោកស្រីមានការទំនាក់ទំនងជាទៀងទាត់ ឬក៏ជាប្រចាំជាមួយ ប៉ុល ពត ហើយនិងប្រពន្ធរបស់គាត់ ដូចដែលកូនប្រុសរបស់លោកស្រីដែរឬទេ?

**ផ៖** ខ្ញុំសូមឆ្លើយថា ចំណែកខ្ញុំមិនបានជិតស្និទ្ធជាមួយគាត់ទេ គ្រាន់តែថានៅព្រៃមែន តែនៅដោយខ្លួនពីគ្នា។ តែកូនខ្ញុំ បានទៅនៅជិតជាមួយ ឬយ៉ាងណា ខ្ញុំមិនសូវដឹងដែរ។

**ស៖** តើលោកស្រីធ្លាប់ជួប ប៉ុល ពត ខ្លះ១ដែរឬទេ ប៉ុល ពត និងភរិយារបស់គាត់ ខ្លះដែរឬទេនៅក្នុងរយៈពេលនោះ?

[០៩:៣១:៤៨]

**ផ៖** ខ្ញុំបានជួប ពេលនៅក្នុងព្រៃហ្នឹង បានជួបម្ដង១។ ជួបទាំងគ្រួសារគាត់ទាំងពីរហ្នឹងបានជួបម្ដង១។ ហើយគេហៅថា បង១ ប៉ុននុ៎ងឯង តែរួច ជួបមានពេលរយៈជួប គេឲ្យជួបបានជួប គេមិនឲ្យជួប ខ្ញុំនៅព្រៃដោយខ្លួនពីគ្នា អត់មាននៅជាមួយគ្នាទេ។

**សៈ** នៅក្នុងកិច្ចសម្ភាសន៍ជាមួយអ្នកស៊ើបអង្កេតគឺខ្មែរមានលេខ 00340561, អង់គ្លេសមានលេខ 00346148, បារាំងមានលេខ 00867719។ កូនប្រុសរបស់លោកស្រីបានផ្តល់សក្ខីកម្មថា គាត់បានឃើញ ខៀវ សំផន នៅស្នាក់ការធំរបស់បក្ស នៅក្នុងព្រៃនៅពេលដែលគាត់រស់នៅទីនោះ ចន្លោះពីឆ្នាំ៧០ដល់៧៣ ដែលគាត់ហៅ ខៀវ សំផន ថា តាហែម។ ដូច្នេះខ្ញុំចង់សួរលោកស្រីថា លោកស្រីបានជួប ខៀវ សំផន នៅទីកន្លែងនោះ នៅក្នុងចន្លោះពីឆ្នាំ៧០ ដល់៧៣ ដែរឬទេ?

**ធៈ** ខ្ញុំដូចជាអត់បានជួបគាត់។ បើបាន ចង់និយាយអ៊ីចឹង និយាយថា កូនវាផ្សេង អត់នៅជាមួយម៉ែទេ។ ឯម៉ែនៅផ្សេង កូននៅផ្សេង ដល់ត្រង់ថា វាទៅជួប ខ្ញុំអត់ដឹង ហើយខ្ញុំបានជួបជាធម្មតាបង ហៅដូចបងអីធម្មតាទេ។ យូរៗជួបគ្នាម្តង។ ខ្ញុំចាំតែប៉ុណ្ណឹង។

[០៩:៣៣:៥៨]

**សៈ** លោកស្រី តើលោកស្រីចាំដែរឬទេថា តើលោកស្រីជួប ខៀវ សំផន ជាលើកដំបូងនៅពេលណាដែរ?

**ធៈ** ខ្ញុំអត់បានចាំទេ អត់បានចាំ។ កន្លែងខ្លះ ខ្ញុំភ្លេចអត់បានចាំថា ជួបគាត់នៅកន្លែងណា ខ្ញុំអត់បានចាំ ហើយជួបឆ្នាំណាក៏ខ្ញុំមិនបានចាំដែរ។

**សៈ** ឥឡូវនេះ ខ្ញុំសូមបន្តទៅដល់រយៈពេលពីថ្ងៃ១៧ មេសា ៧៥ បន្តទៅ។ ហើយជាដំបូងខ្ញុំចង់សួរ ដោយខ្ញុំអាននូវសម្រង់ពីកិច្ចសម្ភាសន៍របស់ស្វាមីលោកស្រីគឺ E3/2782 និង E3/2783 អង់គ្លេសមានលេខ -- ខ្មែរមានលេខ 00095550 ដល់ 51, អង់គ្លេសមានលេខ 00089711 ដល់ 12 និងបារាំងមានលេខ 00596208។ ហើយក្នុងឯកសារនេះ ប្តីរបស់លោកស្រីបានបញ្ជាក់ថា ក្រោយថ្ងៃ១៧ មេសា ៧៥ គាត់ក្លាយទៅជាលេខាភូមិភាគឧត្តរ និងក្រោយមកទៀតក្លាយទៅជាភូមិភាគកណ្តាល។ ហើយគាត់ក៏បានបញ្ជាក់ផងដែរថា កុយ ធួន ដែលជាលេខាតំបន់នោះត្រូវបានគេបញ្ជូនទៅ -- ត្រូវបានគេផ្ទេរទៅទីក្រុងភ្នំពេញ ទៅក្រសួងពាណិជ្ជកម្ម។ ដូច្នេះខ្ញុំចង់សួរលោកស្រីថា តើប្តីលោកស្រីធ្លាប់ប្រាប់លោកស្រីដែរទេ ថាហេតុអ្វីបានជាគេតែងតាំង ដំឡើងឋានៈគាត់ទៅជាលេខាភូមិភាគ ហើយ កុយ ធួន ត្រូវបានគេបញ្ជូនទៅក្រសួងពាណិជ្ជកម្មនៅទីក្រុងភ្នំពេញ ក្រោយថ្ងៃ១៧ មេសា ឆ្នាំ៧៥ ដែរឬទេ?

**ធៈ** ពេលនោះខ្ញុំគ្រាន់ដឹងថា គាត់ឡើងជាលេខាភូមិភាគ ប៉ុន្តែការរៀបចំយ៉ាងណាខ្ញុំអត់ដឹងទេ ព្រោះពេលនោះ គេ អារឿងកិច្ចការគេៗមិនឲ្យយើងជាស្រីដឹងរឿងអីទាំងអស់ រឿងរាក់ជ្រៅអីមិនដឹងទេ។

[០៩:៣៧:១០]

**ស៖** តើលោកស្រីដឹងទេថា តើលោកស្រីដឹងថាលោកស្រីត្រូវបានគេតែងតាំងធ្វើជាលេខាភូមិភាគហ្នឹងនៅពេលណាដែរ?

**ឆ៖** ចាស ខ្ញុំអត់ដឹងទេ។ ដល់ពេលមនុស្សមក គេហៅលាន់ទៅ ខ្ញុំក៏ដឹងតាមហ្នឹងទៅ ហើយសួរគាត់ៗថា "កិច្ចការគេដឹង កិច្ចការគេៗដឹង កិច្ចយើងៗមិនបាច់សួរទេ រឿងរបស់គេ។" តែប៉ុណ្ណឹង។

**ស៖** ឥឡូវនេះខ្ញុំនឹងពិភាក្សាអំពីតួនាទីរបស់លោកស្រីនៅក្នុងបក្ស ក្នុងរបបកម្ពុជាប្រជាធិប-តេយ្យ។ នៅក្នុងកិច្ចសម្ភាសន៍របស់លោកស្រី E3/5294 ខ្មែរមានលេខ 00348827, អង់គ្លេសមានលេខ 00360111, បារាំងមានលេខ 00367803។ លោកស្រីនិយាយថា ដំបូងលោកស្រីជាមេភូមិ នៅក្នុងចន្លោះឆ្នាំ៧០ ដល់៧៥ ហើយនៅពេលចាប់ផ្ដើមរបបកម្ពុជាប្រជាធិបតេយ្យ ខ្ញុំសូមដកស្រង់៖ "នៅពេលដែលភ្នំពេញត្រូវបានរំដោះ ខ្ញុំស្នាក់នៅក្នុងស្រុកព្រែកប្រាសាទ ខេត្តកំពង់ចាម ហើយនៅពេលនោះគេបានឲ្យ បានតែងតាំងខ្ញុំធ្វើជាៗសមាជិកគណៈស្រុកព្រែកប្រាសាទ ហើយខ្ញុំទទួលខុសត្រូវក្នុងការទទួលអ្នកជម្លៀសពីទីក្រុងភ្នំពេញ"។ សូមបញ្ចប់ការដកស្រង់។ លោកស្រីនៅក្នុងរយៈពេលនោះថាតើស្រុកព្រែកប្រាសាទ គឺជាផ្នែកនៃតំបន់៤២ នៃភូមិភាគឧត្តរដែរឬទេ?

**ឆ៖** ត្រង់ហ្នឹង ខ្ញុំភ្លាប់អត់បាន វាភ្លេចបាត់ហើយ។ បើចន្លោះហ្នឹង ខ្ញុំ គេរៀបចំចាត់តាំងអីចឹងមែន តែវាភ្លេចបាត់ហើយកាលហ្នឹង។

[០៩:៣៩:៤៨]

**ប្រធានអង្គជំនុំ៖**

ខាងសហព្រះរាជអាជ្ញារងអន្តរជាតិ ជួយពិនិត្យមើលផង ព្រែកប្រាសាទឯណា ស្រុកហ្នឹងដូចមិនមានទេ មានតែស្រុកព្រៃប្រសព្វ ហើយដល់ពេលសួរទៅវា--

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** ខ្ញុំសូមបញ្ជាក់ ប្រហែលជាខ្ញុំអានឈ្មោះមិនច្បាស់ គឺថាស្រុកដែលលោកស្រីត្រូវបានគេតែងតាំងធ្វើជា -- គឺស្រុកព្រែកប្រសព្វ។

**លោកស្រី ស៊ូ សឿន៖**

**ឆ៖** ចាស នៅស្រុកព្រែកប្រសព្វមែន។

**ស៖** ឥឡូវនេះ ខ្ញុំសូមរំឭកជូនលោកស្រីបន្តិចគឺការដកស្រង់ពីកិច្ចសម្ភាសន៍របស់ប្ដីលោកស្រីគឺ E3/2782 និង E3/2783, ខ្មែរមានលេខ 00095551, អង់គ្លេសមានលេខ 00089713, និងបារាំងមានលេខ 00596210។ ប្ដីរបស់លោកស្រីបានផ្ដល់អំពីរចនាសម្ព័ន្ធនៃភូមិភាគកណ្ដាល គាត់បានបញ្ជាក់ភូមិភាគកណ្ដាលបែងចែកទៅជាតំបន់ចំនួនបី គឺតំបន់៤២, ៤៣, និង ៤៤។ ហើយចំពោះតំបន់៤២ គឺថារួមមាន តាំងគោក បារាយណ៍ ស្ទឹងត្រង់ ចំការលើ និងស្រុកព្រែកប្រសព្វ។ ហើយលោកស្រីអាចនឹកឃើញបានដែរឬទេ អំពីហេតុ -- អំពី -- គឺថាមានស្រុកចំនួនប្រាំដែលបង្កើតបានជាតំបន់៤២ ដែលក្នុងនោះគឺរួមមានស្រុកព្រែកប្រសព្វ ហើយនិងស្រុកចំការលើផងដែរ?

**ឆ៖** ខ្ញុំដូចជាចាំមិនបាន ចាំតែស្រុកព្រែកប្រសព្វមួយ ចំការលើមួយ ក្រៅពីហ្នឹងវាភ្លេច។ ពីមុនខ្ញុំក្ដាប់បាន តែឥឡូវខ្ញុំភ្លេចហើយ រកនឹកមិនឃើញទេ។

[០៩:៤២:៥៨]

**ស៖** មិនអីទេ លោកស្រី។ ឥឡូវនេះ យើងត្រឡប់ទៅនិយាយអំពីតួនាទីរបស់លោកស្រីនៅពេលនោះវិញ។ នៅក្នុងកិច្ចសម្ភាសន៍របស់លោកស្រីគឺ E3/5294 លោកស្រីនិយាយថាលោកស្រីរស់នៅក្នុងស្រុកព្រែកប្រសព្វ ប្រហែលជាកន្លះឆ្នាំ។ ហើយបន្ទាប់មកទៀត គេបញ្ជូនលោកស្រីទៅស្រុកចំការលើ ហើយតែងតាំងលោកស្រីធ្វើជាគណៈស្រុកចំការលើ ទទួលខុសត្រូវលើកិច្ចការនារី។ តើខ្ញុំយល់ត្រឹមត្រូវដែរឬទេ ដែលថា គឺនៅចុងឆ្នាំ៧៥ គឺ៦ខែក្រោយថ្ងៃ១៧ មេសា ដែលលោកស្រីបានផ្លាស់ទៅស្រុកចំការលើ ហើយក្លាយទៅជាសមាជិកគណៈស្រុកនៅស្រុកចំការលើនោះ?

**ឆ៖** ចាស ខ្ញុំត្រឹមត្រូវហើយ ព្រោះខ្ញុំនៅស្រុកព្រែកប្រសព្វនោះ វាបានថាតែកន្លះឆ្នាំចុះ ហើយក្រោយមក គេបញ្ជូនខ្ញុំមកស្រុកចំការលើ។ ស្រុកចំការលើហ្នឹង គឺធ្វើបានតែ១ឆ្នាំទេ ចូលក្នុងគណៈកម្មការស្រុក ហើយប្រាំនាក់ហ្នឹងមានតែខ្ញុំមួយទេស្រី ចែកការងារគ្នាធ្វើ មានតែប៉ុណ្ណឹង។ ហើយក្រៅពីហ្នឹង ខ្ញុំភ្លេចអស់ហើយ រកនឹងមិនឃើញទេ។

**ស៖** ពាក់ព័ន្ធទៅនឹងការតែងតាំងលោកស្រីនៅស្រុកចំការលើ លោកស្រីបាននិយាយថា៖ "ខ្ញុំត្រូវបានតែងតាំងជាលេខាតំបន់, តុល គឺជាលេខាតំបន់"។ ដូច្នេះខ្ញុំចង់សួរលោកស្រីថា បុគ្គលដែលលោកស្រីហៅថា តុល ដែលជាលេខាតំបន់ហ្នឹង ថាតើគាត់ជាបងប្អូនជីដូនមួយប្ដីរបស់លោកស្រីហ្នឹង

តើមែនដែរឬទេ?

**ឆ៖** មិនមែនទេលោកប្រធាន អ្នកដទៃ អ្នកស្រុកជិត ដូចថាមួយនៅស្រុក មួយៗនៅស្រុកមួយនៅឆ្ងាយពីគ្នាដែរ គ្រាន់តែខេត្តជាមួយគ្នា តែស្រុកដោយខ្លួន អត់មានជាប់សាច់ឈាមអីទេ។

**ស៖** តើលោកស្រី ហើយនិងប្ដីរបស់លោកស្រីស្គាល់ គុល ដែលជាលេខាតំបន់ហ្នឹងរយៈពេលប៉ុន្មានឆ្នាំមកហើយ យូរប៉ុនណាដែរ?

[០៩:៤៦:០៤]

**ឆ៖** ខ្ញុំទើបនឹងស្គាល់ពេលគាត់ឡើងធ្វើប្រធានតំបន់។ តែចំណែកខាងគ្រួសារ ដឹងគាត់ស្គាល់ពីត្រឹមណាមក ខ្ញុំក៏អត់ដឹងដែរ។

**ស៖** សូមអរគុណលោកស្រី។ នៅក្នុងកិច្ចសម្ភាសន៍របស់លោកស្រី លោកស្រីនិយាយមនុស្សម្នាក់ទៀត នៅក្នុងគណៈស្រុកចំការលើផងដែរ ដែលលោកស្រីហៅឈ្មោះថា បែន។ តើលោកស្រីអាចប្រាប់បានទេថា បែន ហ្នឹង -- ឈ្មោះ បាន ហ្នឹងជាអ្នកណាដែរ?

**ឆ៖** ឈ្មោះ បាន ជាអ្នកស្រុក គាត់នៅតាមទន្លេ នៅឯទន្លេឯណោះទេ គ្រាន់តែស្គាល់ពេលយើងធ្វើការរៀបចំតំបន់ គេរៀបចំឲ្យចូលក្នុងគណៈកម្មការ ស្គាល់ពេលនុំងហើយ។

**ស៖** តើបុគ្គលឈ្មោះ បាន ដែលៗគាត់បានផ្ដល់សក្ខីកម្មថា គាត់ជាគណៈស្រុកចំការលើ ហើយក៏ជាសាច់ថ្លៃរបស់ប្ដីលោកស្រី។ តើ បាន ហ្នឹងគឺជាមនុស្សម្នាក់ដែលលោកស្រីនិយាយថា ជាសាច់ថ្លៃរបស់លោកស្រី ហើយជាប្ដីបងប្អូនជីដូនមួយលោកស្រីហ្នឹង តើមែនដែរឬទេ?

**ឆ៖** មិនមែនទេប្រធាន គ្រាន់តែថាអ្នកស្រុក គាត់នៅរកស៊ីតាមទន្លេ តាមអីអ៊ីចឹង មិនមែនសាច់ឈាមអីខ្ញុំទេ សាច់ឈាមខាងគ្រួសារ ក៏អត់ដែរ។

**លោក ឌេល លីសាក់៖**

លោកប្រធាន ខ្ញុំសូមអនុញ្ញាតផ្ដល់ជូនសាក្សី នូវកំណត់ហេតុស្ដាប់ចម្លើយសាក្សីរបស់បុគ្គលម្នាក់ គឺឯកសារ E3/ -- E319/19.3.86 ខ្ញុំសូមអានមួយសាទៀត E319/19.3.86។ ខ្ញុំនឹងមិនអានឈ្មោះពេញរបស់បុគ្គលនេះទេ ព្រោះគាត់ជាអង្គជំនុំ -- គឺជាសាក្សីរបស់អង្គជំនុំជម្រះ គឺ 2-TCW-950 ដែលគាត់បានបញ្ជាក់ថា គាត់គឺជាសាច់ថ្លៃរបស់សាក្សី ហើយគាត់ធ្វើការងារនៅក្នុងគណៈស្រុកចំការលើ។ ដូច្នេះ ខ្ញុំចង់បង្ហាញចម្លើយនេះ ជូនទៅសាក្សី។

*(ចៅក្រមពិភាក្សាគ្នា)*

[០៩:៤៩:៣៥]

**ប្រធានអង្គជំនុំ៖**

យើងបានទទួលព័ត៌មានថាសាក្សីគាត់អត់អាចអានបានទេ ព្រោះអត់ចេះអក្សរទេ អត់ចេះអាន។

**លោក ខេល លីសាក់៖**

ដូច្នេះសូមអនុញ្ញាត តើគាត់ត្រឹមតែអានឈ្មោះ ឬក៏អាចថា បុគ្គលិកខាង ធី.ភី.អូ អាចជួយគាត់ដើម្បីឲ្យគាត់អាចកំណត់ថា គាត់ស្គាល់បុគ្គលហ្នឹង ឬក៏អត់។ តើបានទេ លោកប្រធាន?

**ប្រធានអង្គជំនុំ៖**

បាទ អាចបាន ហើយមន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលបញ្ហានេះ។ អានខ្សឹបៗប្រាប់គាត់ទៅបានហើយ។

**សួរដោយលោក ខេល លីសាក់៖**

**ស៖** លោកស្រី ខ្ញុំមិនចង់ឲ្យលោកស្រីអានឈ្មោះគាត់ពេញ អានឮៗនោះទេ។ ខ្ញុំចង់ជម្រាបលោកស្រីថា បុគ្គលនេះ ក៏គាត់មានឈ្មោះបដិវត្តជាច្រើន ហើយក្នុងឈ្មោះនោះ គឺឈ្មោះ ផុស, ប៉ុស ហើយនិង ហ្វ។ តើលោកស្រីចាំឈ្មោះមនុស្សដែលឈ្មោះ ផុស ឬក៏ឈ្មោះ ហ្វ ដែលធ្វើការនៅក្នុងគណៈស្រុកចំការលើជាមួយលោកស្រី ហើយជាសាច់ថ្លៃរបស់លោកស្រី គឺជាប្ដីរបស់ប្អូនជីដូនមួយលោកស្រីនោះដែរឬទេ តើលោកស្រីចាំទេ?

[០៩:៥១:៤២]

**លោកស្រី ស៊ូ សឿន៖**

**ឆ៖** ដំបូង ដូចខ្ញុំស្ដាប់បានថា ស្វរ តាបាន។ ដល់ក្រោយមកនេះ តាផុស ខ្ញុំស្គាល់ ហើយក៏ត្រូវជាបងប្អូនខ្ញុំ អត់មានបងប្អូនជីដូនមួយជាមួយខ្ញុំទេ មិនជាមួយគ្រួសារទេ ជាមួយខ្ញុំ។ ស្គាល់ឈ្មោះគាត់គ្រាន់តែថា ត្រឹមស្គាល់ ធ្លាប់ជាបងជាប្អូនប៉ុណ្ណឹង។

**ស៖** តើឈ្មោះ ផុស ហ្នឹងគឺជា គឺថាគាត់ធ្លាប់ធ្វើការនៅគណៈស្រុកចំការលើជាមួយលោកស្រីហ្នឹងមែនទេ?

**ឆ៖** ចាស ដូចជាភ្លេចបាត់ហើយត្រង់ហ្នឹង ខ្ញុំចាំតែឈ្មោះ ពូបាន មួយ ក្រៅពីហ្នឹងអត់ ភ្លេចៗមនុស្សដែលចូលធ្វើការទាំងប៉ុន្មានដែលខ្ញុំភ្លេចដែរ។

**ស៖** ខ្ញុំសួរលោកស្រីជាទូទៅ អំពីស្រុកចំការលើបន្តិច។ តើលោកស្រីចាំទេ ថាតើមានមនុស្ស

ប្រហែលជាប៉ុន្មាននាក់ដែរ នៅស្រុកចំការលើហ្នឹង នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ?

**ឆ៖** ចំនួន ចាស ឆ្លើយចំនួនមនុស្ស ប្រជាជន ហើយក៏ជាគណៈស្រុក ចង់សួរបញ្ជាក់អ៊ីចឹង?

**ស៖** ខ្ញុំចង់សួរអំពីចំនួនប្រជាជន ប្រជាជនទូទៅ តើនៅស្រុកចំការលើហ្នឹង មានប្រជាជនរស់នៅប៉ុន្មាននាក់ដែរ?

[០៩:៥៣:៣៨]

**ឆ៖** ចាស ខ្ញុំក្តាប់អត់បាន ព្រោះខ្ញុំអត់ចេះកត់ត្រាអី គឺស្រេចទៅលើលេខាស្រុកទាំងអស់។ កិច្ចការអី ខ្ញុំមិនសូវដឹងទេ ព្រោះខ្ញុំមិនបានកត់កំណត់ហេតុ រឿងប្រជាជនសរុបប៉ុន្មានៗ ខ្ញុំអត់សូវដឹងដែរ។

**ស៖** ឥឡូវនេះ យើងនិយាយអំពីតួនាទីរបស់លោកស្រីបន្តទៀត។ លោកស្រីបានផ្តល់សក្ខីកម្មថា នៅចុង៧៥ លោកស្រីក្លាយទៅជាសមាជិកគណៈស្រុកចំការលើ។ តើនៅពេលក្រោយមកទៀត លោកស្រីក្លាយទៅជាលេខាស្រុកចំការលើដែរឬទេ?

**ឆ៖** ខ្ញុំនៅជាសមាជិករហូត ទាល់តែ -- ខ្ញុំធ្វើស្រុកបានតែ១ឆ្នាំទេ ស្រុកចំការលើ។ ក្រោមក ក្រោយមក ខ្ញុំឆ្លងទន្លេទៅ ហើយខ្ញុំឈឺទៅ អត់បានទៅធ្វើការទេ។ ដូច្នេះ នៅជាសមាជិកគេរហូត ហើយសមាជិកហ្នឹងទទួលផ្នែកខាងនារី ខាងលើកទំនប់ លើកប្រឡាយ តែខ្ញុំមិនបានចុះជាប់ជាមួយបងប្អូនទេ។

**ស៖** លោកស្រីសាក្សី ខ្ញុំចង់ជម្រាប់លោកស្រីថាមានកម្មាភិបាលដែលស្និទ្ធស្នាលនឹងលោកស្រីមួយចំនួនបាននិយាយថា នៅក្នុងចុងឆ្នាំ៧៧ លោកស្រីបានក្លាយទៅជាលេខាស្រុកចំការលើ។ ខ្ញុំសូមអានជូនលោកស្រីស្តាប់នូវឯកសារមួយ គឺឯកសារដែលខ្ញុំទើបតែផ្តល់ជូនលោកស្រីហ្នឹង គឺឯកសាររបស់សាច់ថ្លៃលោកស្រីឈ្មោះ បាន ឬក៏ ផុស នៅក្នុងចម្លើយទី១០ នៃកិច្ចសម្ភាសន៍របស់គាត់ គឺ E319/19.3.86។ គាត់បានផ្តល់ចម្លើយដូចតទៅនេះ ខ្ញុំសូមដកស្រង់ "ស៊ូ សឿន ត្រូវបានគេចាត់តាំងឲ្យធ្វើជាលេខាស្រុកចំការលើនៅពេលក្រោយ ប្រហែលជានៅក្នុងឆ្នាំ ចុងឆ្នាំ៧៧។ នៅពេលនោះ អឿនបានដកខ្ញុំពីតំណែងជាប្រធានពាណិជ្ជកម្មតំបន់៤២ មកធ្វើជាអនុរបស់ ស៊ូ សឿន"។ សូមបញ្ចប់ការដកស្រង់។ គាត់បាននិយាយដដែលៗនៅក្នុងកិច្ចសម្ភាសន៍មួយចំនួន។ លោកស្រីសាក្សី ថាតើអ្វីដែលខ្ញុំអានហ្នឹងធ្វើឲ្យលោកស្រីនឹកឃើញដែរឬទេ ថាលោកស្រីក្លាយទៅជាលេខាស្រុកចំការលើនៅចុងឆ្នាំ៧៧? ហើយ ផុស មកធ្វើជាអនុលេខារបស់លោកស្រីនោះ?

[០៩:៥៧:០៧]

**ឆ៖** ខ្ញុំដូចជាមិនបានចាំ ព្រោះអត់បានចូលធ្វើការជាមួយគេ ដល់អ៊ីចឹងនឹកមិនឃើញៗ ហើយក៏តាមមើលវាភ្លេចបាត់ហើយ។ ហើយយូរឆ្នាំហើយ ខ្ញុំភ្លេចច្រើន។

**ស៖** នៅក្នុងការដកស្រង់ដែលខ្ញុំទើបតែអានគឺ បាន ឬក៏ ផុស ដែលជាសាច់ថ្លៃរបស់លោកស្រីនោះ បាននិយាយអំពីឈ្មោះ អឿន ដែលជាលេខាតំបន់៤២ក្រោយ តុល។ តើ អឿន ហ្នឹងជាបងប្រុសរបស់លោកស្រីមែនទេ? ហើយថាគាត់ពិតជាក្លាយជាលេខាតំបន់៤២នៅក្នុងឆ្នាំ៧៧ ក្រោយ តុល ហ្នឹងមែនទេ?

**ឆ៖** ចាស អឿន នេះជាប្អូនរបស់ខ្ញុំទេ ជាប្អូនបង្កើតរបស់ខ្ញុំ។ ហើយឆ្នាំហ្នឹងគឺចាត់តាំងធ្វើជាលេខាតំបន់ហ្នឹងក៏ប្រហែលជាមិនមែនហើយយ៉ាង ខ្ញុំភ្លេចបាត់ដែរហ្នឹង ព្រោះពេលវាខ្លី ហើយក៏អត់បានជាប់ធ្វើការជាមួយនឹងគេ។ ដូច្នេះការភ្លេចភ្លាំងក៏វាច្រើន។

**ស៖** លោកស្រីសាក្សី តើលោកស្រីចាំឈ្មោះ ឈឹម ដែរឬទេ? គឺ ឈឹម មកពីស្រុកតាកែវក្នុងភូមិភាគនិរតី ហើយគេយកមកភូមិភាគឧត្តរនៅឆ្នាំ៧៧ ហើយគេយកមកធ្វើជាប្រធានចម្ការកៅស៊ូនៅចំការអណ្ដូង គឺឈ្មោះ ជឹម នោះដែរឬទេ? តើលោកស្រីចាំឈ្មោះ ជឹម ដែរឬទេ? គឺជាមនុស្សដែលគេយកមកធ្វើជាប្រធានចម្ការកៅស៊ូនៅក្នុងស្រុករបស់លោកស្រីនោះ តើលោកស្រីចាំទេ?

[០៩:៥៩:៣៨]

**ឆ៖** ខ្ញុំអត់ចាំទេ សូម្បីតែបងប្អូនក៏មិនចាំដែរ ហើយដល់អ្នកដទៃទៀត មិនដែលស្គាល់គ្នា ដល់ពេលការរៀបចំ ខ្ញុំអត់ស្គាល់គេ ក៏អត់ដឹងគេរៀបចំម៉េចដែរ។

**ស៖** ឥឡូវនេះខ្ញុំសូមធ្វើការសួរទាក់ទងទៅនឹងការដ្ឋានទំនប់ ១មករាវិញលោកស្រី។ ខ្ញុំចង់សាកសួរអំពីកូនប្រុសរបស់លោកស្រីគឺ កែ ពេជ្រវណ្ណៈ។ ក្នុងកិច្ចសម្ភាសន៍របស់គាត់គឺ E3/35 ខ្មែរមានលេខ 00340563, អង់គ្លេសមានលេខ 00346149, បារាំងមានលេខ 00367721។ គាត់បានរៀបរាប់អំពីការនៅក្នុងឆ្នាំ៧៦ គេបានបញ្ជូនគាត់ទៅសិក្សានៅភ្នំពេញ ជាមួយមនុស្សម្នាក់ឈ្មោះ ពេជ សុខា ហើយនិងមនុស្សម្នាក់ទៀតដែលគាត់ហៅថា ពូឆាយ ហៅ ពូឆាំ។ តើលោកស្រីស្គាល់មនុស្សពីរនាក់នេះដែរឬទេ គឺមនុស្សពីរនាក់ដែលកូនរបស់លោកស្រី សិក្សាជាមួយនៅក្នុងទីក្រុងភ្នំពេញគឺឈ្មោះ ឆាំ ហើយនិង ពេជ សុខា នោះ?

**ឆ៖** ខ្ញុំស្គាល់ ប៉ុន្តែអ្នកពីរនាក់ហ្នឹងគឺស្លាប់អស់ហើយ គ្មានអ្នកណានៅ។

**ស៖** តើ ឆាំ ហ្នឹងជានរណាដែរ?

**ឆ៖** ឆាំ ហ្នឹងក៏អ្នកនៅជាមួយៗគ្រួសារខ្ញុំ។

**ស៖** តើ ឆាំ ហ្នឹងគឺជាមនុស្សម្នាក់ដែលធ្វើការឲ្យប្តីលោកស្រី រហូតនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យហ្នឹងមែនទេ?

**ឆ៖** ប៉ុន្តែស្លាប់បាត់ហើយ។

[១០:០២:២៨]

**ស៖** ខ្ញុំយល់ថាគាត់បានស្លាប់ហើយ ប៉ុន្តែខ្ញុំចង់សួរលោកស្រីថា តើគាត់គឺជាមនុស្សម្នាក់ដែលជិតស្និទ្ធជាមួយប្តីរបស់លោកស្រី ហើយជាមនុស្សម្នាក់ដែលធ្វើការជាមួយប្តីលោកស្រីរហូតនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យហ្នឹងមែនទេ?

**ឆ៖** ចាស មែន។

**ស៖** តើ ឆាំ មានតួនាទីគ្រប់គ្រងទៅលើការដ្ឋានសាងសង់ទំនប់១មករាដែរឬទេ?

**ឆ៖** ត្រង់ហ្នឹងខ្ញុំអត់ដឹងទេ ព្រោះទៅជាប់ជាមួយតែគាត់ ប៉ុន្តែខ្ញុំអត់ដឹងកិច្ចការគេធ្វើអី ខ្ញុំអត់ដឹងទេ ព្រោះខ្ញុំនៅផ្សេង គាត់នៅផ្សេង កិច្ចការដែលគេត្រូវធ្វើអីខ្លះ ខ្ញុំមិនសូវដឹងដែរ។ ខ្ញុំឆ្លើយតាមត្រង់ ខ្ញុំអត់ដឹង ខ្ញុំថាអត់ដឹង។

**ស៖** ឥឡូវនេះ ខ្ញុំសូមបន្តកិច្ចសម្ភាសន៍របស់កូនប្រុសលោកស្រីគឺឯកសារ E3/35។ គាត់បានផ្តល់សក្ខីកម្មថា ក្រោយពេលដែលគាត់ត្រឡប់មកពីការសិក្សានៅទីក្រុងភ្នំពេញ ខ្ញុំសូមដកស្រង់៖ “សំណួរ៖ បន្ទាប់ពីលោកបញ្ចប់ការសិក្សារបស់លោក តើគេឲ្យលោកធ្វើអ្វី? ឆ្លើយ៖ ខ្ញុំបានត្រឡប់មកនៅកំពង់ចាមវិញ ហើយដើរតាមឪពុកខ្ញុំទៅរៀបចំធ្វើទំនប់១មករា។ សំណួរ៖ តើទំនប់១មករា គេចាប់លើកពីឆ្នាំណា? ឆ្លើយ៖ ទំនប់នេះចាប់ផ្តើមគ្រោងតាំងពីពាក់កណ្តាលឆ្នាំ១៩៧៦”។ បញ្ចប់ការដកស្រង់។ ដូច្នេះខ្ញុំចង់សួរលោកស្រីថា តើលោកស្រីដឹងដែរឬទេ ថាតើប្តីរបស់លោកស្រី ត្រូវធ្វើការទំនាក់ទំនង ហើយត្រូវទទួលបានការអនុម័តយល់ព្រមពីមេដឹកនាំបក្សនៅទីក្រុងភ្នំពេញដែរឬទេ ទាក់ទងទៅនឹងការរៀបចំផែនការ ការកសាងទំនប់១មករានោះ?

[១០:០៥:០០]

**ឆ៖** ចំណែកការរៀបចំទាក់ទងធ្វើទំនប់ហ្នឹង ខ្ញុំមិនដឹងទេ ព្រោះរៀបចំពីឆ្នាំណាមកដល់ឆ្នាំណាក៏ខ្ញុំមិនដឹងដែរ ព្រោះកិច្ចការនេះ មិនសូវ -- ស្ត្រីមិនសូវដឹងទេរឿងអីចឹង។ ចំណែកខ្ញុំបានតែនាំសហករណ៍

ធ្វើការនៅលើកទំនប់ លើកប្រឡាយប៉ុណ្ណឹង។ តែកិច្ចការរបស់គេ ខ្ញុំអត់សូវដឹងទេ មិនសូវដឹង ឬថាមិនដឹងតែម្តង។

**ស៖** ឥឡូវនេះ ខ្ញុំសូមសួរសំណួរទូទៅទាក់ទងទៅនឹងប្តីរបស់លោកស្រី។ តើគាត់ទៅចូលរួមកិច្ចប្រជុំនៅភ្នំពេញហ្នឹង ញឹកញាប់ប៉ុនណាដែរ?

**ឆ៖** ចាស ជួនកាលក៏ខ្ញុំដឹង ជួនកាលខ្ញុំនៅដោយខ្លួនពីគ្នា ព្រោះថាផ្ទះខ្ញុំនៅចំការលើឯណោះ ហើយគាត់នៅកំពង់ចាម។ ជួនកាលទៅធ្វើការម្តងពីរដង បានខ្ញុំដឹងម្តង ក្នុង១ខែ ឬ២ខែ ខ្ញុំមិនសូវដឹងដែរ អារឿងការងារហ្នឹង ដឹងតែអារឿងថាយូរៗដឹងម្តង ព្រោះខ្ញុំដឹងពេលដែលថាខ្ញុំទៅលេងផ្ទះអ៊ីចឹងទៅលេងផ្ទះគាត់ទៅ ខ្ញុំដឹង។ បើនៅផ្ទះខ្ញុំ ជួនកាលកន្លះឆ្នាំអី ៣ខែអីមិនទាន់ជួបគ្នាម្តង។

**ស៖** តើលោកស្រីធ្លាប់ទៅជាមួយប្តីរបស់លោកស្រី នៅពេលដែលគាត់ទៅទីក្រុងភ្នំពេញដែរឬទេ?

**ឆ៖** ខ្ញុំអត់ដែរធ្វើដំណើរទៅជាមួយគ្នាទេ។ បើខ្ញុំទៅៗជាមួយអ្នកផ្សេង ទៅជាមួយស្រីៗដូចគ្នា តែចំណែកខាងគាត់ ខ្ញុំអត់ដែលបានដើរជាមួយទេ។

**ស៖** ខ្ញុំចង់បញ្ជាក់បន្តិច ថាតើមានការបកប្រែត្រឹមត្រូវដែរឬទេ? តើលោកស្រីចង់និយាយថា លោកស្រីទៅទីក្រុងភ្នំពេញជាមួយនឹងក្រុមកម្មាភិបាលស្ត្រី តើខ្ញុំយល់អ៊ីចឹងត្រឹមត្រូវដែរឬទេ?

[១០:០៧:៤៦]

**ឆ៖** ខ្ញុំទៅជាមួយតែស្ត្រីដូចគ្នា ទៅដូចថាទៅជួបប្រធាន ដូចមកធ្វើការនៅភ្នំពេញបានជួបបង នួន ជា អីអ៊ីចឹងទៅ។ បើថាមិនបានធ្វើអី មិនដែលបានជួបគ្នាទេ។

**ស៖** តើលោកស្រីអាចប្រាប់បានទេ ថាលោកស្រីទៅទីក្រុងភ្នំពេញជាមួយនឹងកម្មាភិបាលស្ត្រីដូចគ្នា ជាមួយ នួន ជា ហ្នឹង តើលោកស្រីទៅនៅពេលណាដែរ ទៅជួប នួន ជា នៅភ្នំពេញហ្នឹង លោកស្រីអាចប្រាប់ឲ្យបានលម្អិតបន្តិចបានទេ?

**ឆ៖** ពេលខ្ញុំទៅគឺថា ឥឡូវ ខ្ញុំមិនចាំ ព្រោះតាំងពីឆ្នាំ៧០មករហូតមកដល់៧៥ ទៅដែរ តែវាភ្លេច មិនដឹងទៅពេលណា ម៉ោងណា ឆ្នាំណា ក៏ខែណា ក៏ខ្ញុំដូចមិនចាំ។ ដឹងថាទៅៗ តែមិនដឹងថាឆ្នាំនេះត្រូវទៅ ឆ្នាំនោះត្រូវទៅ ខ្ញុំអត់ចាំទេ។

**ស៖** តើលោកស្រីទៅជួប នួន ជា ជាមួយនឹងក្រុមកម្មាភិបាលស្ត្រីហ្នឹង មានគោលបំណងអ្វីដែរ ឬក៏មានគោលដៅអ្វីដែរ?

**ផះ** ពេលទៅជួបគាត់ហ្នឹង ទៅគ្នាច្រើនរាប់រយនាក់ហ្នឹង គឺទៅរៀន អប់រំខាងនយោបាយ ធ្វើនាំប្រជាជន សហករណ៍រៀបចំធ្វើស្រូវមួយឆ្នាំបានប៉ុន្មានតោនៗអីចឹង យើងរៀបចំបងប្អូនឱ្យធ្វើ បងប្អូនសហករណ៍រៀបចំឱ្យស្រួលដើម្បីបង្កបង្កើនផលមួយឆ្នាំ ត្រូវបានប៉ុន្មានតោនក្នុង១ហិកតា ធ្វើប៉ុន្មានដងគឺគាត់អប់រំអីចឹង។ អាហ្នឹងខាងផ្នែកស្ត្រី។

[១០:១០:២៧]

**លោក ឌេល លីសាក់៖**

សូមអរគុណលោកស្រីសាក្សី។ ឥឡូវនេះ ខ្ញុំត្រូវបន្តទៅប្រធានបទថ្មី តើលោកប្រធានយល់ថា ខ្ញុំគួរបន្តទៅទៀត ឬមួយក៏យើងឈប់សម្រាកសិន?

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ឥឡូវនេះដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅ រហូតដល់ម៉ោងដប់កន្លះ សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាក នៅបន្ទប់រង់ចាំសម្រាប់សាក្សី និងអ្នកជំនាញ ដល់សាក្សីរូបនេះ នៅក្នុងអំឡុងពេលឈប់សម្រាក និងឱ្យអញ្ជើញគាត់ រួមទាំងបុគ្គលិកអង្គការធី.ភី.អូ មកកាន់កន្លែងផ្តល់សក្ខីកម្ម នៅក្នុងបន្ទប់សវនាការនេះ នៅវេលាម៉ោងដប់កន្លះ។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១០:១១ នាទី ដល់ម៉ោង ១០:៣១ នាទី)*

[១០:៣១:៣៧]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ និងផ្តល់វេទិកាជូនទៅសហព្រះរាជអាជ្ញារងអន្តរជាតិ ដើម្បីបន្តការតាំងសំណួរដេញដោលចំពោះសាក្សី។

**លោក ឌេល លីសាក់៖**

បាទ សូមអរគុណលោកប្រធាន។

**សួរដោយលោក ខេល លីសាក់៖**

**ស៖** លោកស្រីសាក្សី ឥឡូវនេះ ខ្ញុំសូមចូលទៅសួរមួយចំនួនដែលទាក់ទងទៅការងារ ដែលឲ្យពលករធ្វើនៅទំនប់១មករា។ នៅក្នុងកំណត់ហេតុស្តាប់ចម្លើយលោកស្រី ឯកសារ E3/5294 ERNគឺ 00348834, ERN ជាភាសាអង់គ្លេសគឺ 00360107, ERN ជាភាសាបារាំង 00367810។ លោកស្រីបាននិយាយដូចតទៅនេះ ខ្ញុំសូមដកស្រង់ គេសួរលោកថា៖ “តើអ្នកដែលធ្វើនៅ -- ធ្វើការជាមួយលោកត្រូវបានគេបញ្ជូនធ្វើការនៅទំនប់១មករាដែរឬទេ?” លោកស្រីឆ្លើយ៖ “ស្រុករបស់ខ្ញុំបានបញ្ជូនពលករទៅទីនោះ ព្រោះថាស្រុកទាំងអស់ទទួលបទបញ្ជាឲ្យធ្វើយ៉ាងដូច្នោះ។” សូមបញ្ចប់ការដកស្រង់។ អ៊ីចឹងខ្ញុំសួរថា តើមានពលករប៉ុន្មាននាក់នៃស្រុកចំការលើនោះ ត្រូវបានគេចាត់តាំងឲ្យទៅលើកទំនប់១មករាសរុបទាំងអស់ប៉ុន្មាននាក់?

[១០:៣៣:១៨]

**លោកស្រី ស៊ូ សឿន៖**

**ឆ៖** ចាស ទំនប់១មករាហ្នឹង ខ្ញុំមិនដឹងកំណត់ប៉ុន្មានទេ ព្រោះគេបញ្ជូនបន្តបន្ទាប់។ មិនដឹងថាសហករណ៍ត្រូវគេដកកម្លាំងទៅប៉ុន្មាន ក្នុងប៉ុន្មានៗ ក៏ខ្ញុំមិនដឹងដែរ។ បានព្រោះថាមិនដឹង មកពីខ្ញុំអត់បានកាន់បញ្ជី មានតែលេខាស្រុក។

**ស៖** នៅក្នុងកំណត់ហេតុស្តាប់ចម្លើយរបស់លោកស្រីចំពោះមុខសហចៅក្រមស៊ើបអង្កេត លោកស្រីបាននិយាយថា ទំនួលខុសត្រូវរបស់លោកនៅស្រុកចំការលើនោះ លោកស្រីត្រូវមើលខុសត្រូវលើកម្មករដែលលើកទំនប់១មករានុ៎ង។ តើត្រឹមត្រូវដែរឬទេ?

**ឆ៖** ដឹងឆ្លើយថាម៉េច។ ខ្ញុំឆ្លើយអំមិញហើយ ឲ្យឆ្លើយថាម៉េចទៀត។

**ប្រធានអង្គជំនុំ៖**

បាទ សហព្រះរាជអាជ្ញារងអន្តរជាតិ តាំងសំណួរសាជាថ្មីម្តងទៀត គាត់ស្តាប់មិនយល់ទេ នូវសំណួររបស់លោក ព្រោះគាត់ថាឆ្លើយ បានឆ្លើយរួចហើយ។

**សួរដោយលោក ខេល លីសាក់៖**

**ស៖** បាទ ខ្ញុំនឹងរៀបរាប់អំពីអ្វីដែលលោកស្រីបាននិយាយ គឺកំណត់ហេតុស្តាប់ចម្លើយរបស់លោកស្រីដែលលោកស្រីបានឆ្លើយនៅចំពោះមុខសហចៅក្រមស៊ើបអង្កេត គឺឯកសារ E3/5294, ERN ជាភាសាខ្មែរគឺ 00 -- គេនិយាយអំពីទំនួលខុសត្រូវរបស់លោកស្រី ហើយលោកស្រីបានឆ្លើយថា ទំនួល

ខុសត្រូវរបស់លោកស្រី គឺលោកស្រីទទួលខុសត្រូវអំពីការសង់ទំនប់ ឬជីកប្រឡាយ។ អ៊ីចឹងខ្ញុំសូមសួរលោកស្រីថា តើលោកស្រីមានទំនួលខុសត្រូវក្នុងការគ្រប់គ្រងពលករដែលជីកប្រឡាយលើកទំនប់ហ្នឹងដែរឬទេ?

[១០:៣៦:១១]

**លោកស្រី ស៊ូ សឿន៖**

**ឆ៖** ចាស ខ្ញុំឆ្លើយអំមិញនេះ គឺថាខ្ញុំមិនបានដឹងចំនួនទេ ព្រោះតែបញ្ជូនទៅ -- គ្រាន់តែខ្ញុំរើសពីសហករណ៍បញ្ជូនទៅ តែបញ្ជី១០០នៅលើលេខាស្រុក។ ដូច្នេះខ្ញុំមិនដឹងចំនួនប៉ុន្មានទេ។ ខ្ញុំសូមឆ្លើយប៉ុណ្ណឹង។

**ស៖** តើលោកស្រីដឹងដែរឬទេថា អ្នកណាជាអ្នកទទួលខុសត្រូវពលករស្រុកចំការលើ ដែលត្រូវបានគេបញ្ជូនទៅលើកទំនប់១មករាហ្នឹង?

**ឆ៖** ចាស ខ្ញុំដឹងថា ទៅគេទទួលខុសត្រូវតាមសង្កាត់។ សង្កាត់នីមួយៗសុទ្ធតែមានប្រធានគេអ្នកនាំទៅ។ តែឈ្មោះអ្នកដែលធ្វើប្រធានសង្កាត់ហ្នឹង ខ្ញុំវាមិនចាំៗថា ចំនួន -- មិនចាំឈ្មោះគេ។ ឈ្មោះគេនីមួយៗគឺ ខ្លះក៏ស្លាប់ទៅ ខ្លះក៏នៅ ហើយតែក៏នៅបែកគ្នាឆ្ងាយទៅហើយ ខ្ញុំមិនស្គាល់ មិនចាំឈ្មោះគេទេ។

**ស៖** បាទ សូមអរគុណ។ នៅក្នុងកំណត់ហេតុស្តាប់ចម្លើយរបស់លោកស្រី គឺឯកសារ E3/5294 ERN ជាភាសាខ្មែរ 00348835, ERN ជាភាសាអង់គ្លេស 00360117, ERN ជាភាសាបារាំងគឺ 00367811។ លោកស្រីនិយាយអំពីអ្នកដែលត្រូវបានគេបញ្ជូនទៅលើកទំនប់១មករា។ គេសួរលោកស្រីថា៖ “តើពួកពលករដែលលោកស្រីបញ្ជូនទៅនោះ មានបាត់ខ្លួនដែរឬទេ?” លោកស្រីឆ្លើយថា៖ “មានពេលខ្លះ មិនមែនមានតែពួក១៧មេសានោះទេ ប្រជាជនមូលដ្ឋានក៏មានការបាត់ខ្លួនដែរ”។ លោកស្រីសាក្សី តើលោកស្រីដឹងថា មនុស្សស្រុកចំការលើរបស់លោកស្រីដែលត្រូវបានបញ្ជូនទៅធ្វើការនៅទំនប់១មករា នេះបាត់ខ្លួនតាមរបៀបណាដែរ? តើលោកស្រីដឹងតាមរបៀបណាដែរ?

[១០:៣៩:០៩]

**ឆ៖** ចាស អារឿងបាត់ខ្លួន ពេលដែលទៅនៅធ្វើទំនប់១មករា ខ្ញុំដឹងត្រឹមថា ថាខ្លះគេដកអ្នកនោះទៅរៀនសូត្រ តែប៉ុណ្ណឹង។

**ស៖** តើលោកស្រីដឹងថា គេយកពលករទាំងអស់នោះទៅរៀនសូត្រយ៉ាងដូចម្តេចដែរ? ហេតុអី

ក៏លោកស្រីដឹង?

**ឆ៖** ចាស ខ្ញុំដឹងហ្នឹងដោយប្រធានសង្កាត់នីមួយៗគេប្រាប់ថា ដកអ្នកនេះដកអ្នកនោះយកទៅរៀនសូត្រ។ តែរៀនសូត្រកន្លែងណា ខ្ញុំមិនដឹងទេ។

**ស៖** លោកស្រីបាននិយាយនៅក្នុងកំណត់ហេតុស្ដាប់ចម្លើយរបស់លោកស្រីថា មានប្រជាជន ១៧ និងប្រជាជនមូលដ្ឋានដែលបាត់ខ្លួនផងដែរ។ តើហេតុអ្វីក៏លោកស្រីដឹងថាប្រជាជន១៧មេសា ហើយនិងប្រជាជនមូលដ្ឋាននៃស្រុករបស់លោកស្រីហ្នឹងបាត់ខ្លួន? ដឹងតាមរបៀបណាដែរ?

**ឆ៖** ចាស ដឹងតាមប្រធានសង្កាត់ គេអ្នកនិយាយប្រាប់។ គេថាដកទៅ យកទៅធ្វើការរៀនសូត្រ ដឹងអ៊ីចឹង។

**ស៖** តើលោកស្រីមានដឹងថា អ្នកដែលមានបងប្អូនទៅធ្វើការនៅទំនប់១មករាទាំងបានកត់សម្គាល់ថា បងប្អូនរបស់គេដែលបានធ្វើការនៅទំនប់១មករាហ្នឹងមិនឃើញត្រឡប់មកវិញទេ? តើពួកគេទាំងអស់ដែលនៅរស់ហ្នឹង គេដឹងថាបងប្អូនគេមានរឿងអីកើតឡើងចំពោះបងប្អូនគេដែរឬទេ?

[១០:៤១:៥៦]

**ឆ៖** ចាស ខ្ញុំមិនដឹង ព្រោះគេអត់មកសួរ អត់ដឹងរឿង ថាបាត់ក៏បាត់ទៅ ប្រធានគេថា ឥឡូវគេហៅរៀនសូត្រហើយ ប្រាប់តាមដំណើរហ្នឹងទៅ ដំណើរថាឥឡូវគេយកទៅរៀនសូត្រ។ រឿងបាត់អ៊ីចឹង ខ្ញុំមិនដឹងដែរ។

**ស៖** បាទ ឥឡូវនេះខ្ញុំសូមចោទសំណួរមួយចំនួនទាក់ទងទៅនឹងទស្សនកិច្ចដែលលោកស្រីបានធ្វើនៅទំនប់១មករា។ បាទ ជាបឋមតើលោកស្រីអាចជម្រាបជូនតុលាការបានដែរឬទេ ថាលោកស្រីបានទៅទំនប់១មករានោះប៉ុន្មានដងដែរ?

**ឆ៖** ចាស ខ្ញុំទំនប់១មករាហ្នឹងខ្ញុំក៏ទៅច្រើនដងហើយ តែដឹងចំនួនប៉ុន្មានៗ ខ្ញុំអត់ចាំទេ។

**ស៖** ហេតុអ្វីបានជាលោកស្រីទៅទំនប់១មករាហ្នឹងច្រើនដង? មូលហេតុអ្វីដែលបានទៅច្រើនដង?

**ឆ៖** ទៅច្រើនដង មូលហេតុ មួយគ្រួសារទៅធ្វើការនៅហ្នឹងទៅលេងផង។ ជួនកាលខ្លះក៏ខ្ញុំទៅតាមមិត្តភក្ដិដូចថាកម្មាភិបាលបបួលទៅ ក៏ទៅមើលទំនប់១មករា ទៅមើលបងប្អូនលើកទំនប់ តើវាជីវភាពវាយ៉ាងម៉េចៗ ខ្ញុំក៏លែលកតាមហ្នឹងទៅ។

**ស៖** នៅពេលដែលលោកស្រីទៅលើកទំនប់១មករានោះ រាល់ដងនោះ ឬជាទូទៅលោកស្រីនៅ

ទីនោះរយៈពេលប៉ុន្មានដែរ?

[១០:៤៤:៤០]

**ឆ៖** ចាសជួនកាលក៏ខ្ញុំនៅបាន២ថ្ងៃ ជួនកាលក៏ខ្ញុំត្រឡប់មកវិញ មិនទៀងដែរ ថាមិនទៀងចុះ។ ពេលណាក៏នៅ ពេលណាក៏មកវិញ ហើយមិនចាំពេលវេលាទេ។

**ស៖** នៅពេលលោកស្រីទៅស្នាក់នៅទីនោះ ពីរបីយប់ ឬពីរបីថ្ងៃហ្នឹង តើលោកស្រីដេកនៅកន្លែងណាដែរ?

**ឆ៖** ចាស កន្លែងហ្នឹងមានជំរំគេ លោកប្រធាន។ មានជំរំគេសម្រាប់នារីទៅសម្រាកជាមួយសហករណ៍ហ្នឹងក៏បាន ទៅជាមួយបងប្អូនលើកទំនប់ លើកប្រឡាយទៅ កន្លែងនោះជាបាយរួម ដូច្នេះអត់គិតថា ស្នាក់នៅកន្លែងណាៗ បងប្អូននៅកន្លែងណាខ្ញុំក៏នៅកន្លែងនោះបានទាំងអស់គ្នា។

**ស៖** តើលោកស្រីអាចរៀបរាប់ពីកន្លែងស្នាក់នៅដែលលោកស្រីបានសម្រាកនៅទីនោះ ពីរបីថ្ងៃ ឬពីរបីយប់នោះ នៅពេលលោកស្រីទៅមើលការដ្ឋានហ្នឹងបានដែរឬទេ? តើកន្លែងស្នាក់នៅហ្នឹងមានទ្រង់ទ្រាយយ៉ាងណាដែរ?

**ឆ៖** ចាស ខ្ញុំសូមឆ្លើយ កន្លែងនៅសម្រាកមើលបងប្អូនសហករណ៍ ទ្រង់ទ្រាយ ខ្ញុំនិយាយអ៊ីចឹងទ្រង់ទ្រាយត្រង់ជីវភាពរស់នៅវាសមរម្យដែរ ពួកលើកទំនប់ លើប្រឡាយមិនខ្វះខាតអីទេ។ ការស្នាក់នៅការដេក ការហូបចុកអី ក៏មិនជាខ្វះអ្វីទេ។ អានេះ ខ្ញុំនិយាយតាមត្រង់អ៊ីចឹងហ្មង។

[១០:៤៦:៥៧]

**ស៖** តើឥឡូវលោកស្រីអាចនិយាយឲ្យច្បាស់ជាងនេះបន្តិចបានដែរឬទេ? តើលោកស្រីអាចបញ្ជាក់បានដែរឬទេ នៅពេលដែលលោកស្រីប្រើពាក្យថា "សមរម្យ" នោះ តើលោកស្រីចង់មានន័យយ៉ាងម៉េចដែរ?

**ឆ៖** ខ្ញុំចង់និយាយថា បងប្អូននៅយ៉ាងម៉េចបាន រស់នៅម៉េចបាន ខ្ញុំក៏រស់នៅតាមបងប្អូនបានហើយសមរម្យក្នុងការជីវភាពរស់នៅ ហូបចុកក៏វាសមរម្យដែរ មិនជាខ្វះជីវភាពទេ ការរស់នៅផ្គត់ផ្គង់តាមអង្គការ។ ពេលនោះគេហៅ "អង្គការ" គឺអង្គការផ្គត់ផ្គង់ម្ហូបម្ហា អង្ករចុក អង្ករហូបអីមិនខ្វះអ្វីទេ។ ហ្នឹងខ្ញុំសូមបញ្ជាក់តែប៉ុណ្ណឹង។

**ស៖** ឥឡូវខ្ញុំសូមចោទសំណួរហ្នឹងឡើងវិញទៀត។ នៅពេលដែលលោកស្រីស្នាក់នៅកន្លែងសម្រាកហ្នឹង ពេលយប់នោះ តើលោកស្រីសម្រាន្តផ្ទាល់នឹងដីផ្ទាល់ ឬក៏មានអ្វីសម្រាប់គេងពីលើ?

ហើយមានភ្ជួយអីដណ្តប់ដែរឬទេ?

**ឆ៖** ចាស កន្លែងហ្នឹងវាមានកន្លែងគេធ្វើរោងសម្រាប់អ្នកដែលទៅលើកទំនប់ លើកប្រឡាយហ្នឹង មិនជាឲ្យដេកនឹងដីផ្ទាល់ទេ គេមានរោងមានកន្លែងហូបចុករបស់គេដែរ គេរៀបចំស្រួលបួលដែរ។

[១០:៤៨:៤៩]

**ស៖** បើមិនដេកផ្ទាល់ដីទេ តើពលករទាំងអស់នោះដេកលើអី?

**ឆ៖** ចាស ពលករទាំងអស់នោះធ្វើរោងនៅវែងៗទៅ នៅនាំគ្នាសម្រាកតាមរោង។ ហើយបើគ្នាច្រើនអ៊ីចឹង ជួនកាលក៏ប្រជ្រៀតគ្នាដេកទៅ មុងភួយអី ក៏ខ្លះក៏មានទៅ ប៉ុន្តែមិន តាមខ្ញុំមើល មិនជាអត់អីទេ ព្រោះអង្គការប្រគល់ផ្គត់ផ្គង់ឲ្យពួកលើកទំនប់ លើកប្រឡាយ មិនឲ្យខ្វះខាតតាំងពីភួយតាំងពីកន្លែងហូបចុក តាំងពីកន្លែងរស់នៅ មិនឲ្យបងប្អូននៅផ្ទាល់នឹងដីទេ។

**ស៖** តើមានគ្រែដែរឬទេ នៅកន្លែងសម្រាកហ្នឹង? ឬក៏ពលករទាំងអស់ហ្នឹង ដេកនឹងផ្ទាល់ដីតែម្តង?

**ឆ៖** ចាស ខ្ញុំបានឆ្លើយហើយថា គេធ្វើរោងវែងៗដាក់រនាបឫស្សីទៅ រនាបឈើទៅធ្វើវែងៗដេកជាមួយគ្នាចម្រុះគ្នាអ៊ីចឹងទៅ ដេកវែងៗ រោងរាប់រយទៅ គេធ្វើប្រក់តាមជាក់ស្តែង គឺប្រក់តង់ ប្រក់កៅស៊ូ ឬក៏ធាងដូងប្រក់ទៅជាម្ជប់សម្រាប់ឲ្យបងប្អូននៅ មិនមានគ្រែ ពេលនោះវាគ្មានគ្រែទេ មានតែរនាបឫស្សី មានតែក្តារ មានតែកូនឈើតូចៗ មិនមានអាគ្រែដូចយើងសម័យក្រោយនេះទេ។ ប៉ុន្តែបងប្អូនមិនបានដេកនឹងដីផ្ទាល់ទេ ដេកនឹងគ្រែ -- ដេកនឹងឈើ យើងធ្វើរោងវែងៗទៅគាត់ដេកទៅ ប្រក់តង់ ប្រក់ស្លឹកដូង ប្រក់ស្បូវទៅ។ ពេលម្ជប់ថ្ងៃទៅ យើងមកជ្រក ពេលណាសម្រាកយើងមកជ្រកនៅកន្លែងម្ជប់ហ្នឹង។ ហើយខ្ញុំបាននិយាយពីរបីដងហើយ ជម្រាបលោកប្រធាន។

[១០:៥១:១៣]

**ស៖** លោកស្រីក៏បាននិយាយផងដែរថា ហូបចុកហ្នឹងក៏សមរម្យផងដែរ។ តើលោកស្រីអាចជម្រាបជូនតុលាការបានដែរឬទេ ថាគេឲ្យពលករហូបចុកប៉ុន្មានដងក្នុង១ថ្ងៃ? តើរបបហូបចុកនោះបរិមាណនោះយ៉ាងម៉េចដែរ?

**ឆ៖** ចាស របបហូបចុកនោះ ម្ង៉ៃពីរដង ប៉ុន្តែហូបបបរខ្លះទៅ ជួនកាលក៏ហូបបាយរហូត ជួនកាលក៏ហូបបបរ តាមការជាក់ស្តែង។

**ស៖** តើកម្មករត្រូវការផឹកទឹកអី ទៅផឹកទឹកនៅកន្លែងណាដែរ នៅទំនប់១មករាហ្នឹង?

**ផ៖** ចាស កម្មករផឹកទឹក ត្រូវការផឹកទឹកៗនៅអូរប្រឡាយហ្នឹងឯង ព្រោះពីដើមមាននេះអី មានទឹកអីទេ មានតែទឹកអណ្តូង និងទឹកអូរប្រឡាយហ្នឹងទៅ។ ងូតក៏ងូតហ្នឹង ផឹកក៏ផឹកហ្នឹងទៅព្រោះវាហូរចុះទៅក្រោមទៅ យើងដងទឹកលើមក យកមកដាំបាយទៅ ផឹកទៅ។

**ស៖** តើកម្មករត្រូវការ -- ត្រូវទៅណាដែរនៅពេលដែលចង់ទៅបត់ជើងអីនោះ តើមានបង្គន់ដែរឬទេ?

**ផ៖** ចាស ពេលនោះគ្មានទេ មានជុះ -- បត់ជើងតាមព្រៃតាមផ្សៃ យើងអត់មានធ្វើបង្គន់អី ព្រោះនៅក្នុងព្រៃ។

[១០:៥៣:៤១]

**ស៖** តើមានរុយច្រើនដែរឬទេនៅការដ្ឋាន?

**ផ៖** ចាស មានៗដែរ តែវាមិនច្រើនប៉ុន្មានទេ មានដូចតែយើងវា ពេលយើងអនាម័យស្អាតទៅក៏មិនសូវមាន បើមិនអនាម័យមិនស្អាត ក៏វារោមអ៊ីចឹងដដែល។

**ស៖** លោកស្រី ខ្ញុំចង់អានកំណត់ហេតុស្តាប់ចម្លើយរបស់លោកស្រីដែលលោកស្រីឆ្លើយនៅចំពោះមុខចៅក្រមឯកសារ -- ចំពោះចៅក្រមស៊ើបអង្កេត ERN ជាភាសាខ្មែរគឺ 00340563, ERN ជាភាសាអង់គ្លេស 00346150, ERN ជាភាសាបារាំង 00367721 ដល់22 គឺឯកសារ E3/35។ បាទ កូនរបស់លោកស្រីបានឆ្លើយដូចតទៅនេះ ដែលគាត់និយាយដូចតទៅនេះ ខ្ញុំសូមដកស្រង់៖ "ខ្ញុំបានចុះតាមរោងវែងៗរបស់កងចល័ត ប៉ុន្តែមិនដែលឃើញនិងមិនដែលឮថា មានការចាប់មនុស្សយកទៅសម្លាប់ទេ។ ប៉ុន្តែមានការត្អូញត្អែរអំពីការខ្វះខាតម្ហូបអាហារ។ គណៈកម្មាធិការឲ្យរៀបចំមានក្រុមចុងភៅ ហើយនិងអ្នករកម្ហូប។ បាទ ជាក់ស្តែង គឺមានការខ្វះខាតមែន ខ្ញុំឃើញអ្នកជំងឺនៅតាមរោងនីមួយៗ នៅពេលដែលឆ្លើយទៅនឹងសំណួរ គេឆ្លើយថា មិនមានថ្នាំលេបទេ។ ហេតុការណ៍នោះ ខ្ញុំបានប្រាប់ទៅឪពុករបស់ខ្ញុំ ហើយគាត់ក៏មានបញ្ជាការនៅតាមតំបន់ ឲ្យពេទ្យទៅតំបន់នីមួយៗ ចុះពិនិត្យ និងជួយព្យាបាលអ្នកជំងឺនៅតាមរោងនីមួយៗ ប៉ុន្តែពេទ្យខាងតំបន់ឆ្លើយតបថា ខ្វះថ្នាំពេទ្យ។ នៅពេលលើកទំនប់នោះ ខ្ញុំដឹងមានអ្នកស្លាប់ដោយជំងឺ បណ្តាលមកពីខ្វះថ្នាំពេទ្យ។" បាទសូមបញ្ចប់ការដកស្រង់។ លោកស្រីសាក្សី លោកស្រីបានទៅទំនប់១មករា ប្តីរបស់លោកស្រី ហើយនិងកូនប្រុសលោកស្រីក៏ទៅដែរ តើលោកស្រីមានដឹងទេថា មានខ្វះម្ហូបអាហារ ហើយនិងថ្នាំនៅលើការដ្ឋានហ្នឹង? លោកស្រីមានដឹងទេ?

[១០:៥៦:៤០]

**ឆ៖** ចាស កន្លែងខ្លះខ្ញុំដឹង ព្រោះយូរៗខ្ញុំទៅម្តង អាចមើលវាមិនសព្វដែរ។ កន្លែងខ្លះក៏ពេលអង្គការបានបញ្ជូនទៅ ម្ហូបអាហារថ្នាំពេទ្យទៅ ក៏គេជូនកាលខ្ញុំទៅ ក៏ឃើញថាវាសមរម្យ។ ប៉ុន្តែយូរៗខ្ញុំទៅម្តង ការខ្វះខាតខ្ញុំក៏មិនបានដឹងច្បាស់ទេ។

**ស៖** តើលោកស្រីដឹងដែរឬទេថា អ្នកមកពីភូមិភាគ ឬក៏ពីតំបន់ ឬពីមជ្ឈិមមានលទ្ធភាពផ្តល់ថ្នាំអីទៅការដ្ឋានដែរឬទេ? ខ្ញុំចង់សំដៅទៅលើថ្នាំ ក្រៅពីថ្នាំបុរាណ មិនមែនថ្នាំអាចម៍ទន្សាយហ្នឹងទេ គ្រាប់ពណ៌ខ្មៅនោះទេ។ តើលោកស្រីមានដឹងថា មានផ្តល់ថ្នាំដែលខ្ញុំនិយាយថា មិនមែនថ្នាំអាចម៍ទន្សាយហ្នឹងទៅលើ -- ទៅទំនប់១មករាហ្នឹងដែរឬទេ?

**ឆ៖** ចាស កន្លែងហ្នឹង ខ្ញុំចាំមិនបានទេ។ ខ្ញុំចាំមិនបាន ព្រោះបានថាចាំមិនបាន មកពេលខ្លះ ខ្ញុំអត់បានដឹងថា បញ្ជូនទៅឬយ៉ាងម៉េច ក៏ខ្ញុំមិនដឹងដែរ។

**ស៖** បាទ ឥឡូវនេះ ខ្ញុំសូមចូលនិយាយពីមនុស្សម្នាក់ទៀត ដែលធ្វើការឲ្យប្តីលោកស្រី។ ខ្ញុំមិនឲ្យឈ្មោះគាត់ទេ ពីព្រោះថាសាក្សីគាត់នឹងប្រហែលជាមកផ្តល់សក្ខីកម្មនៅទីនេះ នៅក្នុងសំណុំរឿងយើងនេះ គឺសាក្សី 2-TCW-896 គាត់បានអះអាងថា គាត់ជាក្មួយ ហើយនិងតែកុងឡានរបស់ប្តីលោកស្រី។ ហើយគាត់ក៏បាននិយាយផងដែរថា កែ ពក ហ្នឹងជាប្អូនពៅរបស់ឪពុកគាត់។

**លោក ខេល លីសាក់៖**

លោកប្រធាន ខ្ញុំសូមអនុញ្ញាតដូចអង្កាល់ឯកសារមុនអ៊ីចឹង គឺថាសូមប្រគល់ទៅឲ្យគាត់ ទៅអ្នកជំនួយការ ធី.ភី.អូ ហើយដើម្បីចង់ឲ្យដឹងថា តើគាត់អាចនៃកំណត់អត្តសញ្ញាណឯកសារហ្នឹងបានឬអត់ គឺឯកសារ E3/5264 លោកប្រធាន។

[១០:៥៩:៤១]

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត!

**សួរដោយលោក ខេល លីសាក់៖**

**ស៖** លោកស្រីសាក្សី ខ្ញុំចង់ឲ្យមើលឈ្មោះ លោកស្រីមើលឈ្មោះហ្នឹងឲ្យគេអានឈ្មោះហ្នឹងជូនលោក រួចហើយសូមលោកស្រីកុំអានឈ្មោះហ្នឹងឲ្យគេឮ។ តើលោកស្រីស្គាល់បុគ្គលរូបហ្នឹងដែរឬទេ ដែលបាននិយាយថា គាត់ក្មួយរបស់លោកស្រី ក្មួយរបស់ប្តីលោកស្រី ហើយគាត់ក៏បាននិយាយផងដែរ

ថា គាត់ហ្នឹងជាអ្នកបើកបរឲ្យប្ដីលោកស្រីផងដែរ?

**លោកស្រី ស៊ូ សឿន៖**

**ឆ៖** ខ្ញុំមិនចាំដែរ ប៉ុន្ដែដឹងតែឈ្មោះហ្នឹង ប៉ុន្ដែថាធ្វើការនៅជាមួយគ្នាដឹង តែត្រង់ការដឹងថា បើកឡានបើកអីចឹងដឹង។ ដឹងថាដឹងត្រូវជាសាច់ជាឈាមអីចឹង បានយកមកបើកឡាន។ ខ្ញុំដឹងតែប៉ុណ្ណឹងទេ។

[១១:០១:១៨]

**ស៖** ខ្ញុំសូមដកស្រង់កំណត់ហេតុស្ដាប់ចម្លើយគាត់ហ្នឹងម្ដងទៀត គឺចម្លើយរបស់ក្មួយរបស់លោកស្រីហ្នឹង គឺឯកសារ E3/5264 ជាភាសាខ្មែរគឺ 00271382ដល់83, អង់គ្លេស 00283344, ជាភាសាបារាំង 00333976ដល់77។ សាក្សីរូបនេះបានឆ្លើយថា គាត់ជូនប្ដីរបស់លោកស្រីទៅទំនប់១មករា ហើយនិងគាត់ប្រើពាក្យថា "ទៅជាទៀងទាត់ស្ទើរតែរាល់ថ្ងៃ"។ គាត់បានរៀបរាប់ដូចតទៅនេះអំពីអ្វីដែលគាត់បានឃើញនៅលើការដ្ឋាននោះ៖ "ពេលហ្នឹងមានមនុស្សប្រហែលជារាប់ម៉ឺននាក់កំពុងតែធ្វើការ។ ពួកគេធ្វើការយ៉ាងវេទនា ពិសេសស្រីៗ នៅពេលមានរដូវគ្មានទឹកសម្អាតខ្លួនទេ។ អ្នកខ្លះមានរុយរោមគូទ។ នៅលើការដ្ឋានមានរុយច្រើនណាស់ ដូចជាឃ្មុំយ៉ាងអីចឹង។" លោកស្រីសាក្សី តើលោកស្រីអាចនឹកឃើញទេ អំពីស្ថានភាពនៃទំនប់១មករាហ្នឹង តើលោកស្រីមានបានកត់សម្គាល់ពីលក្ខខណ្ឌការងារវេទនារបស់ស្ត្រី ស្រីៗដែលធ្វើការនៅទីនោះដែរឬទេ? ហើយតើលោកស្រីធ្លាប់និយាយរឿងនេះប្រាប់ប្ដីលោកស្រីដែរឬទេ?

**ឆ៖** ចាស រឿងហ្នឹងក៏ដូចថាគ្នាវាច្រើន ហើយខ្ញុំដើរវាមិនសព្វដែរ។ កន្លែងខ្លះគេអនាម័យ គេស្អាតរបស់គេ មិនមែនអត់ទឹកទេ គឺថាទឹកអូរ ទំនប់ប៉ុនណាណី ថាអត់ទឹកម៉េច។ ទឹក -- ហើយអនាម័យទៅ បើយើងមិនអនាម័យ វារុយរោមមែន។ បើគេអនាម័យកន្លែងខ្លះ គេស្អាត ហើយមិនមែនតែមួយកន្លែងណា មនុស្សរាប់ម៉ឺនរាប់សែននាក់។ ដូច្នេះខ្ញុំម៉េចដើរទៅស្គាល់អស់ ទៅតែម្ដុំៗអីចឹងទៅពិនិត្យម្ដុំៗ។ ខ្ញុំក្ដាប់មិនបានដែរ។

[១១:០៤:១២]

**ប្រធានអង្គជំនុំ៖**

សហព្រះរាជអាជ្ញារងផ្អាកបន្តិចសិន។ សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍!

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

បាទ ខ្ញុំសូមការបំភ្លឺអំពីសំណាក់សហព្រះរាជអាជ្ញា។ ហាក់ដូចលោកកំពុងតែនិយាយអំពីសក្ខីកម្មរបស់បុគ្គលម្នាក់ដែលនឹងមកផ្តល់សក្ខីកម្មនៅទីនេះ។ អ៊ីចឹងយើងត្រូវផ្ទៀងផ្ទាត់។ បុគ្គលរូបនេះដូចជាស្លាប់ហើយ។ ហើយអាស្រ័យហេតុដូច្នេះហើយ បានជាឈ្មោះគាត់ហ្នឹងលែងមាននៅក្នុងបញ្ជីសាក្សីដែលត្រូវមកផ្តល់សក្ខីកម្មនេះទៀតហើយ។ អ៊ីចឹងៗ សូមឲ្យលោកជួយបំភ្លឺមើល៍ តើគាត់ហ្នឹងស្លាប់ហើយ ឬក៏យ៉ាងម៉េច ដើម្បីឲ្យស្ថានភាពនេះច្បាស់លាស់ជាងមុន? ថាព័ត៌មាននេះហាក់ដូចជាមាននៅក្នុងឯកសារ E303/3/2។ បាទ សូមអភ័យទោស គឺឯកសារ E307/3/2។

**លោក ឌេល លីសាក់៖**

លោកចៅក្រម ឡាវែន៍ ខ្ញុំប្រហែលជាមានបញ្ហាបកប្រែទេ។ លោកនិយាយអំមិញ លោកចៅក្រមនិយាយអម្បាញ់មិញនេះ ថាបុគ្គលហ្នឹងគាត់ស្លាប់ហើយ ឬក៏យ៉ាងម៉េច?

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

ខ្ញុំកត់សម្គាល់ឃើញថា បុគ្គលហ្នឹងទំនងជាស្លាប់ហើយ។ ប្រហែលជាអាស្រ័យហេតុដូច្នេះហើយបានជាមិនមានដាក់ឈ្មោះសាក្សីនេះមកផ្តល់សក្ខីកម្ម។ អ៊ីចឹងត្រូវបញ្ជាក់អំពីលក្ខខណ្ឌនៃការប្រើប្រាស់ចម្លើយរបស់គាត់។

[១១:០៦:២៩]

**លោក ឌេល លីសាក់៖**

យើងបានស្រាវជ្រាវដើម្បីឲ្យដឹងថា តើមានព័ត៌មានអីខ្លះលើបុគ្គលរូបនេះនៅក្នុងសំណុំរឿង។ អ៊ីចឹងហើយបានខ្ញុំត្រូវប្រើរហស្សនាម បើសិនជាមិនមានព័ត៌មានបញ្ជាក់ច្បាស់លាស់ថា គាត់ហ្នឹងស្លាប់ដែរឬទេ យើងអាចបន្តរបៀបនេះទៀត ដោយប្រើរហស្សនាមគាត់ដដែល មិនចាំបាច់ហៅឈ្មោះគាត់ចំៗនោះទេ។

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** លោកស្រីសាក្សី និងផ្នែកទី២ នៃឯកសារដដែលគឺ E3/5264 ជាភាសាខ្មែរ ERN 00271381, ជាភាសាអង់គ្លេស 00283442, ជាភាសាបារាំង 00333977 ដល់78។ ក្នុងរបស់លោកស្រីបានពិពណ៌នាអំពីរយៈពេលដែលគាត់ជូនប្តីលោកស្រីទៅទំនប់១មករា ស្ទើរតែរៀងរាល់ថ្ងៃ។ គាត់និយាយថា ប្តីរបស់លោកស្រីហ្នឹងទៅកន្លែងធ្វើការរបស់គាត់ដែលមានការិយាល័យលេខ៧១ ឈ្មោះ

ការិយាល័យ -- មន្ទីរ៧១ ដែលនៅក្នុងស្រុកហ្នឹង ស្ថិតនៅក្នុងឃុំតាប្រុកតាប្រាជ្ញ ស្រុកចំការលើ ខេត្តកំពង់ចាម។ ខ្ញុំមិនចាំឈ្មោះភូមិទេ។ មន្ទីរ៧១នេះ គឺជាមន្ទីរភូមិភាគ ដែលមានកម្មករធ្វើការនៅទីនោះ ហើយមានតែពីរបីនាក់ទេ ដែលធ្វើម្ហូបអាហារឲ្យ កែ ពក នោះ។ ហើយជួនកាលមានបរទេសមកផងដែរ គឺមានជប៉ុន មានអឺរ៉ុប មានអាហ្វហ្គានីស្ថាន អាហ្វ្រិកជាដើម។ គាត់ក៏បាននិយាយផងដែរថា មានចម្ងាយប្រហែលជា៦ ឬ៧គីឡូម៉ែត្រពីមន្ទីរ៧១នេះទៅទំនប់៧មករា អ៊ំ! ១មករា បាទសូមអភ័យទោស។ តើលោកស្រីសាក្សី មន្ទីររបស់លោកស្រីហ្នឹង គឺនៅ -- លោកស្រីដឹងថា មន្ទីរគាត់ហ្នឹងនៅកន្លែងណាដែរឬទេ?

[១១:០៨:៥៩]

**លោកស្រី ស៊ូ សឿន៖**

**ឆ៖** ចាស កន្លែង គេហៅ ៧១ហ្នឹង កន្លែងហ្នឹង ខ្ញុំអត់ដែលបានចូលទេ។ អត់បានចូល ហើយក៏មិនដែលបានស្គាល់កន្លែងហ្នឹងច្បាស់ ព្រោះកន្លែងហ្នឹងសម្រាប់ធ្វើការ។ ដូច្នេះរឿងខាងក្រុមគ្រួសារខាងខ្ញុំជាស្រី ខ្ញុំមិនដែលបានទៅទេ។

**ស៖** ឥឡូវយើងនៅនិយាយអំពីការិយាល័យនៅចំការលើដដែល។ តើលោកស្រីអាចជម្រាបជូនតុលាការបានដែរឬទេ តើមន្ទីរស្រុកលោកស្រីធ្វើការនៅចំការលើហ្នឹងនៅកន្លែងណាដែរ?

**ឆ៖** មន្ទីរស្រុកនៅចំការលើគឺនៅថ្នល់បែក គេហៅទួលឡូវកន្លែងហ្នឹង មានវត្តមួយនៅកន្លែងហ្នឹង។

**ស៖** ចុះមន្ទីរតំបន់ តើមន្ទីរតំបន់ស្ថិតនៅជិតមន្ទីរស្រុកមែនទេ?

**ឆ៖** ចាស មន្ទីរតំបន់មកនៅខាងថ្នល់ជាតិឯណេះ។ ឯមន្ទីរស្រុកវាផ្លូវទៅចំការលើ ទៅស្ទឹងត្រង់។ នៅឆ្ងាយពីគ្នាដែរ ប៉ុន្តែមិនឆ្ងាយប៉ុន្មានទេ ប្រហែល១គីឡូពីគ្នា ឬក៏២គីឡូទៅចុះ ប៉ុណ្ណឹងចុះ។

[១១:១១:០៦]

**ស៖** ខ្ញុំសូមអានចម្លើយមួយរបស់បុគ្គលមួយរូបដែលលោកស្រីបានបញ្ជាក់ពីមុនថា គាត់ជាសាច់ថ្លៃរបស់លោកស្រី ដែលមានឈ្មោះ ផុស គឺឯកសារ E319/19.3.86 (សូមទោស)គឺ E319/19.3.73 ERN ជាភាសាអង់គ្លេសគឺ 00841955, ជាភាសាខ្មែរ -- ជាភាសាបារាំងគឺ 00439862។ នេះជាអ្វីដែលគាត់បានឆ្លើយពាក់ព័ន្ធទៅនឹងស្រុក។ “មន្ទីររបស់ សួន នៅចម្ងាយប្រហែល៥០០ម៉ែត្រពីមន្ទីររបស់ អឿន។ គាត់រស់នៅជាមួយកូនស្រីអាយុ៥ឆ្នាំ ដែលមានឈ្មោះ នាថ

ជាមួយនឹងអ្នកយាម ហើយនិងមានអ្នកបម្រើប្រហែលជា១០នាក់។ សឿន ទទួលខុសត្រូវខាងកិច្ចការនយោបាយស្រុក ហើយខ្ញុំជាអនុរបស់គាត់ ខ្ញុំទទួលខុសត្រូវខាងផ្នែកឃោធា ហើយនិងមានសមាជិកម្នាក់ទៀតទទួលខុសត្រូវខាងសេដ្ឋកិច្ច។ អ្នកដែលជាទទួលខុសត្រូវខាងសន្តិសុខស្រុកគឺឈ្មោះ ហាប់ និង ជួន។ មន្ទីរសន្តិសុខស្រុកមានទីតាំងនៅបុសខ្នុរ។ សឿន តែងតែរៀបចំកិច្ចប្រជុំនៅផ្ទះរបស់គាត់ជាមួយឃុំដើម្បីចេញបញ្ហា និងសេចក្តីណែនាំឲ្យអនុវត្ត។ សំណួរ៖ តើ កែ ពក រស់នៅជាមួយ សឿន ដែរឬទេ? ចម្លើយ៖ អត់ទេ។ គាត់មកម្តងម្កាលតែប៉ុណ្ណោះ។ ជួនកាលគាត់មកតែពេលយប់ទេ នៅពេលដែលគាត់មកនោះ គាត់ដេកតែមួយយប់ប៉ុណ្ណោះ។" លោកស្រីសាក្សី តើចម្លើយរបស់សមាជិកគ្រួសាររបស់លោកស្រីនេះត្រឹមត្រូវដែរឬទេ? តើវារៀបរាប់អំពីរចនាសម្ព័ន្ធនៅក្នុងស្រុកចំការលើដែលជាស្រុករបស់លោកស្រីហ្នឹងដែរឬទេ?

[១១:១៣:៤៧]

**ផ៖** ចាស ការរៀបរាប់របស់ចម្លើយខ្លះមិនត្រឹមត្រូវទេ ព្រោះកន្លែងខ្លះខ្ញុំមិនបានទៅប្រជុំជាមួយប្រធានសន្តិសុខទេ។ សន្តិសុខនោះ ខ្ញុំអ្នកគ្រាន់តែថាស្គាល់កន្លែងសន្តិសុខ តែមិនបានប្រជុំជាមួយទេ មិនបាននិយាយជាមួយទេ។ ការណ៍ខ្លះក៏វាលើស ការណ៍ខ្លះក៏វាត្រឹមត្រូវ ប៉ុន្តែភាគច្រើន ច្រើនពន្លើស ដូចថា ឧទាហរណ៍ថាខ្ញុំពេលនោះបានធ្វើប្រធាននយោបាយ ប្រធានស្រុក ការពិតជាស្រមោលទេ ព្រោះពេលនោះ ខ្ញុំបានឆ្លងទន្លេហើយ ខ្ញុំមិនបានចុះជាប់មូលដ្ឋាន ឬក៏កន្លែងសន្តិសុខទេ។ សូមជម្រាបប្រធានអ៊ីចឹង។

**ស៖** ប្រហែលជាអាចមានបញ្ហាបកប្រែ ចម្លើយដែលខ្ញុំអានអម្បាញ់មិញនេះ មិនបាននិយាយថាលោកជួបជាមួយមេសន្តិសុខទេ គ្រាន់តែបញ្ជាក់ថា លោកស្រីបានចូលរួមនៅក្នុងកិច្ចប្រជុំជាមួយនឹងមេឃុំ។ អ៊ីចឹងខ្ញុំចង់ដឹងថាតើត្រឹមត្រូវដែរឬទេ ដែលលោកស្រីបានចូលរួមប្រជុំជាមួយនឹងមេឃុំ នៅស្រុកចំការលើ?

[១១:១៥:២៦]

**ផ៖** ចាស បើបានជួបលើប្រធានឃុំដូចគេថា គេរាយការណ៍ពីរឿងសហករណ៍មានការចាំបាច់ រឿងធ្វើទំនប់ ធ្វើប្រឡាយ នាំបងប្អូនធ្វើស្រែ ធ្វើចម្ការ អាហ្នឹងជួបមែនជួបជាមួយមេឃុំមែន។ ព្រោះប្រធានសង្កាត់ ឬក៏ប្រធានស្រុកយើងលើកបញ្ហាធ្វើស្រែ១ឆ្នាំបីដង ក្នុងមួយដងវាបានប៉ុន្មានតោនក្នុង១ហិកតា។ អាហ្នឹងយើងពិភាក្សាអ៊ីចឹងមែន។

**ស៖** ឥឡូវនេះខ្ញុំចង់សួរលោកស្រីអំពីសំណួរមួយចំនួន ពាក់ព័ន្ធទៅនឹងហេតុការណ៍ដែលអ្នកស្រីបានរៀបរាប់នៅក្នុងកំណត់ហេតុរបស់លោកស្រី គឺឯកសារ E3/5294 ជាភាសាខ្មែរគឺ 00348833 ទៅដល់ 34, ជាភាសាអង់គ្លេសគឺ 00360116, ជាភាសាបារាំងគឺ 00367809 ទៅដល់ 10។ គេសួរលោកស្រីអំពីទស្សនកិច្ចរបស់គណៈប្រតិភូស្ត្រីមកពីឡាវ នេះជាចម្លើយរបស់លោកស្រី៖ “គណៈប្រតិភូស្ត្រីឡាវមកទស្សនកិច្ចនៅស្រុកចំការលើ។ នៅពេលនោះលោកស្រី អៀង ធីរិទ្ធ និងខ្ញុំបាននាំគណៈប្រតិភូទៅធ្វើទស្សនកិច្ច។” សូមបញ្ចប់ការដកស្រង់។ សំណួរទី១ របស់ខ្ញុំថាតើ ទស្សនកិច្ចដែលអ្នកស្រីនិងអៀង ធីរិទ្ធ បាននាំគណៈប្រតិភូស្ត្រីមកពីឡាវហ្នឹង គឺមានបញ្ចូលទាំងទស្សនកិច្ចទៅកាន់ទំនប់១មករាដែរឬទេ?

[១១:១៧:២១]

**ឆ៖** ចាស គាត់មកទស្សនកិច្ចនៅចំការលើ ក៏ភារកិច្ចគាត់បានតែត្រឹមពិនិត្យទំនប់ប្រឡាយ ឬក៏ឧទ្ទេសនាមពីប្រតិភូមកទស្សនកិច្ចមើលបងប្អូន សហករណ៍ តើធ្វើស្រែ១ឆ្នាំបានប៉ុន្មានគោន ហើយរៀបចំប្រឡាយយ៉ាងម៉េចអីម៉េច ទំនប់ប្រឡាយ បានតែមកទស្សនកិច្ចត្រឹមចំការលើទេ។ តែទៅទស្សនកិច្ចនៅទំនប់១មករា មានគេអ្នកនាំទៅទៀត តែទៅដល់ត្រឹមណាខ្ញុំអត់ដឹងទេ ព្រោះខ្ញុំអត់បានទៅ។

**ស៖** ដើម្បីឲ្យខ្ញុំប្រាកដនោះ គឺថាតើត្រឹមត្រូវទេ ថាលោកស្រីនិង អៀង ធីរិទ្ធ ហ្នឹងគឺទៅជាមួយនឹងគណៈប្រតិភូឡាវ ទៅស្រុកចំការលើ ហើយអត់ទៅទំនប់១មករាហ្នឹងទេ តើត្រឹមត្រូវទេ?

**ឆ៖** ចាស បើទៅត្រឹមស្រុកចំការលើ ត្រឹមត្រូវហើយ ប៉ុណ្ណឹង។ បើថាទៅរហូតទំនប់១មករា ខ្ញុំអត់បានទៅទេ គាត់ក៏មិនបានទៅដែរ។

**លោក ខេល លីសាក់៖**

លោកប្រធានខ្ញុំចង់ផ្តល់ជូនសាក្សីនូវរូបថតពីរ គឺឯកសារ E3/3282 និង E3/3283។ រូបថតនេះត្រូវបានកំណត់ថាជារូបថតនៃគណៈប្រតិភូឡាវដែលបានទស្សនកិច្ច។ អ៊ីចឹងខ្ញុំចង់បង្ហាញជូន សាក្សីថាតើគាត់អាចស្គាល់កន្លែងនៅក្នុងរូបថត ហើយនិងស្គាល់មនុស្សនៅក្នុងរូបថតហ្នឹងដែរឬទេ?

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត!

[១១:២០:០០]

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** លោកស្រីសាក្សី ខ្ញុំបង្ហាញរូបថតពីរជូនលោកស្រីគឺឯកសារ E3/3282 និង E3/3283។ សូមលោកស្រីពិនិត្យមើលរូបថតទាំងពីរហ្នឹង តើលោកស្រីស្គាល់ទីតាំងដែលថតរូបហ្នឹងទេ? ហើយលោកស្រីមានស្គាល់អ្នកណាម្នាក់នៅក្នុងរូបថតទាំងអស់ហ្នឹងទេ?

**លោកស្រី ស៊ូ សឿន៖**

**ឆ៖** ចាស ទីតាំងនេះគឺទីតាំងទំនប់មុខ – គេហៅទួលឡូវ។ ទួលឡូវហ្នឹងប្រឡាយមកពីភូមិស្វាយទាបទៅបឹងល្វា គេហៅភូមិល្វាៗលើ។ ហើយក្នុងរូបថតនេះ ខ្ញុំមិនស្គាល់ទេ ព្រោះម៉្យាងក៏វាៗមើលមិនច្បាស់ ហើយក៏អត់មានទាន់ -- អត់ស្គាល់រូបនរណាមួយទេ តែរូបខ្លួនឯងក៏មិនស្គាល់ផងសូម។

**ស៖** ទីតាំងដែលលោកស្រីរៀបរាប់ហ្នឹង តើលោកស្រីអាចជម្រាបបានទេថា ទីតាំងហ្នឹងស្ថិតនៅក្នុងស្រុកណាដែរ?

**ឆ៖** ចាស នៅស្រុកចំការលើ កន្លែងលើកទំនប់ហ្នឹងគេហៅ "ទួលឡូវ" ហើយផ្លូវទៅស្វាយ -- ស្ពឺៗហើយប្រឡាយហ្នឹងពីស្ពឺ -- ពីន៉ែទួលឡូវទៅស្ពឺ មួយទៅស្ពឺ មួយខាងឆ្វេងដៃទៅហៅភូមិល្វាៗលើ។ ខ្ញុំស្គាល់ច្បាស់ត្រង់ហ្នឹង។

**ស៖** សូមលោកស្រីពិនិត្យមើលរូបថតទី២ លោកស្រីមើលឲ្យជិតទៅមើល លោកស្រីឃើញរូបលោកស្រីទេ លោកស្រីមានស្គាល់រូបលោកស្រីនៅក្នុងរូបថតហ្នឹងទេ?

**ឆ៖** ខ្ញុំអត់ស្គាល់ទេ។ មើលមិនៗច្បាស់ ហើយក៏មិនស្គាល់ អត់មានស្គាល់ពីណាមួយទេ ទាំងអស់គ្នានេះ អត់ស្គាល់ទេ។ អាសន្លឹកទី២ សន្លឹកទី១ រឹតតែមិនស្គាល់ទៀត មើលមិនច្បាស់។

[១១:២២:៥១]

**ស៖** នៅក្នុងកិច្ចសម្ភាសន៍របស់លោកស្រីគឺ E3/5294, ជាភាសាខ្មែរគឺ 00348834, ជាភាសាអង់គ្លេស 00360117, ជាភាសាបារាំងគឺ 00367810។ គេសួរលោកស្រីថា "តើលោកស្រីចាំថាមានមេដឹកនាំជាន់ខ្ពស់ណាផ្សេងទៀតក្រៅពី អៀង ធីរិទ្ធ ទៅទស្សនកិច្ចដែរឬទេ?" ពេលនោះលោកស្រីបានឆ្លើយដូចតទៅ៖ "ខ្ញុំចាំថាមាន នួន ជា មកទស្សនកិច្ចទំនប់១មករា" សូមបញ្ចប់ការដកស្រង់។ តើលោកស្រីចាំអ្វីខ្លះពីទស្សនកិច្ចរបស់ នួន ជា ទៅទំនប់១មករានេះ?

**ឆ៖** ចាស ខ្ញុំអត់បានចាំទេ កន្លែងហ្នឹងដូចថាវាភ្លេចអស់ហើយ។

**សៈ** តើលោកស្រីចាំទេថា នួន ជា គាត់មកតែម្នាក់ឯង ឬក៏មកជាក្រុម?

**ឆៈ** ចាស ពេលនោះ ខ្ញុំអត់ៗដឹងថាគាត់អញ្ជើញទៅហ្នឹងកន្លែងហ្នឹងផង មិនដឹងជាទៅប៉ុន្មាននាក់ ខ្ញុំអត់ដឹង។

**សៈ** នៅពេលដែល នួន ជា មកទស្សនកិច្ចទំនប់១មករា លោកស្រីមានវត្តមាននៅទីនោះទេ ឬក៏លោកស្រីឮពីគេទេ?

[១១:២៤:៥៣]

**ឆៈ** ចាស កន្លែងគាត់ទៅទស្សនកិច្ច ខ្ញុំអត់បានទៅទេ ខ្ញុំនៅជាប់ការងារ គេហៅ -- សំខាន់រឿងជាប់កូន នៅកូនខ្ចី អត់បានទៅទស្សនកិច្ចទេ។ តាមខ្ញុំចាំគឺអ៊ីចឹង អត់បានទៅ។

**សៈ** តើអ្នកណាជាអ្នកប្រាប់លោកស្រី? លោកស្រីដឹងដោយរបៀបណាថា នួន ជា ទៅទំនប់១មករា?

**ឆៈ** បានថា តាមខ្ញុំដឹង ៗតាមរបៀបណា គឺប្រធានសង្កាត់ គេអ្នកនាំកម្លាំងទៅ ហើយដល់គេបកមកវិញ គេប្រាប់ថា តានួន ជា ទៅមើលទំនប់១មករា។ ដឹងតែប៉ុណ្ណឹង។

**សៈ** តើលោកស្រីដឹងទេថា នៅពេលដែល នួន ជា មកកំពង់ចាម និងមកទំនប់១មករាហ្នឹងគាត់មានបានជាមួយប្ដីលោកស្រីទេ?

**ឆៈ** ចាស កន្លែងហ្នឹងខ្ញុំអត់ដឹងទេ ព្រោះខ្ញុំនៅចំការលើ ត្រង់គាត់មកធ្វើការនៅកំពង់ចាម ហើយគាត់ទៅទំនប់១មករា ខ្ញុំមិនបានដឹងទេ។ ហ្នឹងខ្ញុំនិយាយតាមត្រង់។

**សៈ** ចុះ ប៉ុល ពត តើ ប៉ុល ពត គាត់មានមកទស្សនកិច្ចនៅទំនប់១មករាទេ?

[១១:២៦:៤៩]

**ឆៈ** ចាស ត្រង់ តាប៉ុល ពត ខ្ញុំរឹតតែមិនដឹងទៀតហើយ។ តែធ្វើប្រធានហើយ ខ្ញុំមិនដឹងដែរ។ បើដឹងកិច្ចការអី ត្រូវដឹងតាមសង្កាត់ គេអ្នកនាំទៅនាំមក។ បើសង្កាត់គេមិននិយាយប្រាប់ ខ្ញុំក៏មិនដឹង។

**ឆៈ** នៅក្នុងកំណត់ហេតុរបស់លោកស្រី លោកស្រីបាននិយាយថា នៅពេលដែលមានពិធីម្ដងៗនៅទំនប់១មករាហ្នឹង គេអញ្ជើញឲ្យលោកស្រីមកចូលរួមដែរ។ ហើយលោកស្រី ក៏បាននិយាយអំពីទស្សនកិច្ចរបស់គណៈប្រតិភូចិន ដែលដឹកនាំដោយ ឆឹង យ៉ឹងគួយ ដែលមកពិនិត្យមើលទំនប់១មករា នៅពេលគេធ្វើពិធីបើកការដ្ឋាន។ តើនៅពេលពិធីសម្ពោធបើកការដ្ឋានដែលចូលរួមដោយ ឆឹង យ៉ឹងគួយ ដែលដឹកនាំគណៈប្រតិភូចិនមកហ្នឹង លោកស្រីមានបានចូលរួមទេ នៅពេលនោះ?

**ឆ៖** ចាស ពេលនោះខ្ញុំទៅដែរ។ មានពិធីៗធំអ៊ីចឹងខ្ញុំទៅដែរ ទៅជាមួយនឹងគេនឹងឯងទៅជាមួយកម្មាភិបាលនារីៗហ្នឹង នាំបងប្អូនទៅមើល ហើយទៅទទួលភ្ញៀវចិន។ ហ្នឹងខ្ញុំបានទៅ។

[១១:២៨:៣១]

**ស៖** ខ្ញុំចង់អានរបាយការណ៍មួយ ដែលត្រូវបានផ្សព្វផ្សាយនៅក្នុងវិទ្យុកម្ពុជាប្រជាធិបតេយ្យនៅថ្ងៃទី០៧ ធ្នូ ឆ្នាំ១៩៧៧ ថាគឺជាឯកសារ E3/1339, អង់គ្លេសគឺនៅទំព័រ ERN 00168335 ទៅដល់ 36 គឺមានតែជាភាសាអង់គ្លេសទេ មិនមានជាខ្មែរ ជាបារាំងទេ។ របាយការណ៍នេះមានចំណងជើងថា "ឆឹង យឹងគួយ ធ្វើទស្សនកិច្ចនៅភូមិភាគកណ្ដាល ថ្ងៃទី០៦ ធ្នូ ហើយនិងថ្ងៃបន្ទាប់ទៀត គឺថ្ងៃទី០៧ ធ្នូ"។ ខ្ញុំសូមដកស្រង់៖ "នៅព្រឹកថ្ងៃទី០៦ ធ្នូ សមមិត្ត ឆឹង យឹងគួយ សមាជិកមន្ទីរនយោបាយនៃបក្ស -- នៃគណៈមជ្ឈិមបក្សកុម្មុយនីស្តចិន និងភ្ញៀវចិនដទៃទៀតបានទស្សនកិច្ចចម្ការកប្បាស និងស្រែនៅក្នុងវាលស្ពឺ ដោយមានអមដំណើរដោយសមមិត្ត ប៉ុល ពត, វន វេត, ជួន ជឿន ដែលជារដ្ឋមន្ត្រីក្រសួងសុខាភិបាល ផុក -- ពក លេខាគណៈតំបន់ -- គណៈភូមិភាគកណ្ដាលនៃបក្សកុម្មុយនីស្តកម្ពុជា និង អាន ជាអនុលេខា -- និង អន ជាអនុលេខា។" ហើយបន្តទៅទៀតគឺ៖ "នៅពេលរសៀល ភ្ញៀវចិនដែលជាបងប្អូនបានទស្សនកិច្ចវាលស្រែនៅតំបន់បារាយណ៍ និងទំនប់១មករា។ កម្មាភិបាល និងប្រជាជនរាប់ពាន់នាក់ ដែលពោរពេញទៅដោយភាតរភាពបដិវត្តន៍ជ្រាលជ្រៅ ក៏បានចាប់ដៃស្វាគមន៍ភ្ញៀវយ៉ាងកក់ក្ដៅ។" សូមបញ្ចប់ការដកស្រង់។ តើលោកស្រីនៅចងចាំទេ ថានៅពេលសម្ពោធទំនប់១មករានោះគឺថាមាន ឆឹង យឹងគួយ បានមកចូលរួម ហើយនៅពេលនោះក៏មាន ប៉ុល ពត, វន វេត និងប្ដីរបស់លោកស្រី ហើយនិងអនុរបស់គាត់គឺ តាអាន ហ្នឹងក៏ជាអ្នកអមដំណើរ ឆឹង យឹងគួយ?

[១១:៣១:០៦]

**ឆ៖** ត្រង់កន្លែងហ្នឹងខ្ញុំដូចជាភ្លេចដែរ ដូចមិនចាំ។ បើកន្លែងសម្ពោធហ្នឹងគឺបិទ ដល់ពេលពិធីបើកខ្ញុំបានទៅ ដល់ពិធីបិទហ្នឹង ទទួលខ្ញុំឈឺអត់បានទៅ ក៏អត់ដឹងរឿងថា អ៊ំៗទាំងអស់ហ្នឹង មកប៉ុន្មាននាក់ ខ្ញុំមិនដឹងទេ។ បើដឹង ៗតាមកូនប្រាប់ ឬក៏ប្រធានសង្កាត់ដែលគេទៅជំនួសខ្ញុំហ្នឹង។ ដល់ត្រង់ខ្ញុំអត់បានទៅទេ ព្រោះឈឺ ឈឺជិតងាប់ជិតរស់ទៅ មិនបានទៅនឹងគេទេ។ ចាស ខ្ញុំសូមឆ្លើយប៉ុណ្ណឹង។

**ស៖** ខ្ញុំចង់ឲ្យប្រាកដថាខ្ញុំយល់លោកស្រីត្រឹមត្រូវ។ អ៊ីចឹងគឺលោកស្រីចង់មានន័យថា ពិធីសម្ពោធដែលលោកស្រីបានចូលរួមហ្នឹង គឺជាពិធីបើកការដ្ឋាន មិនមែនជាពិធីសម្ពោធបិទការដ្ឋានមែនទេ ដែលថានៅឆ្នាំ១៩៧៧ហ្នឹង?

**ឆ៖** ខ្ញុំចង់បញ្ជាក់អ៊ីចេះថា ខ្ញុំបានទៅត្រឹមបើក ត្រឹមបើកហ្នឹងខ្ញុំបានទៅ។ ដល់ពេលបិទហ្នឹងភៀវចិនមក ខ្ញុំអត់បានទៅទេ បើតាមខ្ញុំចាំគឺអ៊ីចឹង។ អត់បានចាំទេ -- អ៎! អត់បានទៅជាមួយនឹងគេទេ ព្រោះខ្ញុំភារៈដែលថា ឈឺ ដើរទៅវាមិនរួច ដូច្នេះអត់បានទៅទេ។ សូមជម្រាបប៉ុណ្ណឹង។

**លោក ឌេល លីសាក់៖**

លោកប្រធាន ខ្ញុំចូលទៅប្រធានបទថ្មីហើយ អ៊ីចឹងប្រហែលដល់ពេលសមស្របដែលត្រូវសម្រាកហើយ លោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ឥឡូវនេះដល់ពេលសម្រាកថ្ងៃត្រង់ហើយ អង្គជំនុំជម្រះសម្រាកចាប់ពីពេលនេះតទៅរហូតដល់ម៉ោងមួយកន្លះរសៀលនេះ សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី និងអ្នកជំនាញ ដល់សាក្សីរូបនេះ នៅក្នុងអំឡុងសម្រាកថ្ងៃត្រង់ និងឲ្យអញ្ជើញគាត់ រួមទាំងបុគ្គលិកអង្គការធី.ភី.អូ មកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះ នៅវេលាម៉ោងមួយកន្លះរសៀលនេះ។

បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនលោក ខៀវ សំផន ទៅកាន់បន្ទប់រង់ចាំខាងក្រោមសាលសវនាការនេះ និងបង្គាប់ឲ្យនាំខ្លួនគាត់ត្រឡប់ចូលរួមសវនាការនៅក្នុងបន្ទប់សវនាការនេះ ឲ្យបានមុនម៉ោងមួយកន្លះរសៀលនេះ។

សម្រាកចុះ!

*(សវនាការសម្រាកពីម៉ោង ១១:៣៣ នាទី ដល់ម៉ោង ១៣:៣១ នាទី)*

[១៣:៣១:៣៣]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ហើយនិងផ្តល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញា ដើម្បីបន្តការតាំងសំណួរដេញដោលចំពោះសាក្សី។

សូមផ្អាកបន្តិចសិនលោកតំណាងសហព្រះរាជអាជ្ញា!

សូមអញ្ជើញលោក វ៉ិចទ័រ កូប៉េ!

**លោក វិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ សូមជម្រាបសួរលោក លោកស្រីចៅក្រម យើងមានសំណើសុំមួយ យើងចង់ធ្វើសារណារដោយផ្ទាល់មាត់នៅចុងបញ្ចប់នៃពេលរសៀលនេះ ឬក៏នៅស្អែកព្រឹក មុនពេលដែលយើងបន្តសាកសួរសាក្សីនេះ ឬក៏នៅចុងបញ្ចប់នៃសក្ខីកម្មនេះ ទាក់ទងទៅនឹងការបង្ហាញឯកសារដែលបង្ហាញមុខយើងនៅបីបួនម៉ោងមុននេះ ហើយក៏វាទាក់ទងផងដែរ ទៅនឹងសវនាការរបស់អង្គជំនុំជម្រះតុលាការកំពូល។ ដូច្នេះគឺថាខ្ញុំសូមអនុញ្ញាតទុកឲ្យអង្គជំនុំជម្រះធ្វើការសម្រេច ថាតើពេលណាដែលជាពេលសមស្របសម្រាប់យើងខ្ញុំឡើងថ្លែងនូវសារណារដោយផ្ទាល់មាត់នេះ។ សូមអរគុណ។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

ខ្ញុំសូមសួរសំណួរដើម្បីបញ្ជាក់បន្តិច តើមានអ្វីពាក់ព័ន្ធនឹងសាក្សីនេះទេ?

*(ចៅក្រមពិភាក្សាគ្នា)*

[១៣:៣៣:២៨]

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះនឹងអនុញ្ញាតឲ្យលោកធ្វើនៅចុងម៉ោងរសៀលនេះ។

សូមអញ្ជើញសហព្រះរាជអាជ្ញារងអន្តរជាតិ!

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។ ខ្ញុំសូមជម្រាបអំពីការដំណើរការរបស់យើង យើងនឹងបញ្ចប់នៅម៉ោងពីរ ហើយដើមបណ្ដឹងរដ្ឋប្បវេណីប្រហែលជាចំណាយពេល៤០នាទី ហើយគាត់ប្រាប់ថា អាចត្រូវការ១៥នាទីលើសពីហ្នឹង ប៉ុន្តែយ៉ាងក៏ដោយយើងមានបញ្ហាដោយសារតែយើងត្រូវបញ្ចប់នៅថ្ងៃស្អែក។ យ៉ាងណាក៏ដោយខ្ញុំនឹងព្យាយាមគោរពទៅតាមពេលវេលាឲ្យបានសមរម្យ។

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** លោកស្រីសាក្សី ខ្ញុំមានចំណុចបន្ទាប់ដើម្បីសួរលោកស្រីទាក់ទងទៅនឹងទំនប់១មករា។ លោកស្រីបានជម្រាបយើងខ្ញុំថា វាមានពេលខ្លះ លោកស្រីស្នាក់នៅពេលយប់នៅទំនប់១មករា។ ដូច្នេះ ខ្ញុំចង់សួរលោកស្រីថា នៅពេលដែលលោកស្រីស្នាក់នៅពេលយប់នោះ តើប្ដីលោកស្រីស្នាក់នៅជាមួយលោកស្រីដែរឬទេ? ប្រសិនបើប្ដីរបស់លោកស្រីមកស្នាក់នៅជាមួយលោកស្រីទេ តើនៅពេលដែលយប់ហ្នឹង តើប្ដីរបស់លោកស្រីស្នាក់នៅកន្លែងណាដែរ?

[១៣:៣៥:០៩]

**លោកស្រី ស៊ូ សឿន៖**

**ឆ៖** ចាស ពេលនោះ គ្រួសារខ្ញុំមិនបានមកស្នាក់នៅជាមួយទេ ព្រោះគាត់មានផ្ទះ កន្លែងគាត់ផ្សេង ខ្ញុំនៅផ្សេង នៅជាមួយសហករណ៍ផ្សេង ចាស។

**ស៖** ប្រធានបទចុងក្រោយដែលខ្ញុំនឹងពិភាក្សាជាមួយលោកស្រីនៅថ្ងៃនេះ គឺទាក់ទងទៅនឹងការបោសសម្អាតនៅភូមិភាគឧត្តរចាស់ ឬក៏ភូមិភាគកណ្ដាល។ កន្លងមកនេះ យើងបានពិភាក្សាអំពីកម្មាភិបាលម្នាក់ដែលធ្វើការងារជាមួយស្វាមីរបស់លោកស្រីនៅគណៈភូមិភាគកណ្ដាល គឺឈ្មោះ តុល ដែលជាប្រធានតំបន់៤២ ហើយគាត់គឺជាអ្នកតែងតាំងលោកស្រីឲ្យធ្វើជាគណៈកម្មការស្រុកចំការលើ។ តើលោកស្រីអាចជម្រាបបានទេ ថាតើ តុល ហ្នឹងតើមានអីកើតឡើងចំពោះ តុល នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យនោះ?

**ឆ៖** ចាស ពេលនោះ ខ្ញុំអត់ដឹងទេ ជម្រាបត្រង់ ថាអត់ដឹងទេ មិនដឹងថាគេម៉េច ខ្ញុំអត់ដឹងដែរ។

**ស៖** តើ តុល ត្រូវបានគេចាប់ខ្លួន ឬមួយក៏ តុល បាត់ខ្លួននៅក្នុងឆ្នាំ៧៧នោះ?

**ឆ៖** ចាស ពេលបាត់ខ្លួន ពេលគេចាប់ ខ្ញុំដូចជាមិនដឹង ថាព្រោះបានថា មិនដឹងវាត្រង់ហ្នឹងដូចវាភ្លេច មិនដឹងម៉េចទេ វាភ្លេចភ្លាំងរបស់ខ្ញុំបាត់ទៅ មិនដឹងថាគេចាប់ឆ្នាំណា ក៏មិនដឹង ហើយគេធ្វើម៉េចទៀត ក៏មិនដឹង។ ខ្ញុំមានតែប៉ុណ្ណឹង។

**ស៖** ដើម្បីជាកំណត់ត្រា លោកប្រធាន ឯកសារ E3/2956 គឺជាបញ្ជីឈ្មោះអ្នកទោសមកពីស-២១ ដែលមានចំណងជើងថា បញ្ជីឈ្មោះមនុស្សមកពីភូមិភាគឧត្តរ នៅក្នុងលេខ២២គឺ ចាន់ ម៉ុលហៅ តុល គឺជាប្រធានតំបន់៤២ ចូលមកនៅថ្ងៃទី -- នៅក្នុងឆ្នាំ៧៧។ លោកស្រីកម្មាភិបាលដែល -- តើមានកម្មាភិបាលមកពីភូមិភាគឧត្តរចាស់ណាទៀតដែលបាត់ខ្លួននៅក្នុងឆ្នាំ៧៧ ដែរឬទេ?

**ឆ៖** ខ្ញុំដូចជាមិនចាំដែរ។ មិនចាំថា ពួកកម្មាភិបាលខ្លះនៅតំបន់ណា ខ្ញុំអត់បានចាំ ដូចថាវាភ្លេចតែម្ដង។

[១៣:៣៨:២០]

**ស៖** ខ្ញុំសូមជួយលោកស្រីក្នុងការរំឭកនូវការចងចាំរបស់លោកស្រីឡើងវិញ។ ខ្ញុំដឹងថាលោកស្រីមិនអាចអានអក្សរបាន ដូច្នេះខ្ញុំនឹងរៀបរាប់ប្រាប់លោកស្រីអំពីឯកសារមួយចំនួន មកពីមន្ទីរស-២១ ដែលកត់ត្រាការចាប់ខ្លួន និងការសម្លាប់កម្មាភិបាលរាប់រយនាក់មកពីភូមិភាគរបស់លោកស្រី

នៅក្នុងឆ្នាំ៧៧។ E3/2956 គឺជាបញ្ជីដែលខ្ញុំទើបតែជម្រាបលោកស្រីដែលមានឈ្មោះ តុល នៅក្នុងទីនោះ បានរៀបរាប់អំពីមនុស្សចំនួន៩៤ គឺកម្មាភិបាលមកពីភូមិភាគឧត្តរចាស់ ភាគច្រើនមកពីកម្រិតស្រុក តំបន់ និងភូមិភាគ ដែលត្រូវបានចាប់ខ្លួន ហើយបញ្ជូនទៅ ស-២១ ចន្លោះពាក់កណ្តាលខែកុម្ភៈ និងចុងខែមីនា ឆ្នាំ៧៧។ ហើយឯកសារបន្ទាប់គឺ E3/3861 ជាបញ្ជីសម្លាប់អ្នកទោសនៅស-២១ ដែលមានចំណងជើងថា "បញ្ជីអ្នកទោសដែលត្រូវបានកម្ទេចនៅថ្ងៃ០៨ ខែកក្កដា ៧៧ ភូមិភាគឧត្តរ"។ បញ្ជីនេះបានកំណត់ឈ្មោះអ្នកទោស១៧៣នាក់ មកពីភូមិភាគរបស់លោកស្រី ដែលត្រូវបានសម្លាប់នៅ ស-២១ នៅថ្ងៃ -- នៅក្នុងរយៈពេលតែ១ថ្ងៃប៉ុណ្ណោះគឺថ្ងៃ០៨ កក្កដា ៧៧។ លោកស្រីសាក្សី តើលោកស្រីមិនកត់សម្គាល់ទេឬ ថានៅឆ្នាំ៧៧ គឺថាមានកម្មាភិបាលមកពីភូមិភាគឧត្តរជាច្រើនបានបាត់ខ្លួន ហើយត្រូវបានជំនួសដោយកម្មាភិបាលមកពីភូមិភាគនិរតីនោះ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប!

អញ្ជើញលោកមេធាវី វ៉ិចទ័រ កូប៉េ!

[១៣:៤០:២០]

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន ខ្ញុំជំទាស់ទៅនឹងពាក្យថា "បាត់ខ្លួន"។ ពាក្យនេះត្រូវបានប្រើប្រាស់ជារៀងរហូតមក។ ពេលខ្លះប្រើប្រាស់ដោយត្រឹមត្រូវ ពេលខ្លះប្រើប្រាស់ដោយខុស។ ព្រះរាជអាជ្ញាទើបតែអាននូវបញ្ជីឈ្មោះអ្នកដែលត្រូវបានចាប់ខ្លួន ហើយត្រូវបានចោទថាសម្លាប់ ប៉ុន្តែបុគ្គលនេះមិនបានបាត់ខ្លួននោះទេ។ ដូច្នេះខ្ញុំចង់ឲ្យព្រះរាជអាជ្ញាសួរសំណួរឡើងវិញដោយមិនប្រើប្រាស់ពាក្យ "បាត់ខ្លួន" នេះ។

**លោក ឌេល លីសាក់៖**

ខ្ញុំរីករាយនឹងសួរសំណួរឡើងវិញលោកប្រធាន។

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** លោកស្រីសាក្សី តើលោកស្រីមិនដឹងទេឬថា នៅឆ្នាំ៧៧ គឺថាសឹងតែគ្រប់កម្មាភិបាលទាំងអស់មកពីកម្រិតភូមិភាគ តំបន់ និងស្រុកត្រូវបានគេយកទៅសម្លាប់ ហើយត្រូវបានជំនួសដោយមនុស្សមកពីភូមិភាគនិរតីវិញនោះ? តើលោកស្រីមិនដឹងទេឬ?

[១៣:៤១:១៦]

## លោកស្រី ស៊ូ សឿន៖

**ឆ៖** ចាស ជួនកាលក៏មិនដឹងដែរ ព្រោះការងារនេះជួនកាលខ្ញុំបាត់ត្រឹម ជួនកាលមិនដឹងថាបាត់ត្រឹមនោះ តែមិនដឹងគេយកទៅណា ខ្ញុំមិនដឹង។ ប៉ុន្តែខ្លះក៏ស្គាល់ ខ្លះក៏មិនស្គាល់ ស្គាល់ច្បាស់តែលោក ថុល មួយ ក្រៅពីនុំងចាំមិនបាន។

**សៈ** ខ្ញុំសូមអាននូវឈ្មោះមួយចំនួនដែលស្និទ្ធស្នាលជាមួយលោកស្រី ហើយសួរលោកស្រីថា លោកស្រីដឹងដែរឬទេ? នៅក្នុងកំណត់ហេតុស្តាប់ចម្លើយសាក្សី E3/375 អង់គ្លេសមានលេខ 00360752, ខ្មែរ 00348791, បារាំងមានលេខ 00369914។ គឺសាច់ថ្លៃរបស់លោកស្រី ដែលយើងទើបតែនិយាយហើយគឺឈ្មោះ បាន ឬក៏ ផុស នោះដែលធ្វើការជាមួយលោកស្រីនៅគណៈស្រុកចំការលើនោះ បានផ្តល់សក្ខីកម្មដូចតទៅនេះ ខ្ញុំសូមដកស្រង់៖ "បន្ទាប់ពីមានការបោសសម្អាតត្រូវបានធ្វើឡើងនៅភូមិភាគកណ្តាល មានតែមនុស្សសំខាន់បួននាក់ប៉ុណ្ណោះនៅរស់រានមានជីវិតគឺ កែ ពក, អៀង ឆាំ, អឿន ហើយនិងខ្ញុំ។ អ្នកដទៃផ្សេងទៀតត្រូវបានកម្ទេច។ ស៊ូ សឿន ដែលជាបងថ្លៃរបស់ខ្ញុំ និងជាប្រពន្ធរបស់ កែ ពក ដែលគឺជាគណៈស្រុកចំការលើ។" នេះគឺជាអ្វីដែលប្តី -- ហើយឯកសារបន្តគឺជាអ្វីដែលប្តីលោកស្រីបាននិយាយគឺនៅក្នុងឯកសារ E3/2782 និង E3/2783, អង់គ្លេសមានលេខ 00089713 ដល់ 14, ខ្មែរមានលេខ 00095552, បារាំងមានលេខ 00596211។ ខ្ញុំសូមដកស្រង់អំពីសម្តីរបស់ប្តីលោកស្រី៖ "នៅក្នុងខែមិថុនា ឆ្នាំ៧៧ ដំណាក់កាលចាត់ការ -- ចាប់ការចាប់ខ្លួនវគ្គដំបូងហើយពេលនោះនៅសល់តែខ្ញុំ។ ពេលនោះធ្វើការនៅភូមិភាគកណ្តាលអស់ ខាងលើក៏សម្រេចយកកម្មាភិបាលពីនិរតីមកដាក់។ ខាងលើហៅកម្មាភិបាលពីនិរតីមក២០០នាក់ជាង។" សូមបញ្ចប់ការដកស្រង់។ លោកស្រីសាក្សី តើលោកស្រីចាំអំពីការមកដល់របស់កម្មាភិបាលភូមិភាគនិរតី ដែលមកទទួលតំណែង និងជំនួសកម្មាភិបាលរបស់ភូមិភាគនិរតីចាស់ដែរឬទេ?

[១៣:៥៤:២៦]

**ឆ៖** ខ្ញុំចាំមិនបានទេ។

**សៈ** តើលោកស្រីដឹងថាប្តីរបស់ -- ថាតើលោកស្រីយល់យ៉ាងម៉េចដែរ ទាក់ទងទៅនឹងការដែលប្តីរបស់លោកស្រីដឹងអំពីការបោសសម្អាតនៅភូមិភាគកណ្តាល -- ភូមិភាគឧត្តរចាស់ ហើយជំនួសដោយកម្មាភិបាលមកពីភូមិភាគនិរតីវិញនោះ?

**ឆ៖** ចាស ខ្ញុំមិនយល់យ៉ាងម៉េច ព្រោះខ្ញុំយល់ថាខ្ញុំការងាររបស់ខ្ញុំផ្សេង ការងាររបស់គាត់

ផ្សេង ត្រង់សម្រេចយ៉ាងម៉េចៗស្រេចតែលើគាត់ទាំងអស់ តែចំណែកខ្ញុំៗអត់ដឹងទេ។

**ស៖** ឥឡូវនេះយើងនិយាយអំពីអ្នកនៅក្នុងស្រុករបស់លោកស្រីវិញម្តង។ គឺលេខ68 គឺឯកសារ E3/342 គឺលេខ 6802 នៅក្នុងបញ្ជីរបស់សហព្រះរាជអាជ្ញាគឺឈ្មោះ នួន រឿន ហៅ ទៀង។ នួន រឿន ហៅ ទៀង ដែលត្រូវបានកំណត់ថាជាលេខាស្រុកចំការលើ និងជាអនុលេខាតំបន់៤២ បានចូលមន្ទីរ ស-២១ នៅថ្ងៃទី០១ ខែតុលា ឆ្នាំ៧៧។ តើលោកស្រីចាំអំពីកម្មាភិបាលឈ្មោះ ទៀង ដែលជាលេខាស្រុកចំការលើកដែរឬទេ?

[១៣:៤៦:៣៣]

**ឆ៖** ចាស ឈ្មោះ ទៀង នេះខ្ញុំគ្រាន់តែឮទេ តែអត់បានឃើញមុខគ្នាទេ ធ្លាប់តែឮគេនិយាយទេ។

**ស៖** តើគាត់ជាលេខាស្រុកចំការលើមែន ឬក៏មិនមែន?

**ឆ៖** ចាស ជំនាន់ខ្ញុំទៅធ្វើការនៅកន្លែងហ្នឹង ជាសមាជិកស្រុក ដូចជាមិនបានឃើញឈ្មោះហ្នឹង ហើយក៏ជួនកាលក៏ខ្ញុំភ្លេច ក៏មិនដឹង តែខ្ញុំស្គាល់ច្បាស់តែលោក បាន ហើយខ្ញុំ ហើយក្រៅពីហ្នឹងបីនាក់ទៀត ខ្ញុំភ្លេចអស់ហើយ រកនឹកមិនឃើញ។

**ស៖** ខ្ញុំនឹងសាកសួរបន្ថែមពីឈ្មោះមួយចំនួនមកពីស្រុកចំការលើ។ បញ្ជីអ្នកទោស ស-២១ ដែលខ្ញុំបានបង្ហាញពីខាងលើមកហើយគឺ E3/2956 លេខ 70, 71 និង72។ នៅក្នុងឯកសារ E3/2956 គឺមានកម្មាភិបាលមកពីស្រុកចំការលើដែលបានបញ្ជូនទៅ ស-២១ នៅក្នុងខែមីនា ឆ្នាំ៧៧។ មានឈ្មោះបីនាក់ ដែលខ្ញុំនឹងអានជូនលោកស្រីគឺ ម៉ក់ ប៊ាង, អេង ហ៊ ហៅស៊ឺន, និង សុក ផល ហៅសែម។ តើលោកស្រីស្គាល់ឈ្មោះមនុស្សទាំងបីនេះដែរឬទេ លោកស្រីសាក្សី?

**ឆ៖** ចាស ខ្ញុំស្គាល់តែឈ្មោះ សែម មួយ ក្រៅពីនោះ ខ្ញុំអត់ស្គាល់ អត់ចាំពេលហ្នឹង។

**ស៖** *(គ្មានការបកប្រែ)*

[១៣:៤៨:៤១]

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់! សូមអញ្ជើញលោកមេធាវី វ៉ិចទ័រ កូប៉េ!

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំសូមធ្វើការកត់សម្គាល់ទាក់ទងទៅនឹងសំណួរកន្លងមកអំពីឈ្មោះ ទៀង។ ខ្ញុំមិនអាចលើក

និយាយឡើងវិញទេ ប៉ុន្តែគាត់អាចជាកម្មាភិបាលនៅក្នុងស្រុកត្រាំកក់នោះទេ មិនមែនជាកម្មាភិបាលនៅស្រុកចំការលើនោះឡើយ។

**លោក ឌេល លីសាក់៖**

លោកប្រធាន ខ្ញុំមិនឆ្លើយតបនោះទេ ព្រោះថាយើងអាចពិភាក្សា ហើយនិងជជែកនៅលើឯកសារនេះនៅពេលណាមួយផ្សេង។

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** លោកស្រីនិយាយថាលោកស្រីស្គាល់ឈ្មោះ សែម តើមានអ្វីកើតឡើងចំពោះ សែម នៅក្នុងខែមីនា ឆ្នាំ៧៧? លោកស្រីដឹងទេ?

[១៣:៤៩:៤៨]

**លោកស្រី ស៊ូ សឿន៖**

**ឆ៖** សែម ពេលនោះមិនដឹងថាមូលហេតុអី ក៏គាត់បែកពីខ្ញុំទៅ ក៏ស្រាប់តែបាត់ដំណឹងឈឹងទៅ មិនដឹងជាគាត់ទៅខាងណា។ ខ្ញុំចាំតែប៉ុណ្ណឹង។

**ស៖** លោកស្រីសាក្សី តើលោកស្រីដឹងដែរឬទេថា ប្ដីរបស់លោកស្រីដែលជាលេខាតំបន់ ជាអ្នកសម្រេចឲ្យចាប់ខ្លួនកម្មាភិបាលនៅភូមិភាគឧត្តរ ឬមួយក៏មេដឹកនាំនៅទីក្រុងភ្នំពេញទេ ដែលជាអ្នកចេញសេចក្ដីសម្រេចចាប់ខ្លួនកម្មាភិបាលទាំងអស់នោះ? តើអ្នកណាជាអ្នកសម្រេច?

**ឆ៖** ចាស ខ្ញុំសូមឆ្លើយ ត្រង់ហ្នឹងខ្ញុំក្លាប់មិនបានទេ ព្រោះការងាររបស់គាត់ គាត់ផ្សេង ការងារអ្វីគាត់ទាំងអស់ ហើយចំណែកខាងខ្ញុំ អត់មានដឹងទេ។ កិច្ចការអី គាត់ ខាងគាត់អ្នករ៉ាប់រងម៉េច ក៏ស្រេចលើគាត់ទាំងអស់។ ចំណែកខាងប្រពន្ធ អត់មានប៉ះ មានទាក់ទងអីទេរឿងអីចឹងៗ គឺអត់មានទាក់ទងរឿងបោសរឿងអី រឿងចាប់រឿងចង អត់ទេ។ ខ្ញុំអត់ដឹងទេ។

[១៣:៥១:៣៨]

**ស៖** ខ្ញុំចង់ -- ខ្ញុំនឹងអានឲ្យលោកស្រីស្ដាប់នូវប្រធានបទមួយទៀត គឺឯកសារ E3/2782 និង E3/2783 ខ្មែរមានលេខ 0009552--, អង់គ្លេសមានលេខ 00089713, បារាំងមានលេខ 005962 11។ នេះគឺជាអ្វីដែលប្ដីលោកស្រីបានឆ្លើយ ខ្ញុំសូមដកស្រង់៖ "នៅពេលដែលខ្ញុំធ្វើការប្រមូលផ្ដុំនៅក្នុងតំបន់៤១ នីរសារមកពីភ្នំពេញបានមកដល់ ប្រាប់ខ្ញុំឲ្យត្រៀមរៀបចំសម្រាប់បេសកកម្មចុះស៊ើបអង្កេតនៃទីតាំងមួយចំនួន ប៉ុន្តែនៅពេលដែលខ្ញុំមកដល់ទីក្រុងភ្នំពេញ ខ្ញុំជួប ប៉ុល ពត និងបង នួន ជា។ ពួកគេ

បង្ហាញខ្ញុំនូវឯកសារអំពីតំបន់ និងក្រសួងទាំងអស់។ បន្ថែមទៅលើនេះទៀត ចម្លើយគឺច្បាស់ៗ ច្បាស់ខ្លាំងមិនអាចកែតម្រូវបាន។" ហើយបន្តចុះមកទៀត៖ "ខ្ញុំនិយាយថា វាពិបាកក្នុងការនិយាយ ពីព្រោះកម្មាភិបាលទាំងអស់ គឺជាមិត្តភក្តិរួមស្លាប់ រួមរស់ជាមួយខ្ញុំ ប៉ុន្តែបើសិនអង្គការបានសម្រេចរួចទៅហើយ ខ្ញុំមិនមានការតវ៉ាអ្វីទៀតនោះទេ។ កងទ័ពខ្លះបានធ្វើការជាមួយខ្ញុំតាំងពីឆ្នាំ៦៨ ប៉ុន្តែពួកគេត្រូវបានចោទប្រកាន់ថាជា សេ.អ៊ី.អា។ ខ្ញុំមិនដឹងថាត្រូវធ្វើយ៉ាងម៉េចទេ ក្រៅពីប្រាប់ពួកគេ។ ខ្ញុំត្រូវដាក់ពួកគេទៅថ្នាក់លើ គឺទៅបងខាងលើ។" លោកស្រីសាក្សី ខ្ញុំដឹងថានេះជាប្រធានបទពិបាកក្នុងការពិភាក្សា ហើយលោកស្រីក៏ពិបាកដែរ ក្នុងនាមជាគណៈស្រុក ហើយប្តីលោកស្រីជាប្រធានគណៈភូមិភាគ ហើយបងប្អូនលោកស្រីជាប្រធានគណៈតំបន់។ ប៉ុន្តែតើប្តីរបស់លោកស្រី ធ្លាប់ពិភាក្សាជាមួយលោកស្រី អំពីការដែលគាត់បានជួបប្រជុំជាមួយ ប៉ុល ពត ជាមួយនឹង នួន ជា ព្រមទាំងការបង្គាប់បញ្ជាឲ្យចាប់ខ្លួន និងបោសសម្អាតកម្មាភិបាលមកពីភូមិភាគឧត្តរដែរឬទេ?

[១៣:៥៤:០២]

**ឆ៖** ចាស ខ្ញុំឆ្លើយថាកិច្ចការទាំងអស់នេះ -- ខ្ញុំបានបញ្ជាក់ម្តងជាពីរដងហើយ -- កិច្ចការទាំងអស់ ការងារទាំងអស់គឺការងារគាត់ គឺគាត់ដឹង។ ការងារខ្ញុំ ខ្ញុំដឹង តែរឿងអីៗ តែខ្ញុំអត់ដឹងទេ។ រឿងទាក់ទងជាមួយខាងលើ ជាមួយអង្គការ ជាមួយអីនេះ ខ្ញុំមិនដឹងទេ រឿងអីចឹងៗ ខ្ញុំមិនដឹងទេ។

**លោក ឌេល លីសាក់៖**

សូមអរគុណលោកស្រី ហើយសហការីជាតិរបស់ខ្ញុំ គាត់មានសំណួរមួយចំនួន ដើម្បីសាកសួរលោកស្រីបន្តទៀត។ សូមអរគុណ។

**លោក សេង លាង៖**

ជម្រាបសួរលោកប្រធាន។ ជម្រាបសួរលោក លោកស្រីចៅក្រមទាំងអស់។

**សួរដោយលោក សេង លាង៖**

**ស៖** ជម្រាបសួរលោកស្រីសាក្សី ខ្ញុំបាទឈ្មោះ សេង លាង ជាសហព្រះរាជអាជ្ញារងជាតិ។ ដោយសារថាបញ្ហាពេលវេលាវាតិចតួចសម្រាប់ខ្ញុំ ដូច្នេះខ្ញុំមានសំណួរបីបួនតែប៉ុណ្ណោះ ដើម្បីសួរបញ្ជាក់ទៅលើលោកស្រី។ កាលពីព្រឹកមិញ លោកស្រីបានលើកឡើងថា លោកស្រីជាអ្នករើសប្រជាជនពីសហករណ៍ឲ្យទៅធ្វើការនៅទំនប់១មករា។ លោកស្រីបាននិយាយយ៉ាងដូច្នេះ នៅវេលាម៉ោងដប់សាមសិបប្រាំមួយនាទីព្រឹកនេះ។ សំណួររបស់ខ្ញុំចង់បញ្ជាក់ថា តើលោកស្រីអាចនិយាយលម្អិតបន្តិចបានទេ

ថា តើលោកស្រីរើសប្រជាជនឲ្យទៅធ្វើការនៅទំនប់១មករាហ្នឹង តាមរបៀបណាដែរ?

[១៣:៥៦:២៤]

**លោកស្រី ស៊ូ សឿន៖**

**ឆ៖** ចាស រើសតែប្រជាជនសហករណ៍ទៅធ្វើការទំនប់១មករា ខ្ញុំមិនបានចុះផ្ទាល់ទេ ទៅតាមសង្កាត់នីមួយៗ តើសង្កាត់គេរើសអ្នកណាមានសមត្ថភាពយ៉ាងណា មានសុខភាពយ៉ាងណា ក៏ស្រេចទៅលើគាត់រើស ហើយចំណែកចំនួនប៉ុន្មានៗ ខ្ញុំអត់ដឹងដែរ។

**ស៖** លោកស្រីអាចបញ្ជាក់បានទេថា ពាក្យថា "សង្កាត់" នេះគឺដូចគ្នានឹងពាក្យថា "ឃុំ" ដែរឬទេ?

**ឆ៖** ចាស សម័យនោះគេហៅតែ "ឃុំ" បើពីឥឡូវនេះគេហៅ "ឃុំ" ពីមុនគេហៅ "សង្កាត់"។ ពីសម័យខ្ញុំគឺហៅសង្កាត់។ ហៅសង្កាត់ ភូមិ ឃុំ សង្កាត់ ហ្នឹងវារួមគ្នាអ៊ីចឹង សហករណ៍នីមួយៗមានសង្កាត់គេអ្នកគ្រប់គ្រងប្រជាជន។ ចាស ខ្ញុំជម្រាបបានប៉ុណ្ណឹង។

**ស៖** តើលោកស្រីអាចប្រាប់បានទេ ថានៅក្នុងស្រុកចំការលើរបស់លោកស្រីហ្នឹង មានប៉ុន្មានសង្កាត់ដែរ?

**ឆ៖** ចាស ខ្ញុំសូមជម្រាបទៅវិញថា អត់ចាំៗសង្កាត់ប៉ុន្មានទេ ភូមិប៉ុន្មាន ប្រជាជនប៉ុន្មាន ខ្ញុំភ្លេចអស់។ តាំងពីនោះមកដល់ឥឡូវ វាយូរដែរហើយ។ តាំងពីជំនាន់ខ្ញុំអាយុ៥០, ៤០ ឥឡូវមកដល់៧៩ហើយ ដូចថានឹកមិនឃើញ ភ្លេចអស់ហើយ។

**ស៖** អរគុណលោកស្រី។ តើលោកស្រីអាចដឹងទេថា តើក្នុងការជ្រើសរើសប្រជាជនហ្នឹង ក្នុងមួយសង្កាត់ហ្នឹង តើតម្រូវឲ្យរើសប៉ុន្មាននាក់ដែរ?

[១៣:៥៨:៥៤]

**ឆ៖** ចាស សង្កាត់នីមួយៗ រើសតាមសហករណ៍ទៀត។ សហករណ៍នីមួយយកប៉ុន្មាន អាហ្នឹងបញ្ជីនៅលើប្រធានស្រុកទាំងអស់។ បើយកប៉ុន្មានៗ គ្រាន់តែយើងគ្រាន់ថាឥឡូវក្មួយឯងរើសយកសង្កាត់នេះមួយ យកប៉ុន្មាន។ ២០នាក់ ឬក៏៣០នាក់ រើសហើយ បញ្ជីកត់ហើយ បញ្ជូនទៅស្រុកគេទៅ។ ហើយចំណែកខាងខ្ញុំ ខ្ញុំអត់ចេះអក្សរ ដូច្នេះអត់បានទទួលទេ បញ្ជីហ្នឹងនោះ។

**ស៖** លោកស្រីពីព្រឹកមិញក៏បាននិយាយដែរថា លោកស្រីជាអ្នកដឹកនាំ ទទួលខុសត្រូវក្នុងការដឹកនាំប្រជាជនឲ្យទៅលើទំនប់១មករា។ ចង់ឲ្យលោកស្រីជួយបញ្ជាក់បន្តិចថា តើលោកស្រីមានចុះជាប់

ជាមួយនឹងប្រជាជនដែលធ្វើការនៅទំនប់១មករានោះ ឬមួយក៏យ៉ាងណាដែរ?

**ឆ៖** ចាស ខ្ញុំអត់បានទៅទេ។ អត់បានទៅជាប់ជាមួយប្រជាជនទេ គ្រាន់តែទៅម្តងម្កាល ដូចថា ទៅសួរសុខទុក្ខបងប្អូនម្តងម្កាលប៉ុននុ៎ង។ មិនបានទៅជាប់ថិតថេរនៅជាមួយបងប្អូនទេ។ ជួនកាលក៏១ខែ២ខែទៅបានៗទៅលេងម្តង១ថ្ងៃ ឬក៏២ថ្ងៃប៉ុណ្ណឹងឯងមកវិញ។

**ស៖** អរគុណលោកស្រី។ ចុះបើសិនជាលោកស្រីអត់ចុះទៅជាប់អ៊ីចឹង តើលោកស្រីមានចាត់តាំងនរណាម្នាក់ដែលនៅក្រោមបង្គាប់លោកស្រីក្នុងការចុះជាប់ជាមួយនឹងកម្លាំងពលករ នៅទំនប់១មករាដែរឬទេ?

[១៤:០១:០៥]

**ឆ៖** កម្លាំងសហករណ៍ គឺមានប្រធានគេ។ ប្រធានដូចថាមួយឃុំអ៊ីចឹង គេមានប្រធានសង្កាត់គេមួយ។ ប្រធានសង្កាត់គេមួយ គេទៅគ្រប់គ្រងសហករណ៍នៅកន្លែងហ្នឹង ចំនួនប៉ុន្មានៗ ស្រេចលើប្រធានសង្កាត់។ តែចំណែកខ្ញុំអត់បានទៅគ្រប់គ្រងផ្ទាល់ទេ គ្រាត់តែទៅសួរសុខទុក្ខម្តងៗ។

**ស៖** ចុះបើសិនជាលោកស្រីអត់ចុះជាប់អ៊ីចឹង តើនៅពេលដែលសង្កាត់ ប្រធានសង្កាត់នីមួយៗត្រូវរាយការណ៍នោះ តើគេទៅរាយការណ៍ជូនលោកស្រី ឬក៏ជូននរណាគេ?

**ឆ៖** ចាស ដល់ពេលគេរាយការណ៍ជូន គឺជូនប្រធានស្រុក ហើយបានយើងនិយាយថា ចំនួនប្រជាជនទៅធ្វើការ ចំនួនប៉ុន្មាននៅលើបញ្ជីរបស់គេទាំងអស់។ គេដឹងហើយ។

**ស៖** ចុះលោកស្រីដែលទទួលរបាយការណ៍ពាក់ព័ន្ធជាមួយនឹងការអនុវត្តការងារនៅទំនប់១មករាហ្នឹង ថាតើវាមានការលំបាកយ៉ាងណា ងាយស្រួលយ៉ាងណាដែរឬទេ ពីអ្នកនៅក្រោមបង្គាប់របស់លោកស្រី?

**ឆ៖** ចាស ហ្នឹងគេមានប្រធានគេទទួលខុសត្រូវហើយ ពិបាក ស្រួល ខ្វះខាតទៅតាមប្រធានសង្កាត់នីមួយៗគេនឹងយកទៅផ្គត់ផ្គង់។ ចំណែកខ្ញុំគ្រាន់តែគេមកនិយាយប្រាប់ផ្ទាល់ៗអ៊ីចឹង ប្រាប់ថា "ឥឡូវបងអ្អើយ ការងារបងប្អូនខ្វះអ៊ីចេះខ្វះអ៊ីចុះ" ហើយខ្ញុំប្រាប់តាមប្រធានសង្កាត់ទៅ ថាឥឡូវខ្វះ ហើយយើងរែតាមសហករណ៍មួយយកទៅចែកបងប្អូនទៅ។ ប៉ុន្តែក្នុងហ្នឹងក៏មានអង្គការជួយហើយ អត់ខ្វះអីទេ។

[១៤:០៣:៣១]

**ស៖** ចុះនៅពេលដែលមានការរាយការណ៍មកជូនលោកស្រីអំពីការលំបាកនោះ តើលោកស្រី

ធ្វើយ៉ាងណាដើម្បីរាយការណ៍ទៅថ្នាក់លើទៀត?

**ឆ៖** ចាស ទទួលការរាយការណ៍ហើយ ខ្ញុំពិភាក្សាជាមួយគណៈស្រុកហើយ ក៏លេខាស្រុកគេរាយការណ៍ទៅតំបន់។ ចាស យល់ប៉ុណ្ណឹង។

**ស៖** ចុះនៅពេលដែលលោកស្រីបានទទួលផែនការពីថ្នាក់លើនោះ តើលោកស្រីមកផ្សព្វផ្សាយជាមួយនឹងសហករណ៍ដែលធ្វើការនៅទំនប់១មករា តាមរបៀបណាដែរ?

**ឆ៖** ចាស រឿងទទួលពីការរាយការណ៍ពីខាងលើហើយ គឺថា ឥឡូវត្រូវគិតយ៉ាងម៉េច ខាងស្រុកជំនុំប្រជុំគ្នាទៅ ហើយចាត់កម្លាំងទៅទំនប់១មករា។ តាមនិយាយឲ្យត្រង់ទៅគឺថា ខាងផ្នែកខាងស្រុក ឬក៏ផ្នែកខាងខ្ញុំផ្ទាល់ ខ្ញុំមិនបានទៅស្ថិតស្ថេរ ហើយក៏មិនបានទៅដឹកនាំផ្ទាល់នៅកន្លែងទំនប់១មករាទេ ព្រោះខ្ញុំភារកិច្ចនៅខាងស្រុកដឹកនាំប្រជាជនធ្វើទំនប់ ធ្វើប្រឡាយ មិនបានទៅ រឿងទំនប់១មករា គេមានការចាត់តាំងរបស់គេហើយ។ ដែលខ្ញុំទទួលខុសត្រូវ ខ្ញុំនៅចំការលើណេះ ជីកប្រឡាយ ជីកទំនប់នៅណេះទេ។ កម្លាំងខ្ញុំគ្រប់គ្រងនៅឯណេះ។ អ៊ីចឹងបានថា រឿងទាក់ទង ខ្ញុំមិនដឹងទេរឿងទំនប់១មករា ទៅៗ គ្រាន់តែទៅលេងដូចភ្ញៀវអ៊ីចឹង គ្រាន់ទៅមើលអ៊ីចឹង។ ខ្ញុំជម្រាបតាមត្រង់។

[១៤:០៥:៤៧]

**ស៖** ដោយសារពេលវេលាអស់ហើយ ខ្ញុំសុំសួរតែមួយសំណួរទៀតទេ។ ខ្ញុំចង់សួរលោកស្រីថា លោកស្រីជាអ្នកបញ្ជូនពលករឲ្យទៅធ្វើការនៅទំនប់១មករាហ្នឹង តើលោកស្រីបានផ្ដល់នូវឧបករណ៍អ្វីខ្លះឲ្យពួកគេក្នុងការទៅលើកទំនប់១មករាហ្នឹង?

**ឆ៖** ខ្ញុំមិនបានបញ្ជូនឧបករណ៍អីទេ ព្រោះកន្លែងធ្វើការនោះ វាមានគ្រប់សព្វអស់ហើយ។ មានប្រដាប់ប្រដាគេ មានចប មានកាំបិត មានពូថៅ មានបង្គីអស់ហើយ។ ខ្ញុំអត់មានការចាត់ -- បញ្ជូនអីទៅទៀតទេ។ កម្លាំងទៅប៉ុន្មានគឺរៀបចំម្ចាស់ការទាំងអស់។

**ស៖** តាមដែលលោកស្រីមានប្រសាសន៍ មានន័យថា ពលករទាំងនោះគឺប្រើតែចប បង្គី ក្នុងការលើកទំនប់នោះ ដោយគ្មានប្រើឧបករណ៍អីផ្សេងទៀតទេ ឬយ៉ាងណា?

**ឆ៖** ចាស កន្លែងធ្វើ -- កម្លាំងធ្វើការនៅទំនប់១មករា ជំនាន់ខ្ញុំនេះគឺគ្មានទេ មានតែកម្លាំង មានបង្គី មានតែចប មានតែកាំបិត សម្រាប់ត្រួសត្រាយផ្លូវព្រៃ និងចបកាប់ ហើយបង្គី ដងរែក មានប៉ុណ្ណឹងហើយកម្លាំងរែកប៉ុណ្ណឹង។ កាលណាជីវភាពគ្រប់គ្រាន់ កម្លាំងវាមានរែកដី។ ខ្ញុំសូមជម្រាបប៉ុណ្ណេះ។

[១៤:០៧:៣៤]

**លោក សេង លាង៖**

អរគុណលោកប្រធាន ខ្ញុំសូមអស់សំណួរប៉ុណ្ណេះ ដោយសារថា ខាងមេធាវីដើមបណ្ដឹងគាត់មានសំណួរដែរ។ ខ្ញុំសូមបញ្ចប់សំណួរត្រឹមណេះ។ សូមអរគុណលោកស្រី។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ជាបន្តទៅនេះ អង្គជំនុំជម្រះសូមផ្ដល់វេទិកាជូនទៅក្រុមសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីដើម្បីមានឱកាសតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ។

សូមអញ្ជើញ!

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

សូមអរគុណលោកប្រធាន។ ជម្រាបសួរភាគីទាំងអស់។ មុនពេល -- មុនផ្ដល់វេទិកានេះជូនលោកស្រី ជេត វណ្ណលី ខ្ញុំសូមជម្រាបថា យើងត្រូវការពេលវេលា២០នាទីបន្ថែមទៀត ដើម្បីអាចឲ្យយើងសួរសំណួរដែលយើងចង់សួរទាំងអស់លោកប្រធាន។ ឥឡូវនេះគឺម៉ោងពីរ ដប់នាទីហើយ។ អ៊ីចឹងខ្ញុំធ្វើសំណើបន្ថែមជូនអង្គជំនុំជម្រះថា យើងត្រូវការពេលវេលាបន្ថែម២០នាទី។ បន្ទាប់មកខ្ញុំប្រគល់វេទិកានេះ ជូនលោកស្រីមេធាវី ជេត វណ្ណលី។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត។ សូមអញ្ជើញលោកស្រីមេធាវី!

[១៤:០៨:៣៨]

**លោកស្រី ជេត វណ្ណលី៖**

សូមគោរពលោកប្រធាន។ សូមគោរពលោក លោកស្រីចៅក្រម និងអង្គសវនាការទាំងមូល។

**ការតាំងសំណួរដោយសហមេធាវីដើមបណ្ដឹងរដ្ឋប្បវេណី**

**សួរដោយលោកស្រី ជេត វណ្ណលី៖**

**ស៖** ជម្រាបសួរលោកស្រី សូ សឿន។ ខ្ញុំមេធាវី ជេត វណ្ណលី ជាមេធាវីដើមបណ្ដឹងរដ្ឋប្បវេណី។ ពីព្រឹកមិញលោកស្រីបានបញ្ជាក់ និងបំភ្លឺនូវចំណុចមួយចំនួននៅចំពោះមុខអង្គសវនាការ ប៉ុន្តែខ្ញុំនៅតែចង់ឲ្យលោកស្រីបញ្ជាក់នូវចំណុចមួយចំនួនបន្ថែមទៀត ដើម្បីបំភ្លឺអង្គសវនាការ។ លោកស្រីជាប្រពន្ធរបស់លោក កែ ពក ដែលជាលេខាភូមិភាគ។ ខ្ញុំចង់ឲ្យលោកស្រីបញ្ជាក់ថា តើក្រៅពីតួនាទីជាលេខាភូមិភាគ តើប្ដីលោកស្រីមានតួនាទីអ្វីផ្សេងទៀតទេ?

**លោកស្រី សូ សឿន៖**

**ឆ៖** ចាស រឿងភារកិច្ចភូមិភាគ ក្រៅពីនុំងមានតែដឹកនាំប្រជាជនទៅមើលទំនប់១មករា។ ចាស មានប៉ុណ្ណឹង។

**ស៖** អរគុណលោកស្រី អរគុណ។ ពីព្រឹកមិញលោកស្រីថា មានពេលខ្លះលោកស្រីឡើងទៅជួបប្ដីលោកស្រីនៅភ្នំពេញ។ តើនៅភ្នំពេញ ប្ដីលោកស្រីមានតួនាទីជាអ្វីដែរនៅភ្នំពេញ?

[១៤:១០:២៨]

**ឆ៖** ចាស ព្រឹកមិញដូចខ្ញុំអត់បានឆ្លើយរឿងថា ខ្ញុំមកជួបគ្រួសារនៅភ្នំពេញ ដូចមិនបានជួប មិនបាននិយាយ។ ដូចខ្ញុំមិនបាននិយាយ។ តាមខ្ញុំចាំដូចជាមិនបាននិយាយ ហើយក៏គ្មានភារកិច្ចប្ដីមកនៅភ្នំពេញដែរ ភារកិច្ចនៅតែភូមិភាគកណ្ដាល។ បើថាចង់ជួបៗគ្នានៅកំពង់ចាម។ មានតែប៉ុណ្ណឹង។

**ស៖** អរគុណលោកស្រី។ លោកស្រីព្រឹកមិញលោកស្រីបានបញ្ជាក់ថា លោកស្រីមកភ្នំពេញពេលនោះលោកស្រីបានជួបអ៊ំ ប៉ុល ពត។ តើពេលដែលលោកស្រីជួបអ៊ំ ប៉ុល ពត ហ្នឹងលោកស្រីទៅជាកិច្ចការផ្ទាល់ខ្លួន ឬក៏ទៅជាកិច្ចការដែលត្រូវទទួលការណែនាំពីអ៊ំ ប៉ុល ពត?

**ឆ៖** ចាស រឿងខ្ញុំទៅភ្នំពេញខ្ញុំអត់មានទៅផ្ទាល់ខ្លួនទេ គឺខ្ញុំទៅទាល់តែមានភារកិច្ច ឬអង្គការហៅទៅធ្វើការបានខ្ញុំឡើងទៅ បើថាគ្មានភារកិច្ចពីរឿងអង្គការ -- រឿងការងារទេ ខ្ញុំអត់មានទៅជួបអីផ្ទាល់ខ្លួន ខ្លួនខ្ញុំទេ។

**ស៖** អរគុណលោកស្រី។ ខ្ញុំចង់ឲ្យលោកស្រីបញ្ជាក់ថា តើពាក្យដែលលោកស្រីបានៗលើកឡើងអំមិញថា ទៅការងារហ្នឹង ការងារអីទៅលោកស្រី?

[១៤:១២:០៨]

**ឆ៖** ការ -- ចាស ខ្ញុំទៅការងារហ្នឹងដូចថា អង្គការត្រូវហៅទៅប្រជុំដាក់ភារកិច្ចចែកគ្នាទៅតាមស្រុកតាមសង្កាត់នីមួយៗ។ ហើយខ្ញុំទៅហ្នឹងក៏ខ្ញុំមិនទៅតែឯង មនុស្សរាប់រយពាន់ទៅប្រជុំស្ដាប់គាត់អប់រំណែនាំពីរឿងធ្វើការ ត្រូវចែករំលែកគ្នាយ៉ាងម៉េច តាមស្រុកនីមួយៗត្រូវធ្វើអីខ្លះ ត្រូវចែកសហករណ៍យ៉ាងណាខ្លះ ត្រូវប្រជាជនគិតយ៉ាងណាខ្លះ។ ចាស មានការងារមានតែអ៊ីចឹងទេ។

**ស៖** អរគុណលោកស្រី។ ក្នុងនាមលោកស្រីជាប្រពន្ធរបស់លោក កែ ពក តើលោកស្រីដែលឃើញ -- តើលោកស្រីដឹងទេថា អ្នកណាជាថ្នាក់លើរបស់គាត់ខ្លះ?

**ឆ៖** ចាស ខ្ញុំដឹងតែ តាប៉ុល ពត, តានួន ជា, បងខៀវ សំផន ហើយខ្ញុំដឹងតែប៉ុណ្ណឹង ក្រៅពីហ្នឹង

ខ្ញុំអត់ដឹង។

**ស៖** អរគុណលោកស្រី។ តើលោកស្រីមានបានដឹងទេថា កន្លងមកទំនាក់ទំនងគាត់របៀបថ្នាក់លើ គាត់ធ្វើយ៉ាងម៉េចខ្លះ? តាមរយៈនីរសារ ឬក៏តាមរយៈសារទូរលេខ?

**ឆ៖** ចាស ជំនាន់ហ្នឹងគឺអត់មានទូរលេខទេ អត់មាននេះទេ តាមនីរសារ គឺថាទៅមាននីរសារគាត់ទៅផ្ទាល់ ទៅហៅពីកំពង់ចាម ឬមកភ្នំពេញ តែមិនមានដូចថាយើងជំនាន់យើងនេះមានទូរស័ព្ទអីខ្វាត់ខ្វែងទេ។ ហើយបើមានទូរលេខក៏ទាល់តែមានច្បាប់ទម្លាប់ ថាឥឡូវអង្គការខាងលើសម្រេចឲ្យហៅតាមទូរស័ព្ទបានហៅ បើមិនអ៊ីចឹងទេនីរសារទៅហៅយកមកផ្ទាល់ គឺទៅឡាន ឬម៉ូតូទៅយកមក។

[១៤:១៤:៣៩]

**ស៖** អរគុណលោកស្រី អរគុណ។ ក្រៅពីការប្រជុំ តើប្ដីលោកស្រីរាយការណ៍ពីការងារតាមមធ្យោយបាយណាទៀត? ទៅថ្នាក់លើលោកស្រី គាត់រាយការណ៍ទៅថ្នាក់លើ មានមធ្យោបាយណាផ្សេងទៀតទេ ក្រៅពីការប្រជុំ?

**ឆ៖** ចាស ខ្ញុំមិនដឹងទេរឿងការងាររបស់គាត់ ខ្ញុំមិនដឹងគាត់រាយការណ៍តាមណា ខ្ញុំអត់ដឹងដែរ។

**ស៖** ឥឡូវនេះ ខ្ញុំបកមកទំនប់១មកវាម្ដង។ តើលោកស្រីស្គាល់ឈ្មោះ សោ ទេលោកស្រី?

**ឆ៖** ចាស ខ្ញុំអត់ស្គាល់ទេ ឈ្មោះ សោ។

**ស៖** ចុះឈ្មោះ ឆាំ និងឈ្មោះ សុខា តើលោកស្រីបានស្គាល់ទេ?

**ឆ៖** ឆាំ ខ្ញុំស្គាល់ព្រោះធ្លាប់នៅជាមួយគ្នា ជិតគ្នា ទៅមក នីរសាររបស់គាត់។ តែ សោ -- មួយទៀតនោះ ខ្ញុំអត់ -- ដូចជាភ្លេចហើយ ភ្លេចឈ្មោះគេ។

**ស៖** សុខា?

**ឆ៖** ខានជួបគេយូរ វាភ្លេច។ សុខា ដឹងមួយណា ខ្ញុំភ្លេចបាត់ហើយ បែកគ្នាមិនដែលឃើញមុខគ្នាអ៊ីចឹង ភ្លេចទៅ រកនឹកមិនឃើញ។

**ស៖** ខ្ញុំចង់ឲ្យលោកស្រីបញ្ជាក់ថា តើអ្នកណាជាអ្នកដែលទទួលខុសត្រូវក្នុងបញ្ហាសាងសង់ទំនប់ហ្នឹង ឈ្មោះ ឆាំ ឬក៏ឈ្មោះ សុខា ឬក៏ឈ្មោះណាផ្សេងទៀត លោកស្រី?

[១៤:១៧:០៦]

**ឆ៖** ចាស អារឿងល្អិតហ្នឹង គឺខ្ញុំមិនបានយល់ទេ មិនបានដឹងទេរឿងអ្នកទទួលខុសត្រូវ ខ្ញុំដឹងតែ

ថាទំនប់១មករា គឺអង្គការអ្នករៀបចំ។ ដឹងតែប៉ុណ្ណឹងទេ។

**ស៖** សូមអរគុណលោកស្រី។ ខ្ញុំចង់ឲ្យលោកស្រីបញ្ជាក់ដែរ បើសិនជាលោកស្រីអាចបញ្ជាក់បាន ថាហេតុអីបានជាទំនប់ហ្នឹង គេដាក់ឈ្មោះ ទំនប់១មករា? ហើយហេតុអីបានជាគេធ្វើទំនប់ហ្នឹង លោកស្រី?

**ឆ៖** ចាស ទំនប់១មករាហ្នឹង តាមការយល់របស់ខ្ញុំគឺកម្លាំងអង្គការថា រៀបចំបិទទំនប់១មករា ដើម្បីយកទឹកចិញ្ចឹមប្រជាជន ចិញ្ចឹមសហករណ៍ឲ្យហូរមកដល់ស្រុកបារាយណ៍រហូតមក។ ត្រង់ថាយ៉ាងម៉េចទៀត ខ្ញុំអត់យល់ទេ។

**ស៖** អរគុណលោកស្រី។ ខ្ញុំចង់ឲ្យលោកស្រីបញ្ជាក់ដែរទៀតថា តើនៅថ្ងៃសម្ពោធហ្នឹង លោកស្រីមាននៅទីនោះទេ?

**ឆ៖** ចាស ថ្ងៃសម្ពោធ គឺខ្ញុំបានទៅសម្ពោធនឹងគេដែរ។

**ស៖** តើគេរៀបចំកម្មវិធីដូចម្ដេចដែរលោកស្រី? មានថ្លែងសុន្ទរកថា មានអ្នកឡើងមានមតិ មានគណៈអធិបតីណាខ្លះដែលចូលរួមលោកស្រី? សូមលោកស្រីបញ្ជាក់ឲ្យអង្គសវនាការទាំងមូលបានដឹងផងចាស។

[១៤:១៩:០០]

**ឆ៖** ទេ វែងពេក ដូចជាយូរពេក ខ្ញុំក៏អត់ចាំដែរ មិនដឹងថាអ្នកណាឡើង អ្នកណាថ្លែងការណ៍ ខ្ញុំក្ដាប់អត់បានដែរ ភ្លេចបាត់អស់។

**ស៖** សូមលោកស្រីរំឭកមើល មានអ្នកដឹកនាំណាខ្លះដែលលោកស្រីនៅចាំណ៎ា ដែលយើងគ្រាន់តែចាំខ្លះណ៎ា លោកស្រីមានអ្នកណាខ្លះ? ក្រែងលោលោកស្រីអាចនៅចាំបាន ដែលទៅនៅក្នុងពិធីសម្ពោធហ្នឹង?

**ឆ៖** ចាស ខ្ញុំចាំៗតែគ្រួសារប៉ុណ្ណឹង។ ឥឡូវនេះវាវិញ្ញាណវាកាន់តែខ្លីហើយ ដូច្នេះមានគេច្រើនតែខ្ញុំអត់ចាំ វាចាំច្បាស់តែគ្រួសារមួយ ហើយនិងកម្មាភិបាលចំនួន ជំនួស -- មួយស្រករខ្ញុំហ្នឹង ក៏គេស្លាប់អស់នៅសល់តែខ្ញុំ។

**ស៖** អរគុណលោកស្រី។ តើក្នុងពិធីសម្ពោធហ្នឹង គេធ្វើម៉េចខ្លះទៅលោកស្រី? លោកស្រីមានបានឃើញទេ?

[១៤:២០:២១]

**ឆ៖** ចាស ខ្ញុំបានឃើញ តែឥឡូវយកមកវ៉ាយវ៉ាប់ ក៏ខ្ញុំអត់ចាំទេៗថា គេធ្វើម៉េចខ្លះៗ ខ្ញុំអត់ចាំ។

**ស៖** អរគុណលោកស្រី។ ពីព្រឹកមិញលោកស្រីបាននិយាយថា លោកស្រីធ្លាប់បានចុះទៅការដ្ឋាន១មករា ហើយអម្បាញ់មិញនេះទៀត នៅចំពោះមុខព្រះរាជអាជ្ញា ក៏លោកស្រីបានបញ្ជាក់ដែរថា លោកស្រីបានទៅលេងនៅទំនប់១មករា។ ខ្ញុំចង់ឲ្យលោកស្រីបញ្ជាក់ឲ្យបានច្បាស់ថា តើពេលដែលលោកស្រីទៅលេងហ្នឹង លោកស្រីមានឃើញ -- ហើយពីព្រឹកមិញនេះទៀត លោកស្រីក៏បានបញ្ជាក់ដែរថា កម្មករទាំងអស់បានដេកនៅលើគ្រែ ដែលមានរនាប មិនផ្ទាល់ដីទេណា ហើយការហូបចុកក៏មិនខ្វះខាត។ ប៉ុន្តែចំណុចមួយដែលគួរឲ្យកត់សម្គាល់ គឺបញ្ហាអនាម័យ។ លោកស្រីបាននិយាយថា កាលនោះបង្គន់គឺអត់មានទេ គឺថាដើរជីក -- ដើរជុះតាពីតាពាស ហើយមានរុយ។ ដូច្នេះខ្ញុំចង់ឲ្យលោកស្រីបញ្ជាក់ដែរថា តើនៅក្នុងការដ្ឋានហ្នឹង ជាដំបូងគឺចង់ដឹងថា តើចំនួនមនុស្សប្រហែលប៉ុន្មានដែរលោកស្រី?

**ឆ៖** ចាស ទំនប់១មករា ដែលខ្ញុំបានបញ្ជាក់ពីព្រឹកហ្នឹង គឺថាមានរនាបមានអី តែរនាប មិនមែនរនាបអី រនាបកូនឈើហ្នឹង យើងកាប់ទៅធ្វើ រែងដេកខ្លួនឯងទៅ។ ខ្ញុំមិនមែនថា យករនាបៗឬស្សី រនាបអីហ្នឹងទាំងអស់ហ្នឹង កាប់យកទៅដេកទៅ រួមគ្នា សាមគ្គីគ្នា ធ្វើជម្រកជ្រក។ តែមនុស្សវាច្រើន អ្នកណាដែលបានទៅជួយធ្វើបាន ប្រហែលជា២០.០០០ ទៅ៣០.០០០នាក់ លើកទំនប់ហ្នឹង មិនមែនថាកម្លាំងតិចតួចទេ។ បើកម្លាំងតិចធ្វើទំនប់១មករាអត់បានទេ។ នេះកម្លាំងវា២០.០០០ទៅ៣០.០០០ហ្នឹង ខ្ញុំថាបន្ថយផង ប្រហែលជា៤០.០០០។ វាដូច្នេះអារឿងហូបចុក អារឿងបង្គន់ រឿងបត់ជើង រឿងអនាម័យ ឧទាហរណ៍ថា គ្រួសារយើងមួយម៉េច ក៏មិនបានស្អាត ចុះទម្រាំមនុស្សរាប់ម៉ឺនរាប់សែននាក់ អ្នកណាទៅការពារ។ ពេលនោះមានបង្គន់ឯណា ទាល់តែជុះតាមព្រៃតាមផ្សៃអីចឹងទៅ។ ហើយទឹកអូរ ទំនប់១មករា ទឹកហូរវឹង អត់ខ្វះទេ។ រួចចោទទៅលើអ្នកអនាម័យដែលនៅនុ៎ង បញ្ហាហ្នឹងយើងដោះស្រាយអីចឹង។ ខ្ញុំសូមឆ្លើយប៉ុណ្ណឹង។

[១៤:២៣:០៨]

**ស៖** អរគុណលោកស្រី។ ចុះលោកស្រីមានបានសង្កេតឃើញថា តើមានអ្នកឈឺថ្កាត់ច្រើនទេលោកស្រី?

**ឆ៖** ចាស ពេលខ្ញុំសង្កេត ខ្ញុំពិនិត្យមើលឃើញមានមនុស្សឈឺដែរ ព្រោះមនុស្សវាច្រើន។ អនាម័យវាមិនសូវស្អាត ដូច្នេះការស៊ីចុក ក៏វាទៅតាមហ្នឹងទៅ រុយរោមស្អីៗទៅ។ បើដល់អីចឹង វាមានអ្នកឈឺ ហើយជំនាន់នោះ វាមិនសូវមានថ្នាំសម្បូរប៉ុន្មានដែរទេ ព្រោះអង្គការទើបនឹងរៀបចំធ្វើថ្មី ដូច្នេះ

ថ្នាំចែកចាយតាមទំនប់មួយៗ វាខ្សោយដែរ។ ត្បិតតែឈឺ ក៏មានពេទ្យគេមើលដែរ មិនមែនអត់ទេ។

**សៈ** អរគុណ។ ចុះក្នុងករណីដែលមានការឈឺខ្លាំង តើគេបញ្ជូនទៅមន្ទីរពេទ្យ ឬនៅព្យាបាលនៅកន្លែង លោកស្រី?

**ឆៈ** ចាស ពេលឈឺខ្លាំង គេបញ្ជូនមកដាក់ពេទ្យកំពង់ចាម។ អ្នកណាគេឈឺខ្លាំង គេយកបញ្ជូនមកហ្នឹង នៅពេទ្យរដ្ឋនៅកំពង់ចាម។

**សៈ** អរគុណលោកស្រី។ ពីព្រឹកមិញលោកស្រីបានបញ្ជាក់ នៅមុខចំពោះមុខអង្គសវនាការថា លោកស្រីបាន -- ក្នុងនាមលោកស្រីជាគណៈស្រុកចំការលើ លោកស្រីបានបញ្ជូនមនុស្ស ឲ្យមកចូលរួមនៅក្នុងការដ្ឋាន១មករានេះដែរ។ ខ្ញុំចង់ឲ្យលោកស្រីបញ្ជាក់ដែរថា តើប្រភេទមនុស្សដែលលោកស្រីបញ្ជូនមកនោះ មានប្រុស មានស្រី ហើយមានជាៗកម្រិតមធ្យម តើលោកស្រីរើសពីមនុស្សអាយុប៉ុន្មានទៅ? កម្លាំងស្រួច ឬក៏កម្លាំងកណ្តាល?

**ឆៈ** ចាស ដែលរើសកម្លាំងយកទៅហ្នឹង ដូចខ្ញុំជម្រាបពីព្រឹកហើយ ថាប្រធានសហករណ៍ហើយនិងតាមភូមិ តាមសង្កាត់គេមួយៗ គេអ្នករើស តែគេរើសគឺរើសយកកម្លាំងពេញដែរ។ កម្លាំងពេញចាប់ពី៣០ ចុះមក២០ អាយុ២០ក៏មានដែរ ដល់អាយុ២៨ -- ១៨ ដប់អីហ្នឹងក៏មានកម្លាំង តែកន្លែងចាស់ៗ គាត់នៅកន្លែងសហករណ៍ មិនបានបញ្ជូនមកទេ បញ្ជូនតែកម្លាំងពេញ។

[១៤:២៦:០៨]

**សៈ** អរគុណលោកស្រី។ ចំពោះបញ្ហាសម្ភារៈ ពីព្រឹកមិញលោកស្រីបញ្ជាក់ថា ចប បង្គីអីហ្នឹងអង្គការអ្នកដោះស្រាយ ប៉ុន្តែខាងលោកស្រី ខាងស្រុក តើខាងស្រុកមានជួយ -- ចុះស្បៀងខាងណាអ្នកដោះស្រាយ ស្បៀងអាហារសម្រាប់ពលករដែលលោកស្រីបញ្ជូនពីស្រុករបស់លោកស្រី? ហើយចំពោះសម្លៀសបំពាក់ តើអង្គការផ្តល់ឲ្យ ឬក៏ជាសម្លៀកបំពាក់ផ្ទាល់ខ្លួន?

**ឆៈ** ចាស អារឿងសម្លៀកបំពាក់ហ្នឹងគឺរដ្ឋអ្នកផ្តល់។ មិនខ្វះទេ ខោអាវស្លៀកពាក់ ដូចថាគ្រាន់តែថាមិនមានពណ៌ មានតែខ្មៅ គឺថាមានមួយកំប្លេពីរកំប្លេ ក្នុងម្នាក់មានពីរបីកំប្លេដែរ មិនឲ្យអត់ទេរដ្ឋអ្នកចែក។ រឿងស្បៀងអាហារ គឺអង្គការអ្នកជួយបញ្ជូន តែមកតាមរយៈភាគក៏ដឹងអីមិនដឹង ទាល់កាលណាល្ងិតចាត់ចែងអីចឹង ខ្ញុំភ្លាប់អត់បានដែរ។

**សៈ** អរគុណលោកស្រី។ ហើយចំពោះមនុស្សដែលបញ្ជូនមក តើមនុស្សហ្នឹងនៅជាប់នៅការដ្ឋានរហូត ឬក៏មានការប្តូរកម្លាំងចុះឡើងលោកស្រី? ឧទាហរណ៍ថាពេលមុន លោកស្រីបញ្ជូនមក

៥០ ហើយ៥០ឡើងទៅ ដូរ៥០មកវិញ ឬក៏៥០ហ្នឹងនៅជាប់រហូត?

[១៤:២៧:៤៥]

**ធ៖** ចាស អារឿងកម្លាំងហ្នឹងគេដោះដូរ។ ដូចថាចំនួនថាគេឲ្យប៉ុន្មានខែ ប៉ុន្មានខែគេត្រូវដូរម្តង។ គេដូរពីវ័យកណ្តាលទៅ រហូតដល់វ័យជំទង់ -- អ៎ មិនមែនជំទង់ទេ អាយុ១៧, ១៨ហ្នឹង។ ហើយគេផ្លាស់ប្តូរគ្នាដែរ មិនមែនតែដូរកម្លាំងហ្នឹងទៅ ដូរកម្លាំងទៅទំនប់១មករាទៅ គេយកកម្លាំងទំនប់១មករាហ្នឹង យកមកធ្វើទំនប់តាមស្រុកវិញ ចាស។

**ស៖** អរគុណលោកស្រី។ ហើយពីព្រឹកមិញនេះទៀត លោកស្រីបានបញ្ជាក់នៅមុខអង្គជំនុំសវនាការថា នៅក្នុងការដ្ឋាននេះក៏មានការបាត់ខ្លួនដែរ ទាំងអ្នក១៧មេសា ទាំងអ្នកមូលដ្ឋាន។ ខ្ញុំចង់ឲ្យលោកស្រីបញ្ជាក់ដែរថា តើកម្លាំងដែលស្រុករបស់លោកស្រីបញ្ជូនមក មានការបាត់ខ្លួនទេ លោកស្រី?

**ធ៖** ចាស អាការបញ្ជូនទៅ មានការបាត់ខ្លួនដែរ មិនមែនថាប្រជាជនថ្មី ឬក៏ប្រជាជនចាស់ទេ ប៉ុន្តែខ្ញុំសួរគេ គេថា គេបញ្ជូនឲ្យទៅរៀន អ៊ីចេះ។

**ស៖** ប៉ុន្តែការដែលថាទៅរៀនសូត្រហ្នឹង មានដែលបានត្រឡប់មកវិញទេ លោកស្រី?

**ធ៖** ចាស បញ្ជូនទៅរៀន ទាល់ខ្លះក៏ឃើញត្រឡប់មក ប៉ុន្តែខ្លះគេថាបញ្ជូនទៅនៅស្រុកផ្សេង។

[១៤:២៩:៤៤]

**ស៖** អរគុណលោកស្រី។ ពេលដែលលោកស្រីនៅការដ្ឋាននោះ តើលោកស្រីមានបានសង្កេតឃើញសភាពពលករដែលនៅទីនោះទេ យ៉ាងម៉េចដែរ? គាត់មានទឹកមុខសប្បាយរីករាយ ឬគាត់ស្គមគាត់ធាត់អីយ៉ាងម៉េចដែរ សុខភាពគាត់អីយ៉ាងម៉េចដែរលោកស្រីមានសង្កេតឃើញយ៉ាងម៉េចដែរពលករដែលនៅទីនោះ ចាស?

**ធ៖** ចាស ជាធម្មតាមិនជាស្គម ហើយក៏មិនជាធាត់ ព្រោះគាត់ធ្វើការហត់ ហើយការជីវភាពវាមានត្រឹមតែបាយ បបរ ម្ហូបមិនខ្វះទេ គេបញ្ជូនមកពីទន្លេសាបយកមកឲ្យហូប។ ប៉ុន្តែថាឲ្យជីវភាពដូចយើងសព្វថ្ងៃវាមិនមានទេ ព្រោះគ្មានផ្លែឈើ គ្មានស្ករដូចផ្គត់ផ្គង់ទេ។ មានតែស្ករ ហើយធ្វើអីហូបខ្លួនឯងទៅ ហើយមានអង្ករ មានត្រីងៀត។ ខ្ញុំសង្កេតឃើញអ៊ីចឹង បើខ្ញុំទៅតែមួយភ្លែតៗ ដូចអាចមើលឃើញមួយជ្រុងៗ វាមិនបានឃើញទាំងអស់ទេ។

**ស៖** អរគុណលោកស្រី។ ខ្ញុំចង់ឲ្យលោកស្រីបញ្ជាក់ដែរ ព្រោះលោកស្រីនៅៗលើពីកន្លែងពីការដ្ឋានផ្ទាល់ លោកស្រីមានបានឃើញថា តើនៅក្នុងការសាងទៅទំនប់ហ្នឹង គេប្រើគ្រឿងចក្រជំនួយ

ដែរ ឬក៏ដោយកម្លាំងមនុស្សសុទ្ធ?

[១៤:៣១:១៥]

**ផ៖** ចាស ខ្ញុំជម្រាបថា ខ្ញុំមិនបានទៅនៅកន្លែងហ្នឹងឋិតថេរទេ ខ្ញុំទៅតែម្ដងៗ។ ប៉ុន្តែកម្លាំងដែលថាអង្គាល់នុ៎ង វាអត់មានជំនួយដោយជាអាត្រាក់ ឬក៏អីទេ មានតែកម្លាំងស្មាបងប្អូនសហករណ៍ទាំងអស់វែកពន់ទៅតាមហ្នឹងទៅ តែកម្លាំងគ្រឿងចក្រ គ្រឿងយន្តអីអត់ទាន់មានទេ។ ក្រោយមកបានមាន។

**ស៖** អរគុណលោកស្រី។ ខ្ញុំចង់ឲ្យលោកស្រីបំភ្លឺចំពោះមុខតុលាការដែរ ចុះចំពោះពេលម៉ោងធ្វើការលោកស្រី ពេលម៉ោងធ្វើការគេចាប់ធ្វើពីម៉ោងប៉ុន្មានទៅម៉ោងប៉ុន្មាន ហើយល្ងាចពីម៉ោងប៉ុន្មានហើយមានពេលសម្រាកដែរអត់?

**ផ៖** ចាស ពេលព្រឹកហូបស្រួបស្រស់អី ឬក៏ពេលខ្លះក៏បានហូប ពេលខ្លះក៏ទៅពីព្រឹកដែរ។ ដល់ម៉ោងយើង – កាលនោះដូចគ្មានម៉ោង ខ្ញុំក៏គ្មានម៉ោងមើលដែរ ដូចថាមិនដឹងជាម៉ោងប៉ុន្មាន ទាល់តែស្មាន ឥឡូវប្រហែលជាម៉ោងប្រាំពីរអីហ្នឹងចេញទៅធ្វើការ។ ហើយល្ងាចម៉ោងប្រាំ យើងថាម៉ោងប្រាំចុះបើថ្ងៃលិច ទៅថាម៉ោងប្រាំចុះ។

**ស៖** ក្រោយពីការបញ្ចប់ការងារហើយ តើមានការប្រជុំជីវភាពទេលោកស្រីនៅតាមក្រុម និងទៅតាមកងនីមួយៗ?

[១៤:៣៣:០៤]

**ផ៖** ចាស កន្លែងហ្នឹងដូចជាអត់បានប្រជុំឲ្យនេះទេ កាលដូចថា ទេត្រង់ហ្នឹងដូចជាខ្ញុំភ្លេចដែរ ព្រោះដល់ពេលនេះ គេរំសាយអស់តែម្ដងទៅ។ ខ្ញុំក៏ក្ដាប់ៗមិនបាន ហើយម្យ៉ាងពន្យារពេលយូរដែរ ខ្ញុំក្ដាប់មិនជាប់ទេ ព្រោះវិញ្ញាណរបស់ខ្ញុំវាតិចទៅហើយ។ ស្ដាប់វាអត់ទាន់ អ៎! អត់នែដឹងថា ពេលគេប្រជុំស្រាប់តែពេលរួចហើយរំសាយអស់ទៅតែម្ដងទៅ អត់ដឹងថា ម៉េចទៀត ខ្ញុំអត់ដឹងដែរ។

**ស៖** អរគុណលោកស្រី។ ខ្ញុំចង់ឲ្យលោកស្រីបញ្ជាក់មួយចំណុចថែមទៀត គឺផែនការដែលពលករម្នាក់ៗ។ តើផែនការរបស់អង្គការមានកំណត់ឲ្យធ្វើដោយវាស់ម៉ែត្រគូប ឬក៏ឲ្យធ្វើជាធម្មតា ធ្វើជាទូទៅលោកស្រី ឬក៏គិតថា ម្នាក់ប៉ុន្មានម៉ែត្រគូបអីអីចឹង?

**ផ៖** ចាស ដល់ពេលល្អិតអីចឹង ខ្ញុំក៏ក្ដាប់អត់បានដែរ ព្រោះខ្ញុំអត់បានថា ទៅរៀបចំខាងកិច្ចការហ្នឹង ខ្ញុំមិនដឹងថាគេវាស់គូប ឬគេកាប់តាមដំណើររបស់គេទៅ ខ្ញុំអត់ដឹងដែរ។ វាដល់ពេលល្អិតទៅ ខ្ញុំរក

ក្តាប់អត់បានទេ ត្រង់ថាវាស់ក្នុងម្នាក់ត្រូវវាស់ប៉ុន្មានម៉ែត្រ ៗខ្ញុំអត់ចុះជាប់ទេកន្លែងហ្នឹង ព្រោះខ្ញុំអត់ដឹងថាខ្ញុំអត់ដឹងហើយ។

[១៤:៣៤:៤៤]

**ស៖** អរគុណលោកស្រី។ ខ្ញុំសូមឆ្លងទៅប្រធានបទមួយទៀត មុននឹងឆ្លងទៅខ្ញុំសូមអានចម្លើយរបស់លោកស្រីនៅចំពោះមុខសហចៅក្រមស៊ើបអង្កេត ដែលមាន ERN 00348832 ជាភាសាខ្មែរ និងជាភាសាអង់គ្លេស 00360115, ជាភាសាបារាំង 00367808 ដែលលោកស្រីបាននិយាយថា ខ្ញុំឃើញនៅពេលនោះវត្តអារាមត្រូវគេយកធ្វើជាមន្ទីរពេទ្យ ហើយចំពោះព្រះសង្ឃត្រូវបានគេចាប់ផ្សឹក និងធ្វើការបណ្តេញចេញពីវត្ត។ ខ្ញុំចង់ឲ្យលោកស្រីបញ្ជាក់ដែរថា តើព្រះសង្ឃដែលគេផ្សឹកហ្នឹង គេបញ្ជូនទៅណាដែលលោកស្រី? ហើយហេតុអ្វីបានជាខ្មែរក្រហមលុបបំបាត់សាសនា?

**ឆ៖** ចាស ពេលនោះ ខ្ញុំនៅក្នុងព្រៃមិនទាន់បានមកនៅស្រុកគេទេ។ ដល់ពេលខ្ញុំមក វាដូចជាឆ្នាំប៉ុន្មាន ខ្ញុំភ្លេចបាត់ឆ្នាំហើយ។ មកគេរៀបចំអ៊ីចឹង ឃើញវត្តអត់មានលោក ហើយត្រង់ថាលោកហ្នឹងគេផ្សឹកហើយ គេឲ្យទៅណា ក៏ខ្ញុំក្តាប់អត់បាន។ ហើយលោកដែលត្រូវគេបណ្តេញចេញ ក៏ខ្ញុំក្តាប់អត់បាន ព្រោះខ្ញុំនៅព្រៃ មិនទាន់បានមកដល់ស្រុកទេ។

**លោកស្រី ជេត វណ្ណលី៖**

អរគុណលោកស្រី។ អរគុណចំពោះការបំភ្លឺរបស់លោកស្រី។ ដោយពេលវេលាយើងខ្ញុំមានកំណត់ យើងខ្ញុំសូមជូនវេទិកានេះ ជូនសហភាគអន្តរជាតិ។ សូមអរគុណ។

[១៤:៣៦:៣០]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ សូមអញ្ជើញមេធាវីនាំមុខអន្តរជាតិ!

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

**ស៖** ជម្រាបសួរលោកស្រីសាក្សី ខ្ញុំឈ្មោះ ម៉ារី ហ្គីរ៉ូដ៍។ ខ្ញុំជាមេធាវីតំណាងឲ្យក្រុមដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿងនេះ។ ខ្ញុំមានសំណួរខ្លីៗមួយចំនួនដើម្បីសួរពាក់ព័ន្ធទៅនឹងទំនប់១មករា។ បន្ទាប់មកទៀត ខ្ញុំនឹងសួរពាក់ព័ន្ធទៅនឹងការរៀបអាពាហ៍ពិពាហ៍ក្នុងអំឡុងកម្ពុជាប្រជាធិប

តេយ្យ។ ចំពោះពលករដែលធ្វើការនៅទំនប់១មករា លោកស្រីបានពន្យល់ជូនសហភាតារបស់ខ្ញុំថា មានការផ្លាស់វេនគ្នា ហើយមេឃុំជាអ្នកជ្រើសរើសពលករដែលចេញទៅធ្វើការនៅទំនប់១មករា ហើយប៉ុន្មានខែក្រោយមកទៀត កម្មករទាំងអស់ហ្នឹងចូលមក -- ត្រឡប់មកវិញ ហើយគេចាត់តាំងឲ្យធ្វើការងារផ្សេង។ ខ្ញុំចង់ដឹងថាតើការផ្លាស់វេនគ្នាកម្មករហ្នឹងគេធ្វើយ៉ាងម៉េច? លោកស្រីធ្លាប់ឃើញពលករហ្នឹងត្រឡប់ទៅភូមិវិញទេ ក្រៅពីរយៈពេលដែលផ្លាស់វេនគ្នាហ្នឹង?

[១៤:៣៨:០០]

**លោកស្រី ស៊ូ សឿន៖**

**ឆ៖** ចាស ដល់ពេលគេដកកម្លាំងត្រឡប់ទៅវិញ គេដូរ ហើយគេត្រៀម។ មុននឹងដកកម្លាំងគេត្រៀមកម្លាំងថ្មី ត្រូវរើសចំនួនប៉ុន្មាន យកទៅដូរនឹងអ្នកមកពីនោះវិញ។ ដឹងថាមកហើយអ្នកចាស់ដែលមកពីទំនប់១មករា មកលើកទំនប់នៅស្រុកចំការលើ។

**ស៖** អ៊ីចឹងតាមរយៈចម្លើយរបស់លោកស្រីហ្នឹង គឺថាគេដកមនុស្សចេញពីការដ្ឋាន១មករាហ្នឹងយកទៅដាក់នៅការដ្ឋានផ្សេងទៀត។ តើអ៊ីចឹងមែនទេ?

**ឆ៖** ចាស យកមកដាក់នៅចំការលើ រៀបចំលើកទំនប់ លើកប្រឡាយ លើកទំនប់ភ្លោះប្រឡាយ បង្ហូរយកទឹកដើម្បីចិញ្ចឹមប្រជាជនធ្វើស្រូវ ស្រែ។

**ស៖** សូមអរគុណ។ ចុះអ្នកឈឺមានត្រឡប់ទៅភូមិដើម្បីសម្រាកទេ ឬក៏គេបញ្ជូនទៅមន្ទីរពេទ្យ?

**ឆ៖** ចាស ត្រង់ហ្នឹង ខ្ញុំក្តាប់អត់បានទេ ព្រោះតាមបើស្រុកខ្ញុំ ខ្ញុំក្តាប់បាន តែអ្នកឈឺគេបញ្ជូនទៅមន្ទីរពេទ្យ។ ឯកន្លែង ក្នុងកន្លែងធ្វើការនៅទំនប់១មករា ហ្នឹងខ្ញុំក្តាប់អត់បានទេ។

[១៤:៤០:០១]

**ស៖** នៅសម័យនោះ លោកស្រីនៅស្រុក តើលោកស្រីធ្លាប់ឃើញអ្នកឈឺនៅការដ្ឋាន ហើយត្រឡប់មកភូមិផ្សេងៗ ឬក៏ឃុំផ្សេងៗនៅក្នុងស្រុករបស់លោកស្រីទេ? លោកស្រីមានចាំទេថាមានអ្នកឈឺហើយ គេបញ្ជូនមកឲ្យនៅភូមិវិញ?

**ឆ៖** ចាស ខ្ញុំចាំថាកម្លាំងដែលឈឺនៅទំនប់១មករា គេបញ្ជូនមកមន្ទីរពេទ្យ ដល់ជាហើយមកសហករណ៍វិញ។ ខ្ញុំក្តាប់បានប៉ុណ្ណឹង។

**ស៖** សូមអរគុណ។ មូលហេតុដែលខ្ញុំសួរសំណួរនេះ ពីព្រោះថាក្នុងសប្តាហ៍នេះ មុននេះបន្តិច

ហ្នឹង យើងស្ដាប់ចម្លើយរបស់ដើមបណ្ដឹងរដ្ឋប្បវេណីមួយរូបដែលបានធ្វើការ៣ខែនៅទំនប់១មករា គាត់មកពីស្រុកព្រៃកប្រសព្វ ជាស្រុកផ្សេងពីលោកស្រី ហើយគាត់បានពន្យល់ថាអ្នកឈឺត្រឡប់មកភូមិវិញដើម្បីសម្រាក។ ហើយគឺគេពន្យល់ប្រាប់អ្នកធ្វើការនៅទីនោះគឺអ៊ីចឹង។ អ៊ីចឹងនៅក្នុងស្រុករបស់លោកស្រី គឺថាអ្នកឈឺហ្នឹងមិនមែនមកសម្រាកនៅភូមិទេ គឺគេបញ្ជូនទៅឲ្យព្យាបាលនៅមន្ទីរពេទ្យ។ គឺអ៊ីចឹងតាមរយៈចម្លើយរបស់លោកស្រីហ្នឹង គឺមានន័យថាអ៊ីចឹងមែនទេ?

**ឆ៖** ចាស មានអ៊ីចឹងមែន ប៉ុន្តែអ្នកឈឺធ្ងន់គេយកពីទំនប់១មករាមក យកទៅដាក់មន្ទីរពេទ្យកំពង់ចាម។ ដល់ពេលជាត្រឡប់មកធ្វើការនៅសហករណ៍វិញ។ អាហ្នឹងតាមខ្ញុំចាំអ៊ីចឹង។

[១៤:៤២:០០]

**ប្រធានអង្គជំនុំ៖**

អរគុណ។ បាទ ដល់ពេលសមស្របនឹងសម្រាកហើយ ប៉ុន្តែមុននឹងសម្រាក អង្គជំនុំជម្រះសូមសួរទៅលោកមេធាវី វ៉ិចទ័រ កូប៉េ កាលដែលលោកស្នើសុំដាក់សារណាផ្ទាល់មាត់ពាក់ព័ន្ធជាមួយនឹងការដាក់បង្ហាញឯកសាររបស់សហព្រះរាជអាជ្ញារងអន្តរជាតិកាលពីព្រឹកមិញ ហើយនិងបញ្ហាពាក់ព័ន្ធនឹងបញ្ហានេះដែរ ដែលទាក់ទងទៅនឹងបណ្ដឹងសាទុក្ខប្រឆាំងនឹងសាលក្រម០០២/០១នោះ តើលោកត្រូវការពេលវេលាទំនងប្រហែលជាប៉ុន្មានក្នុងការធ្វើសារណាផ្ទាល់មាត់នេះ ដើម្បីអង្គជំនុំជម្រះរៀបចំនូវកាលពេលវេលាសមស្របសម្រប់ធ្វើកិច្ចការនេះនៅចុងម៉ោងនៅរសៀលនេះ?

**លោក វ៉ិចទ័រ កូប៉េ៖**

លោកប្រធាន ខ្ញុំគិតថាប្រហែលជាពីរបីនាទីតែប៉ុណ្ណោះ។ ខ្ញុំគ្រាន់តែបង្ហាញពីការព្រួយបារម្ភរបស់ខ្ញុំទាក់ទងទៅនឹងការបង្ហាញឯកសារ ជាពិសេសផ្នែកបន្ទាប់នៅក្នុងសវនាការរបស់យើង គឺព្រលានយន្តហោះកំពង់ឆ្នាំង។ ដូច្នេះខ្ញុំគិតថាយ៉ាងច្រើនបំផុតគឺគ្រប់គ្រាន់បំផុតគឺ៥នាទីប៉ុណ្ណោះ លោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ឥឡូវនេះដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅរហូតដល់ម៉ោងបី សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្ដល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី និងអ្នកជំនាញដល់សាក្សីរូបនេះនៅក្នុងអំឡុងពេលឈប់សម្រាក និងឲ្យអញ្ជើញគាត់រួមទាំងបុគ្គលិកអង្គការធី.ភី.អូ មកកាន់កន្លែងផ្ដល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះនៅវេលាម៉ោងបី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១៤:៤៤ នាទី ដល់ម៉ោង ១៥:០១ នាទី)*

[១៥:០១:៣៩]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ហើយនិងផ្តល់វេទិកាជូនទៅសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីមានឱកាសចុងក្រោយ ក្នុងការតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ។

**លោកស្រី ម៉ារី ហ្គីរ៉ូដ៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោកស្រី ម៉ារី ហ្គីរ៉ូដ៖**

**ស៖** ជម្រាបសួរលោកស្រីសាក្សី។ អម្បាញ់មិញនេះ មុនពេលឈប់សម្រាក យើងនិយាយពីបញ្ហាអ្នកជំងឺឈឺ សុំទោសអ្នកកម្មករឈឺ ហើយនិងមន្ទីរពេទ្យ ហើយលោកស្រីថា អ្នកដែលឈឺនៅការដ្ឋានហ្នឹង គេមិនបញ្ជូនមកភូមិទេ គឺគេបញ្ជូនទៅមន្ទីរពេទ្យ។ ខ្ញុំចង់ឲ្យលោកស្រីឆ្លើយតបទៅនឹងសក្ខីកម្មមួយដែលយើងបានស្តាប់ប៉ុន្មានថ្ងៃមុននេះ គឺដើមបណ្តឹងរដ្ឋប្បវេណីដែលមកពីបារាយណ៍។ គាត់បានរៀបរាប់អំពីមន្ទីរពេទ្យមួយ អ៊ីចឹងខ្ញុំចង់ដឹងថា តើការរៀបរាប់មន្ទីរពេទ្យហ្នឹង វាដូចគ្នាទៅនឹងមន្ទីរពេទ្យដែលមាននៅក្នុងស្រុករបស់លោកស្រីដែរឬទេ? គឺប្រតិចារឹកថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១៥ គឺលោកស្រី សិត្ថានី គឺនៅម៉ោងប្រាំបួន គាត់បានរៀបរាប់អំពីមន្ទីរពេទ្យមួយ ដែលបងប្រុសរបស់គាត់សម្រាកនៅទីនេះ ហើយ៣ថ្ងៃក្រោយមកស្លាប់។

[១៥:០៣:១៣]

គាត់បានរៀបរាប់ដូចតទៅ៖ “មន្ទីរពេទ្យជាសាលារៀនចាស់ ហើយចាស់ទ្រុឌទ្រោម គេមិនមានសង់អំពីថ្មទេ។ អ្នកឈឺត្រូវបញ្ជូនពីបារាយណ៍មកមន្ទីរពេទ្យនេះ។ អ្នកជំងឺត្រូវបានបញ្ជូនទៅមន្ទីរពេទ្យ ហើយអ្នកជំងឺ ហើយនិងអ្នកមើលជំងឺហ្នឹង គឺស្គមមែនទែន សុខភាពមិនល្អទេ”។ ហើយបន្ទាប់

មកនៅម៉ោងដប់ មួយនាទី គាត់បាននិយាយថា៖ "នៅសម័យនោះ គឺជាសាលារៀនដែលគេធ្វើពីឈើ ពីក្តារ ដំបូលគឺប្រក់ស្លឹក។ ហើយដូចដែរខ្ញុំបាននិយាយអ៊ីចឹង គឺថាមិនមានសភាពអីល្អទេ ហើយមានអ្នកជំងឺជាច្រើននៅលើគ្រែ ហើយបើអត់មានគ្រែគ្រប់ទេ គឺអ្នកជំងឺខ្លះដេកនៅផ្ទាល់ដី។" អ៊ីចឹងលោកស្រីសាក្សី តើការដែលខ្ញុំបានរៀបរាប់អម្បាញ់មិញនេះ គឺវាត្រូវគ្នានឹងស្ថានភាពនៅមន្ទីរពេទ្យនៅស្រុករបស់លោកស្រីទេ?

**លោកស្រី ស៊ូ សឿន៖**

**ឆ៖** ចាស ខាងផ្នែក ខាងបារាយណ៍ ខ្ញុំមិនដឹងទេ ប៉ុន្តែខាងផ្នែកខាងខ្ញុំ បើយកពីទំនប់១មករាមក គឺយកទៅដាក់មន្ទីរពេទ្យកំពង់ចាម គឺមន្ទីរពេទ្យថ្ម មិនមែនមន្ទីរពេទ្យនៅខ្ទម ឬអីទេ គឺផ្ទះថ្ម មន្ទីរពេទ្យថ្មគេ មានពីរជាន់ ពីរជាន់ទៅបីជាន់។ ដូច្នេះការព្យាបាល ក៏បងប្អូនខិតខំដែរ ប៉ុន្តែការសង្គ្រាមវាធម្មតា ជួនកាលវាមិនគ្រប់គ្រាន់នឹងថ្នាំសង្កូវបងប្អូនទេ។ ហ្នឹងតាមខ្ញុំដឹងខ្លះៗ។

**ស៖** សូមអរគុណ។ នៅចំពោះមុខសហចៅក្រមស៊ើបអង្កេត លោកស្រីបាននិយាយច្បាស់ជាងនេះ ពាក់ព័ន្ធទៅនឹងមន្ទីរពេទ្យក្នុងស្រុករបស់លោកស្រី។ ខ្ញុំសូមយោងទៅលើឯកសារ E3/5294 ERN ជាភាសាខ្មែរ 00348834, ជាភាសាអង់គ្លេស 00360117, ជាភាសាបារាំងគឺ 00367810។ លោកស្រីបានពន្យល់ថា៖ "មានមន្ទីរពេទ្យនៅស្រុក និងនៅតាមឃុំនីមួយៗមានមន្ទីរពេទ្យដែរ។" អ៊ីចឹងខ្ញុំចង់ដឹងថា តើមន្ទីរពេទ្យឃុំ ហើយនិងមន្ទីរពេទ្យស្រុកហ្នឹង មានលក្ខណៈខុសគ្នាទេ?

[១៥:០៦:០៥]

**ឆ៖** ចាស មន្ទីរពេទ្យស្រុក វាគ្រាន់ថាជីវភាពវាខ្ពស់បន្តិច ត្រង់មានថ្នាំសង្កូវវាអាច មិនសម្បូរទេប៉ុន្តែវាអាចព្យាបាលបងប្អូនបាន។ មន្ទីរពេទ្យតាមឃុំ យើងមើលតាមពេទ្យសហករណ៍នីមួយៗ គឺមើលតាមលទ្ធភាព។ លទ្ធភាពដែលមានថ្នាំ ក៏យើងមើលអ្នកជំងឺល្មមៗ ក៏ជាទៅ។ ឯណាខ្លាំងក៏គេបញ្ជូនមកស្រុក ឯខ្លាំងក៏បញ្ជូនទៅកំពង់ចាម។ ខ្ញុំសូមជម្រាប។

**ស៖** សូមអរគុណ។ មុននេះបន្តិចលោកស្រីបាននិយាយអំពីមន្ទីរពេទ្យមួយនៅក្នុងវត្ត ហើយអម្បាញ់មិញនេះ ខ្ញុំនិយាយអំពីមន្ទីរពេទ្យនៅក្នុងសាលា។ អ៊ីចឹងតើនៅក្នុងឃុំ -- នៅក្នុងស្រុករបស់លោកស្រីហ្នឹងគឺថា មន្ទីរពេទ្យហ្នឹងគឺត្រូវបានរៀបចំឡើងនៅតាមវត្ត និងតាមសាលាដូចដែលបានលើកឡើងហ្នឹងមែនទេ?

**ឆ៖** ចាស មន្ទីរពេទ្យនៅស្រុកខ្ញុំ មិនបានធ្វើនៅនឹងវត្តទេ គឺធ្វើនៅតាមឃុំមួយ មិនៗធ្វើនៅក្នុង

មន្ទីរពេទ្យ -- ក្នុងវត្តទេ។ ដូចខ្ញុំជម្រាបអំមិញអ៊ីចឹងថា ធ្វើមន្ទីរពេទ្យមានស្រុកមានឃុំ មានសង្កាត់ ហ្នឹងតាមជីវភាព។ បើថាស្រុកទៅ វាដោះស្រាយតាមលទ្ធភាពវាគួរសម។ ឯតាមឃុំ វាខ្សត់បន្តិច យើងធ្វើតាមខ្សត់ទៅ។ កាលណាឈឺខ្លាំង យើងបញ្ជូនមកស្រុក ខ្លាំងមែនទែនយើងបញ្ជូនទៅកំពង់ចាម។ ខ្ញុំបានបញ្ជាក់អ៊ីចឹងហើយ។

[១៥:០៨:៣០]

**ស៖** សូមអរគុណ។ អម្បាញ់មិញនេះ ខ្ញុំបានអានឱ្យលោកស្រីស្ដាប់អំពីការរៀបរាប់របស់ដើមបណ្ដឹងរដ្ឋប្បវេណីមួយរូបដែលគាត់និយាយថា ទាំងអ្នកជំងឺទាំងអ្នកមើលថែអ្នកជំងឺហ្នឹង គឺស្គមស្គាំងហើយមានសុខភាពមិនល្អទេ។ អ៊ីចឹងលោកស្រីពេលសម័យហ្នឹង មានសង្កេតឃើញថា នៅតាមមន្ទីរពេទ្យស្រុក ឬមន្ទីរពេទ្យឃុំហ្នឹងមានលក្ខណៈដូចដែលដើមបណ្ដឹងរដ្ឋប្បវេណីរូបនោះ គាត់បានរៀបរាប់ទេ?

**ឆ៖** ចាស ខាងស្រុកខ្ញុំ វាមានមិនដល់មានថ្នាក់ប៉ុណ្ណឹងទេ ព្រោះខាងចំការលើវាសម្បូរហូបដែរ។ សហករណ៍មួយៗក៏មិនសូវខ្វះ ឯផ្លែចេកផ្លែអី ក៏មានគួរសម។ ឯស្រុកគេផ្សេងខ្ញុំអត់ដឹងទេ ដឹងតែស្រុកខ្ញុំ សហករណ៍ខ្ញុំៗដឹង។

**ស៖** សូមអរគុណ។ នៅពេលដែលលោកស្រីឆ្លើយនៅចំពោះមុខសហចៅក្រមស៊ើបអង្កេត លោកស្រីបានលើកឡើងអំពីទស្សនកិច្ចរបស់លោកស្រី អៀង ធីរិទ្ធ ដែលបានយើងបាននិយាយពីព្រឹកមិញនេះ។ ហើយនៅក្នុងឯកសារដដែលគឺ E3/5294 នៅ ERN ដដែលដូចអម្បាញ់មិញ លោកស្រីបានឆ្លើយថា លោកស្រីបានចុះទៅមើលមន្ទីរពេទ្យជាមួយលោកស្រី អៀង ធីរិទ្ធ ហើយនៅពេលនោះគេសួរសំណួរ៖ "ថាតើលោកស្រី អៀង ធីរិទ្ធ ដឹងអំពីការខ្វះខាតថ្នាំនៅតាមមន្ទីរពេទ្យដែរឬទេ?" លោកស្រីឆ្លើយថា៖ "គាត់ដឹង ពេលគាត់ទៅវិញ គាត់បញ្ជូនថ្នាំ ហើយនិងសម្ភារៈផ្សេងៗមកឱ្យយើង"។ តើលោកស្រីអាចពន្យល់បានទេថា តើថ្នាំប្រភេទណាខ្លះដែលមន្ទីរពេទ្យនៅក្នុងស្រុកលោកស្រីហ្នឹងខ្វះខាត? លោកស្រីអាចរៀបរាប់លម្អិតបន្តិចពាក់ព័ន្ធទៅនឹងការខ្វះខាតថ្នាំបានទេ?

**ឆ៖** ចាស រឿងថ្នាំហ្នឹង គឺខ្ញុំមិនអាចស្គាល់អស់ទេ។ ប្រើភាគច្រើន ព្រោះយើងនៅជនបទ ភាគច្រើន ៗតែថ្នាំគ្រុនចាញ់ ហើយនិងថ្នាំគ្រុនក្ដៅ និងថ្នាំបញ្ចុះកម្ដៅ និងថ្នាំគ្រុនចាញ់។ ក្រៅពីហ្នឹង គឺខ្ញុំភ្លាប់ដូចថាថ្នាំហ្នឹង វាមិនស្គាល់ថ្នាំ មិនស្គាល់ថ្នាំអី ព្រោះខ្ញុំមិនស្គាល់យីហោថ្នាំទេ។

[១៥:១១:១៤]

**ស៖** សូមអរគុណលោកស្រី។ តើលោកស្រីចាំទេថា មានមនុស្សស្លាប់ច្រើនទេ នៅមន្ទីរពេទ្យស្រុក និងមន្ទីរពេទ្យឃុំ?

**ឆ៖** ចាស កន្លែងខ្លះ យើងអាចសង្គ្រោះមិនបាន បងប្អូនក៏មានការគ្រោះថ្នាក់ដែរ។ កន្លែងខ្លះយើងមានលទ្ធភាពជួយសង្គ្រោះបងប្អូនបាន យើងយកទៅមន្ទីរពេទ្យខេត្ត ក៏បងប្អូនមិនគ្រោះថ្នាក់អីទេ។

**ស៖** សូមអរគុណ។ ខ្ញុំឈប់សួរពីបញ្ហាមន្ទីរពេទ្យនេះហើយ ខ្ញុំចូលទៅប្រធានបទថ្មី។ ខ្ញុំចង់សួរលោកស្រីអំពីការរៀបអាពាហ៍ពិពាហ៍នៅក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ គឺនៅក្នុងស្រុករបស់លោកស្រីផ្ទាល់តែម្តង ដែលលោកស្រីស្ថិតនៅក្នុងគណៈស្រុក។ តើលោកស្រីមានបានទទួលការណែនាំពីថ្នាក់លើពាក់ព័ន្ធទៅនឹងការរៀបចំអាពាហ៍ពិពាហ៍នៅក្នុងស្រុករបស់លោកស្រីនៅសម័យនោះទេ?

**ឆ៖** ចាស ក្នុងពេលនោះ មានរៀបចំអាពាហ៍ពិពាហ៍មាន។ ខាងប្រធាន ខាងសង្កាត់ក៏គេសួរទៅសាមីខ្លួនខាងស្រី សាមីខ្លួនខាងប្រុស បើថាយល់ព្រមហើយ ក៏គេរៀបចំធ្វើពិធី មិនមានពិធីអីធំដុំទេ។ ពិធីគ្រាន់តែមានការរៀបចំហូបចុកអីតិចតួចទៅ ហើយឧទ្ទេសនាមរៀងខ្លួនទៅ ហើយខាងប្រធានខាងស្រុកក៏មានមតិផ្តាំផ្ញើទៅ ហើយខាងសាមីខ្លួនក៏ចាប់អារម្មណ៍រៀងខ្លួន។ ចាស មានប៉ុណ្ណឹង។

[១៥:១៣:៣៧]

**ស៖** តើស្រុកមានចូលរួមពាក់ព័ន្ធនៅក្នុងការរៀបអាពាហ៍ពិពាហ៍ហ្នឹងទេ?

**ឆ៖** ចាស កន្លែងខ្លះក៏ស្រុកចុះទៅជាប់ដែរ កន្លែងខ្លះសង្កាត់គេអ្នករៀបចំ។ ទៅធ្វើតាមសង្កាត់សង្កាត់គេរៀបចំទៅ។ កន្លែងខ្លះ មានប្រធានស្រុកទៅចូលរួមដែរ។

**ស៖** សូមអរគុណ។ ខ្ញុំចង់ឲ្យលោកស្រីឆ្លើយតបទៅនឹងសក្ខីកម្មមួយចំនួនដែលយើងបានស្តាប់ក្នុងរយៈពេលកន្លងមកនេះ គឺអ្នកដែលមានទទួលទំនួលខុសត្រូវស្រដៀងលោកស្រីដែរ គឺនៅស្រុកត្រាំកក់។ គាត់ជាលេខា ឬក៏ជាគណៈស្រុក។ គាត់បានឆ្លើយពាក់ព័ន្ធទៅនឹងការរៀបអាពាហ៍ពិពាហ៍នៅក្នុងសវនាការនេះ។ ខ្ញុំចង់ដកស្រង់ចម្លើយរបស់គាត់ ហើយឲ្យលោកស្រីឆ្លើយតប ថាតើនៅក្នុងស្រុករបស់លោកស្រីហ្នឹង ធ្វើដូចនៅស្រុករបស់សាក្សីរូបនោះដែរឬទេ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប!

សូមអញ្ជើញលោកមេធាវី វ៉ិចទ័រ កូប៉េ!

[១៥:១៥:០៤]

**លោក វិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំជំទាស់ទៅនឹងការសាកសួរបែបនេះ។ ដើមបណ្ដឹង -- មេធាវីដើមបណ្ដឹងរដ្ឋប្បវេណីកំពុងតែបង្ហាញសក្ខីកម្មមកពីតំបន់ មកពីភូមិភាគផ្សេង ហើយសាក្សីនេះអាចផ្ដល់សក្ខីកម្មតែទៅលើអ្វីដែលកើតឡើងនៅក្នុងភូមិភាគរបស់គាត់តែប៉ុណ្ណោះ។ គាត់មិនអាចផ្ដល់សក្ខីកម្មទាក់ទងទៅនឹងអ្វីដែលកើតឡើងនៅកម្រិតថ្នាក់ឃុំ ឬស្រុកនៅភូមិភាគនិរតីបាននោះឡើយ។

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

លោកប្រធាន គំនិតរបស់ខ្ញុំនេះ គឺមិនចង់ឲ្យគាត់ឆ្លើយតបទៅនឹងអ្វីដែលបានកើតឡើងនៅកន្លែងផ្សេងទេ គឺពាក់ព័ន្ធទៅនឹងស្រុករបស់គាត់។ អង្គជំនុំជម្រះទទួលបណ្ដឹងពាក់ព័ន្ធទៅនឹងការរៀបអាពាហ៍ពិពាហ៍នៅថ្នាក់ជាតិ។ ដូច្នេះ យើងអាចសួរថាតើការរៀបអាពាហ៍ពិពាហ៍ហ្នឹង គឺវាមានលក្ខណៈដូចគ្នា ឬក៏លក្ខណៈខុសគ្នាពីស្រុកមួយទៅស្រុក។ ដូច្នេះគោលបំណងនៃការសួរសំណួរនេះ គឺដើម្បីចង់ឲ្យសាក្សីរូបនេះ ឆ្លើយតបថា តើនៅក្នុងស្រុករបស់គាត់ដែលគាត់ជាអ្នកទទួលខុសត្រូវហ្នឹង គឺការរៀបអាពាហ៍ពិពាហ៍ហ្នឹង គឺវាប្រព្រឹត្តទៅដូចគ្នា ឬក៏ខុសគ្នាពីស្រុកត្រាំកក់ ដែលយើងបានស្ដាប់ឮរួចមកហើយនៅក្នុងសវនាការនោះ។ ដូច្នេះខ្ញុំគិតថា គំនិតរបស់ខ្ញុំហ្នឹង គឺថាវាមានភាពពាក់ព័ន្ធ ហើយនិងមានភាពចាំបាច់សម្រាប់សវនាការយើងនេះ។

[១៥:១៦:២៨]

*(ចៅក្រមពិភាក្សាគ្នា)*

[១៥:១៧:៤២]

**ប្រធានអង្គជំនុំ៖**

បាទ ហើយអង្គជំនុំជម្រះកត់សម្គាល់ឃើញថា ការជំទាស់របស់មេធាវីការពារក្ដីលោក នួន ជា ចំពោះការត្រៀមរៀបចំការតាំងសំណួររបស់សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី វាឆាប់រហ័សពេក។ ដោយសារយើងមិនទាន់បានស្ដាប់នូវសំណួរផង ហើយប្រសិនបើរង់ចាំស្ដាប់សំណួរសិនទៅ ហើយអង្គជំនុំជម្រះនឹងពិចារណាសម្រេចទៅតាមការជាក់ស្ដែង បើសិនជាមានការជំទាស់។

បាទ សូមអញ្ជើញលោកស្រីចៅក្រម អ៎! លោកស្រីមេធាវីអាចតាំងសំណួរបានហើយ!

**សួរដោយលោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

**ស៖** គឺខ្ញុំនឹងដកស្រង់នៅឃ្លាមួយនៃការស្ដាប់សក្ខីកម្មសាក្សីមួយរូប ដែលយើងបានស្ដាប់កាល

ពីប្រហែលជា១ខែមកហើយ។ គាត់មានទំនួលខុសត្រូវនៅក្នុងគណៈស្រុកត្រាំកក់។ ខ្ញុំសូមដកស្រង់នៅប្រតិចារឹក E1/291.1 គឺកំណត់ហេតុសវនាការនៅថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១៥ គឺប្រហែលជាម៉ោងប្រាំបួនប្រាំបីនាទី។ លោក ពេជ្រ ជឹម គឺជាសាក្សីដែលខ្ញុំនិយាយនេះ។ គាត់និយាយអំពីការរៀបចំអាពាហ៍ពិពាហ៍នៅក្នុងស្រុករបស់គាត់។ គាត់បានឆ្លើយដូចតទៅ៖ "តាមពិតទៅយើងពិភាក្សាគ្នានៅថ្នាក់ស្រុកអំពីការគ្រប់គ្រងទៅលើការរៀបអាពាហ៍ពិពាហ៍ និងការណែនាំរបស់ថ្នាក់ភូមិភាគ។ យើងគិតគោរពទៅលើការណែនាំ បើតាមការអនុវត្តនោះ គឺថាមានការខ្វះចន្លោះ មិនទាំងអស់គ្នាទេ ដែលព្រមរៀបអាពាហ៍ពិពាហ៍នោះ។ ដូច្នេះយើងៗត្រូវផ្តល់អំណាចមួយចំនួនទៅឲ្យខាងមេកងដើម្បីចាត់ចែងការរៀបការ។" ដូច្នេះសំណួរខ្ញុំ ខ្ញុំចង់ដឹងថា លោកស្រីសាក្សី ខ្ញុំទើបតែអាននូវសក្ខីកម្មរបស់សាក្សីមួយរូបដែលមានតួនាទីប្រហាក់ប្រហែលហ្នឹងលោកស្រីដែរ នៅស្រុកផ្សេង។ អ៊ីចឹងខ្ញុំចង់ដឹងថា នៅស្រុកព្រែកប្រសព្វហ្នឹង ការរៀបអាពាហ៍ពិពាហ៍ហ្នឹងវាប្រព្រឹត្តទៅដូចនៅស្រុកដែលខ្ញុំបានរៀបរាប់អម្បាញ់មិញហ្នឹងទេ?

[១៥:២០:០០]

**លោកស្រី ស៊ូ សឿន៖**

**ឆ៖** ចាស ខ្ញុំមិនមែននៅស្រុកព្រែកប្រសព្វទេ ខ្ញុំនៅស្រុកចំការលើ។ ពីមុនខ្ញុំនៅមែន ប៉ុន្តែខ្ញុំអត់ទាន់បានរៀបចំអាពាហ៍ពិពាហ៍ រឿងគូស្រករទេ។ តែក្រោយមក ខ្ញុំបានមកនៅចំការលើ១ឆ្នាំ ដូច្នេះការរៀបចំពិភាក្សាពីស្រុកមែន ប៉ុន្តែការរៀបចំសម្រេចត្រូវធ្វើពិធី គឺត្រូវធ្វើតាមសង្កាត់។ សង្កាត់នីមួយៗគេអាចធ្វើបានម្ចាស់ការ។ ដូច្នេះអារឿងស្រុកផ្សេង ខ្ញុំភ្លាប់អត់បានទេ។ ខ្ញុំភ្លាប់បានតែស្រុកខ្ញុំ ខ្ញុំធ្វើរបៀបគណៈកម្មការយ៉ាងម៉េច ខាងលើណែនាំយ៉ាងម៉េច ខ្ញុំធ្វើអ៊ីចឹង។ តែស្រុកផ្សេង ខ្ញុំអត់ភ្លាប់បានទេ យ៉ាងម៉េច ខ្ញុំភ្លាប់មិនបានទេ។

**ស៖** សូមអរគុណ។ នៅពេលដែលលោកស្រីនៅក្នុងគណៈស្រុក តើលោកស្រីធ្លាប់ទទួលបញ្ជីឈ្មោះអ្នកដែលត្រូវរៀបការ ដែលឃុំបញ្ជូនមកទេ?

**ឆ៖** ចាស បញ្ជីឈ្មោះអ្នករៀបចំជាគូស្រករ ខ្ញុំជម្រាបហើយជម្រាបទៀតថា ខ្ញុំមិនអាចអានអក្សរ សរសេរអក្សរបានទេ អាហ្នឹងសម្រេចលើប្រធានស្រុក គេអ្នករៀបចំ។ ខ្ញុំគ្រាន់តែស្តាប់តាមពេលនេះទៅគេនិយាយដូចថា យើងធម្មតាគេនិយាយប្រាប់ ដល់ពេលប្រជុំក៏គេនិយាយប្រាប់។ អាត្រង់បញ្ជីចំនួនមនុស្សដែលត្រូវរៀបចំប៉ុន្មាន បើថាប្រាំគូៗ បីគូៗ អាហ្នឹងគេនិយាយតែម្តង គេនិយាយប្រាប់

ថាអ៊ីចឹង។ តែខ្ញុំអត់បានមើលបញ្ជីគេកត់ ព្រោះខ្ញុំអត់ចេះអក្សរ។

[១៥:២២:០៩]

**ស៖** អ៊ីចឹងគឺមានបញ្ជី ក៏ប៉ុន្តែលោកស្រីមិនបានអានទេ ដោយសារតែលោកស្រីមិនចេះអាន នៅសម័យនោះ។ អ៊ីចឹងនៅសម័យនោះ តើគេអនុញ្ញាតឲ្យរៀបការរវាងអ្នកមូលដ្ឋាន និងអ្នកចាស់ទេ គឺថាគេអាចឲ្យប្តី – ឧទាហរណ៍ប្តីប្រពន្ធហ្នឹង ម្នាក់ជាអ្នកមូលដ្ឋាន ម្នាក់ជាអ្នកថ្មីហ្នឹង គេអាចអនុញ្ញាតឲ្យរៀបការទេ?

**ឆ៖** ចាស កន្លែងខ្លះក៏ ចាសខ្ញុំនិយាយតែអារឿងថាកន្លែងខ្លះ គឺស្រុកខ្ញុំវាមានខ្លះដែរ។ ការពាក់ព័ន្ធជាមួយគ្នា គេបានរៀបចំ ដូចស្នើទៅតាមសង្កាត់ សង្កាត់ឡើងមកស្រុកអ៊ីចឹងទៅ ហើយសម្រេចថាមនុស្សល្អ យើងរៀបចំឲ្យ។ មាន ប៉ុន្តែវាមានភាគតិច មិនមែនមានច្រើនទេ។

**ស៖** តើលោកស្រីដឹងអំពីការណែនាំរបស់ថ្នាក់លើថា មិនឲ្យអ្នកចាស់ហ្នឹងរៀបការជាមួយអ្នកថ្មី? លោកស្រីមានចាំទេថា មានថ្នាក់លើគេណែនាំមកទេថាមិនឲ្យអ្នកចាស់ហ្នឹងរៀបការជាមួយអ្នកថ្មីទេ?

**ឆ៖** ចាស រឿងហ្នឹងមិនមែនអ៊ីចឹងទេ។ គឺថាអ្នកចាស់និងអ្នកថ្មីនៅក្នុងសហករណ៍ គឺអ្នកធ្វើការទៅមានការទាក់ទង អ៊ីចឹងហើយគេប្រធានគេឃើញថា មនុស្សវាគួរសម គេរៀបចំឲ្យ។ តែខាងលើមិនមានណែនាំថា ដាច់ប៉ាត់រឿងអ្នកចាស់ និងអ្នកថ្មី មិនឲ្យទាក់ទង មិនឲ្យរៀបការ មិនមានទេ។ ខ្ញុំមិនបានទទួលពាក្យហ្នឹងទេ។ ទទួលតែពាក្យល្អ គឺថានៅក្នុងសហករណ៍ យើងធ្វើការពលកម្មល្អ គឺរៀបចំបាន។

[១៥:២៤:២៨]

**ស៖** សូមអរគុណ។ លោកប្រធាន ខ្ញុំមានសំណួរចុងក្រោយមួយទៀត។ ខ្ញុំនឹងដកស្រង់នូវចម្លើយរបស់ ពេជ្រ ជឹម ដែលគាត់មានឋានៈប្រហាក់ប្រហែលលោកស្រីនៅក្នុងគណៈស្រុក។ ហើយខ្ញុំនឹងសួរសំណួរលោកស្រី ថាតើមានការណែនាំពីថ្នាក់លើដែរឬទេ? គឺខ្ញុំសំដៅទៅលើឯកសារដដែលគឺ E1/291.1 គឺនៅថ្ងៃទី២៣ មេសា ២០១៥ គឺនៅពេលព្រឹក គឺមុនម៉ោងប្រាំបួន ប្រាំបីនាទីបន្តិច។ ពេលនោះគេសួរសំណួរគាត់ដូចតទៅ៖ “តើលោកដឹងអំពីការណែនាំពាក់ព័ន្ធនឹងការរៀបអាពាហ៍ពិពាហ៍ទេ?” សាក្សីគាត់ឆ្លើយថា៖ “ចំពោះការរៀបអាពាហ៍ពិពាហ៍ គឺមានការណែនាំមែន។ ខ្ញុំដឹងថាមានការណែនាំពីថ្នាក់លើ ហើយខ្ញុំស្គាល់ ខ្ញុំដឹងច្បាស់ ក៏ប៉ុន្តែការណែនាំហ្នឹងមិនមានជាច្បាប់ មិនមានជាមាត្រាអីពិត

ប្រាកដទេ វាគ្រាន់តែជាការអនុវត្តជារួម សម្រាប់ការអនុវត្តពីថ្នាក់លើរហូតទៅដល់ថ្នាក់មូលដ្ឋាន"។ ដូច្នេះលោកស្រីសាក្សី តើលោកស្រីដឹងអំពីការណែនាំ ឬក៏ការអនុវត្តពាក់ព័ន្ធទៅនឹងការរៀបអាពាហ៍ពិពាហ៍នេះ ដែលដាក់ចេញមកពីថ្នាក់លើទេ?

**ឆ៖** ចាស ការណែនាំរៀបចំ គឺខាងលើៗ ត្រឹមៗភូមិភាគចុះ ខាងលើហ្នឹងគឺណែនាំថា បើៗយើងទៅចំ -- ចង់រៀបចំជាគ្រួសារ ជាគូ ត្រូវរៀបប៉ុន្មាន ហើយត្រូវធ្វើយ៉ាងម៉េច។ ហ្នឹងមាន មិនមែនថាអត់ទេ ប៉ុន្តែបើពីលើមកដល់តំបន់ តំបន់មកដល់ស្រុក មកដល់ស្រុកមានន័យថាថ្នាក់ល្មម យើងទៅដល់សង្កាត់។ អាហ្នឹងរៀប -- វាតគ្នាពីលើដល់ក្រោម។ ការរៀបចំគឺអ៊ីចឹងមែន ការរៀបចំតាមថ្នាក់ការណែនាំពីលើមកតំបន់ តំបន់មកស្រុក ស្រុកចុះទៅសង្កាត់។ អានេះតាមខ្ញុំចាំខ្លះ គឺរៀបចំអ៊ីចឹង។

[១៥:២៧:០០]

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

សូមអរគុណលោកប្រធាន។ ខ្ញុំគិតថា ខ្ញុំអស់ពេលហើយ ខ្ញុំសូមបញ្ចប់ត្រឹមនេះ។ សូមអរគុណលោកស្រីសាក្សី ដែលបានឆ្លើយទៅនឹងសំណួររបស់ខ្ញុំ។

**ប្រធានអង្គជំនុំ៖**

បាទ អស់លោក លោកស្រីចៅក្រម មានសំណួរអីសួរដល់សាក្សីរូបនេះដែរឬទេ?

សូមអញ្ជើញលោកស្រីចៅក្រម ហ្វេនស៍!

**សួរដោយចៅក្រម ក្លូឌា ហ្វេនស៍៖**

**ស៖** សូមអរគុណ។ លោកស្រីសាក្សី លោកស្រីបាននិយាយអំពីកម្មករនៅទំនប់ ត្រូវបានគេប្តូរវេនគ្នាប្រហែលជាក្នុងរយៈពេល៣ខែម្តង។ តើលោកស្រីអាចប្រាប់បានទេ ហេតុអ្វីបានជាគេដូរវេនកម្មករដូច្នេះ?

**លោកស្រី ស៊ូ សឿន៖**

**ឆ៖** ចាស ការដូរនេះ គឺខ្ញុំជម្រាបថា ដោយកម្លាំងដែលធ្វើទំនប់ហ្នឹង វាការវាហត់ហេវ។ អ៊ីចឹងគេដូរកម្លាំងថ្មីទៅជំនួសកម្លាំងចាស់ តែកម្លាំងចាស់ក៏មិនមកឲ្យនៅស្ងៀមទេ ត្រូវរៀបចំធ្វើស្រែ ធ្វើចម្ការ ធ្វើរួមនៅក្នុងសហករណ៍។ ឯកម្លាំងថ្មីទៅធ្វើទំនប់១មករា។ អានេះខ្ញុំសូមជម្រាប។

[១៥:២៨:២៤]

**ស៖** ដូច្នេះការផ្លូវវេនាគ្នាហ្នឹង ប្តូរពីការងារដែលលំបាកធ្ងន់ធ្ងរមកការងារដែលស្រាល ឬក៏មាន

លក្ខណៈដូចថាងាយជាងមុន។ អ៊ីចឹងមែនទេ?

**ឆ៖** ចាស ប្តូរកម្លាំងហាត់នឿយ ដែលៗបានទៅទំនប់១មករា ត្រូវលីសែង លើក រែកដី ធ្វើទំនប់។ យើងដូរអ្នកកម្លាំងហ្នឹង អ្នកចាស់យើងដូរកម្លាំងអ្នកថ្មីទៀត យើងយកកម្លាំងចាស់ហ្នឹងមក មករៀបចំ វាស្រាលបន្តិច។ ស្រាលត្រង់ណា ស្រាលត្រង់ថាមកដល់ ក៏នៅតែធ្វើការ តែការងារដូចជាធ្វើស្រែ ធ្វើចម្ការ ធ្វើប្រឡាយ វាស្រាលជាងនៅកន្លែងនោះ។ បើនៅសហករណ៍ កម្លាំងវាដូចថាសហករណ៍នីមួយៗ កម្លាំងវាតិច ការហូបចុកក៏វាគួរសម កន្លែងខ្ញុំវាគួរសម។ ចាស សូមអស់ហើយ។

**ស៖** សំណួរបន្តរបស់ខ្ញុំ គឺសួរអំពីស្ថានភាពនៅទំនប់។ លោកស្រីបាននិយាយថា លោកស្រីទៅការដ្ឋានទំនប់ គឺថាលោកស្រីទៅញឹកញាប់ ពេលខ្លះទៅពីរបីដង ទៅពីរបីថ្ងៃ។ ដូច្នេះក្នុង១ខែ ជាមធ្យម តើលោកស្រីទៅការដ្ឋានទំនប់ហ្នឹង ប្រហែលជាប៉ុន្មានថ្ងៃដែរ? តើលោកស្រីអាចប្រាប់ដោយត្រួសៗបានដែរឬទេ?

**ឆ៖** ចាស ក៏សូមបញ្ជាក់ ខ្ញុំទៅទំនប់១មករាមិនសូវញឹកញាប់ទេ។ ២ខែ ឬ៣ខែខ្ញុំទៅម្តង មិនមែនទៅញឹកញាប់ ព្រោះការងារខ្ញុំនៅនេះ ធ្វើការជាមួយបងប្អូនសហករណ៍ មិនបានទៅចោលការងារយូរទេ។ ខ្លាំងទៅមួយយប់ម៉ៃអ៊ីហ្នឹង ត្រឡប់មកវិញ។ ចាស សូមអស់ហើយ។

**ស៖** ខ្ញុំចង់សួរលោកស្រីអំពីការជ្រើសរើសកម្មករ។ លោកស្រីនិយាយថា កម្មករដែលធ្វើការនៅទំនប់នេះ ត្រូវបានគេជ្រើសរើស។ ដូច្នេះខ្ញុំចង់ដឹងថា ប្រសិនបើមានមនុស្សដែលត្រូវបានជ្រើសរើសនោះតើគាត់អាចបដិសេធ គាត់និយាយថា មិនចង់ទៅធ្វើការនៅទំនប់ហ្នឹងបានដែរឬទេ?

[១៥:៣១:២៣]

**ឆ៖** ចាស ដែលការជ្រើសរើសហ្នឹង មិនមានពីណាប្រកែកទេ។ ដូចថាឲ្យតែស្រុករៀបចំកម្លាំង បងប្អូនអត់មានជំទាស់ទេ ទៅហើយ ដូរក៏ដោយ ត្រូវទៅទំនប់មករា ក៏គាត់ទៅ។ ឯគាត់មកវិញក៏គាត់អរ គាត់ត្រេកអរ មកធ្វើការស្រាល។ ប៉ុន្តែគ្មានប្រកែកប្រណាំងអីទេ គ្មានជំទាស់អីទេ ចាស។

**ស៖** ប្រសិនបើពួកគាត់មិនសប្បាយចិត្តនឹងធ្វើការនៅការដ្ឋាននោះទេ ហេតុអ្វីក៏គ្មានអ្នកណាម្នាក់បដិសេធ នៅពេលដែលពួកគាត់ត្រូវបានគេជ្រើសរើសទៅធ្វើការនៅការដ្ឋាននោះ?

**ឆ៖** ចាស កន្លែងហ្នឹងដូចថា ការចាត់តាំងរបស់គណៈស្រុក ដូច្នេះបងប្អូនមិនមានប្រកែកអីទេ។ ការចាត់តាំងទៅប៉ុន្មាន ប្រាំនាក់ប្រាំមួយនាក់ក៏ទៅ ដូរមកវិញប៉ុន្មាននាក់ក៏មក អត់មានប្រកែកប្រណាំងអីទេ ព្រោះការអប់រំរបស់ស្រុកត្រូវថា ខំប្រឹងធ្វើដើម្បីគោរពវិន័យ ការងារនៅនេះក៏មានវិន័យ

ទៅណោះក៏មានវិន័យក្នុងការធ្វើការ។ វិន័យធ្វើការទេ មិនមែនវិន័យអីទេ។

**ស៖** តើគេធ្លាប់ប្រាប់កម្មករថា ប្រសិនបើកម្មករបដិសេធ ឬក៏មិនធ្វើតាមទេ នឹងត្រូវទទួលទារុណកម្ម? តើគេមានធ្លាប់ប្រាប់អ៊ីចឹងទេ?

**ឆ៖** ចាស កន្លែងហ្នឹងគេអត់មានប្រាប់ផង។ គេប្រាប់ឲ្យតែគោរពវិន័យៗត្រូវៗធ្វើការ គោរពវិន័យគោរពម៉ោងពេល ដូចថាយើងចេញម៉ោងប៉ុន្មាន ហូបបាយម៉ោងប៉ុន្មាន ហើយល្ងាចពេលណា ចូលវិញ។ ចាសមានប៉ុណ្ណឹងៗ។

[១៥:៣៣:៥៧]

**ស៖** នៅពេលដែលកម្មករត្រូវបានគេជ្រើសរើស ហើយទៅធ្វើការនៅការដ្ឋាន តើកម្មករហ្នឹងអាចនិយាយថា ខ្ញុំឈប់ចង់ធ្វើការនៅទីនេះទៀតហើយ ខ្ញុំចង់ទៅផ្ទះ ខ្ញុំចង់ត្រឡប់ទៅវិញ តើគេអាចនិយាយ ឬក៏អាចធ្វើអ៊ីចឹងបានទេ?

**ឆ៖** ចាស បងប្អូនអត់មានប្រកែកអ៊ីចឹងទេ។ ការចាត់តាំងរបស់រដ្ឋ ឬរបស់សង្កាត់ ត្រូវចាត់តាំងប៉ុន្មាន គេគោរពតាមហ្នឹង។ អត់មានប្រកែកថា ហ៎! ខ្ញុំចង់ទៅផ្ទះ ខ្ញុំត្រូវចង់មកវិញ ហើយខ្ញុំត្រូវទៅធ្វើការ អត់មានពីណានិយាយទេ។

**ស៖** ហេតុអ្វីក៏គ្មានអ្នកណាម្នាក់ហ៊ាននិយាយបែបនេះ?

**ឆ៖** ចាស ដោយការអប់រំ ដូចថាយើងត្រូវខំប្រឹងធ្វើការដើម្បីដោះជីវភាពប្រជាជនឲ្យមានស៊ីមានចុក ហើយប្រឹងទាំងអស់គ្នា ដើម្បីកសាងជាតិ។ ថាតែប៉ុណ្ណឹងទៅ គេស្ដាប់បាន។ ហើយគ្មានពីអ្នកណាគំរាមកំហែងថាអ៊ីចេះអ៊ីចុះ អត់ទេ។ គឺបងប្អូនស្ម័គ្រចិត្តថាទៅ។

**ស៖** លោកស្រីបានរៀបរាប់អំពីស្ថានភាពនៅទំនប់ ហើយខ្ញុំសូមសង្ខេបថា ការរៀបរាប់របស់លោកស្រី គឺបង្ហាញពីស្ថានភាពការងារដ៏លំបាកដែលយើងបានស្ដាប់ឮ គឺមានការរៀបរាប់អំពីស្ថានភាពធ្ងន់ធ្ងរបំផុត។ ដូច្នេះខ្ញុំចង់សួរលោកស្រីថា ដោយសារតែមានកាលៈទេសៈដ៏លំបាកលំបិនបែបនេះ តើលោកស្រីចាំថា មានហេតុការណ៍ដែលកម្មករ គាត់ព្យាយាមរត់ចេញពីការដ្ឋានទៅទេ?

[១៥:៣៦:២២]

**ឆ៖** ចាស កន្លែងហ្នឹងដូចជា រឿងការដ្ឋានដូចគ្មានមនុស្សរត់ចេញ។ តាមខ្ញុំថា ខ្ញុំក្ដាប់មិនបាន ប៉ុន្តែខ្ញុំគ្រាន់ថាមិនដែលឮថា បងប្អូនរត់ចេញទេ។

**ស៖** ហេតុអ្វីបានជាគ្មានមនុស្សរត់គេចពីកន្លែងហ្នឹងអ៊ីចឹង?

**ឆ៖** ចាស ខ្ញុំមិនដឹងដែររឿងហ្នឹង ព្រោះមិនបានដឹងល្អិតទេ។ ព្រោះចិត្ត -- វាគ្រាន់តែថាឃើញជាក់ស្តែង បងប្អូនមិនដែលគេចវេះទៅណា ឃើញតែធ្វើការពលកម្ម ទោះបីហេវហត់យ៉ាងណាក៏ដោយ បងប្អូននៅទ្រាំធ្វើរហូត។

**ស៖** លោកស្រីប្រាប់យើងថា លោកស្រីធ្លាប់គ្រប់គ្រងកម្លាំងពលកម្មនៅទំនប់នោះ។ ដូច្នេះខ្ញុំចង់សួរលោកស្រីថា តើមានការបង្គាប់បញ្ជា ឬក៏ការណែនាំពីថ្នាក់លើរបស់លោកស្រី ដោយប្រាប់ថា តើត្រូវធ្វើយ៉ាងម៉េចចំពោះអ្នកដែលត្រូវបានជ្រើសរើស ហើយបដិសេធ ឬក៏ចំពោះអ្នកដែលរត់គេចពីការដ្ឋាន? តើមានការណែនាំបង្គាប់បញ្ជាពីខាងលើអីដែរឬទេ?

[១៥:៣៨:០៤]

**ឆ៖** ចាស អារឿងគ្រប់គ្រងនៅកម្លាំងទំនប់១មករា ខ្ញុំសូមបញ្ជាក់ថា ខ្ញុំអត់បានទៅគ្រប់គ្រងណែនាំនៅកន្លែងនោះទេ។ ភារកិច្ចខ្ញុំនៅតែត្រឹមស្រុក។ ធ្វើការនៅស្រុក មិនបានទៅគ្រប់គ្រងនៅកន្លែងទំនប់១មករាទេ។ នៅស្រុកនោះ គឺវេលារបស់ខ្ញុំមិនសូវបានចុះទេ ច្រើនតែអ្នកនៅស្រុកខាងលើ ឬក៏ខាងក្រោម។ ចំណែកខ្ញុំ រូបខ្ញុំជាស្រី ហើយជាប់ជំពាក់នឹងកូនតូចតាចអីចឹងទៅ ដូច្នេះមិនសូវបានទៅជាប់នឹងប្រជាជនប៉ុន្មានទេ ប៉ុន្តែគ្រាន់តែគេធ្វើការអីហើយ បងប្អូនធ្វើការអីហើយ មកប្រាប់ថា បង! ធ្វើអីចេះ អីស្រុកយើងត្រូវរៀបចំអីចេះ អាហ្នឹងដឹង។ ដឹងថាគេប្រាប់ថា ឥឡូវរៀបចំសហករណ៍ ហើយត្រូវរៀបចំទំនប់ប្រឡាយ ប៉ុណ្ណឹងដឹង ចាស។ ព្រោះខ្ញុំធ្វើបានតិច ធ្វើបានតែ១ឆ្នាំទេ ធ្វើស្រុកតែ១ឆ្នាំទេ។

**ស៖** សំណួរចុងក្រោយរបស់ខ្ញុំ គឺថាលោកស្រីបានប្រាប់យើងមុននេះ ថាលោកស្រីទៅភ្នំពេញម្តងម្កាលដែរ គឺដើម្បីទទួលការណែនាំ។ ដូច្នេះខ្ញុំចង់ដឹងថា ការធ្វើដំណើរទៅភ្នំពេញហ្នឹង ធ្វើដំណើរជាទៀងទាត់ ឧទាហរណ៍ថា១ខែម្តង ឬមួយក៏ជាការធ្វើដំណើរដោយមិនទៀងទាត់? ឧទាហរណ៍ថា ប្រសិនបើគេហៅលោកស្រីទៅ លោកស្រីធ្វើដំណើរទៅ។ ខ្ញុំចង់ដឹងថា តើវាអាចថា ជាការកំណត់កាលបរិច្ឆេទច្បាស់លាស់ថា ថ្ងៃទី០១ នៃខែនីមួយៗលោកស្រីត្រូវធ្វើដំណើរ ឬមួយវាជាការចៃដន្យ?

**ឆ៖** ចាស អារឿងទៅធ្វើ -- មកភ្នំពេញនេះ ខ្ញុំសូមជម្រាបថា ទាល់តែអង្គការត្រូវហៅមករៀនសូត្រ ត្រូវមកអប់រំ ផ្សព្វផ្សាយនូវការងារទាំងអស់ ហើយមកក៏មិនមែនមកតែខ្ញុំ មកគ្នាច្រើន។ ទៅមួយឡានពីរឡានមក កម្លាំងវាច្រើន មកទទួលការងារ ចែកការងារគ្នាតាមស្រុក។ ត្រូវធ្វើអីខ្លះ ផ្នែកធ្វើអីខ្លះ ហើយស្រុកត្រូវចែកតាមសង្កាត់យ៉ាងណា។ អាហ្នឹងទៅតាមលទ្ធភាពមួយៗ តាមស្រុកមួយៗ។ ចាស ខ្ញុំជម្រាបប៉ុណ្ណឹង។

[១៥:៤១:១៩]

**ស៖** ខ្ញុំស្តាប់ទៅ គឺអត់មានការបកប្រែដូចជាមួយកង់ ខ្ញុំឃើញសាក្សីនិយាយ ប៉ុន្តែអត់មានការបកប្រែមួយកង់។ ខ្ញុំចង់ដឹងថាហេតុអី? ដូច្នេះខ្ញុំចង់សួរលោកស្រីបន្តទៀត នៅពេលដែលលោកស្រីទទួលខុសត្រូវការងារហ្នឹង តើលោកស្រីទៅភ្នំពេញ ពេលធ្វើដំណើរទៅភ្នំពេញម្តងៗហ្នឹង តើចំណាយពេលប៉ុន្មានដែរ គឺការធ្វើដំណើរដើម្បីទៅទទួលយកព័ត៌មាន ហើយនិងទទួលយកការណែនាំនោះលោកស្រីចំណាយពេលប៉ុន្មានដែរ?

**ឆ៖** ជួនកាលក៏ពីរបីថ្ងៃអ៊ីចឹងត្រូវត្រឡប់មកវិញ។ វាមិនទៀងដែរ ខ្ញុំថាពីរបីថ្ងៃហ្នឹងវាយូរផង។ ខ្លាំងមកម្យប់ពីរយប់ត្រឡប់ទៅវិញ។ ចាស ទទួលការងារមិនយូរទេ។

**ស៖** តើក្នុង -- លោកស្រីនិយាយថា១ឆ្នាំ។ តើក្នុងរយៈពេល១ឆ្នាំដែលលោកស្រីនិយាយហ្នឹង តើលោកស្រីធ្វើដំណើរទៅនុ៎ងប៉ុន្មានដងដែរ?

**ឆ៖** ចាស តាមខ្ញុំចាំ ១ឆ្នាំប្រហែល -- មើលទៅភ្លេចអស់ហើយ មិនដឹងថា១ឆ្នាំទៅប៉ុន្មានដងទេ។ គ្រាន់តែថា បានមកៗបានទទួលការណែនាំពីខាងលើ។ តែឲ្យរាប់ថា ១ឆ្នាំទៅប៉ុន្មានដងចាំមិនបាន។

**ស៖** ខ្ញុំសូមសាកសួរម្តងទៀត យើងអាចថាពីរបីដង ឬមួយក៏ដប់ម្ភៃដង។ ខ្ញុំមិនចង់ឲ្យលោកស្រីបញ្ជាក់ឲ្យច្បាស់នោះទេ ប៉ុន្តែគ្រាន់តែថា ជួយបង្ហាញប្រាប់ខ្ញុំបន្តិចមើលថា តើវាញឹកញាប់ ឬមួយក៏វាម្តងម្កាល រង្វើលៗនោះទេ?

[១៥:៤៣:៤០]

**ឆ៖** ចាខ្ញុំដូចថាក្តាប់មិនបាន ១ឆ្នាំត្រូវមកប៉ុន្មានដង ១ខែត្រូវមកម្តងក៏ ចាំមិន -- ដូចថាអារម្មណ៍ សតិអារម្មណ៍ហ្នឹងវាអត់បានគិតដល់។ ពីមុនចាំ តែឥឡូវនេះនិយាយមុខភ្លេចក្រោយ។ ដូច្នេះ ១ឆ្នាំ អ៎! ១ខែ ឬ២ខែ ឬ៣ខែត្រូវមកទទួលការណែនាំពីខាងលើ។ អ៊ីចឹងខ្ញុំថា សន្និដ្ឋានថាអ៊ីចឹងលើសផង។ ហើយដូច្នេះវាជម្រាបថា ខ្ញុំមិនចាំតែម្តង ទល់ខ្ញុំមិនចាំ។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

សូមអរគុណលោកស្រី។ ខ្ញុំសូមបញ្ចប់ការសាកសួរសំណួររបស់ខ្ញុំ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍!

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

សូមអរគុណលោកប្រធាន។

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

**ស៖** លោកស្រីសាក្សី ខ្ញុំមានសំណួរមួយចំនួន។ នៅភ្នំពេញហ្នឹង តើគេនិយាយប្រាប់លោកស្រីអ្វីខ្លះ ហើយលោកស្រីជួបអ្នកណាខ្លះនៅភ្នំពេញ? លោកស្រីថា លោកស្រីបានជួប នួន ជា តើលោកស្រីអាចបញ្ជាក់ម្តងវិញទៀតបានដែរឬទេ?

[១៥:៤៥:០៩]

**លោកស្រី ស៊ូ សឿន៖**

**ឆ៖** ចាស ខ្ញុំបានជួបគាត់។ បានជួបគាត់ គាត់អ្នករៀបចំកម្លាំងតាមស្រុកដើម្បីទៅធ្វើការនៅមូលដ្ឋានមួយៗ។ ខ្ញុំបានជួបគាត់។ គាត់រៀបចំការងារតាមស្រុក ដើម្បីគាត់ណែនាំទៅដឹកប្រឡាយធ្វើស្រែ ធ្វើចម្ការ ជីកប្រឡាយ ជីកទំនប់ រៀបចំកម្លាំងសហករណ៍។ ពេលខ្ញុំបានជួបគាត់ គាត់ណែនាំយ៉ាងនេះ។

**ស៖** តើគាត់មាននិយាយអំពីការតស៊ូវណ្ណៈ និយាយអំពីខ្មាំង និយាយអំពី សេ.អ៊ី.អា ឬ កា.ហ្សេ.បេ ទេ?

**ឆ៖** ចាស អារឿងការអប់រំ គឺមិនបាននិយាយពាក់ព័ន្ធដល់រឿងហ្នឹងទេ។ អង្គាល់តស៊ូវណ្ណៈទាល់ការ -- សេ.អ៊ី.អា អីមិនមានទេ ព្រោះខ្ញុំមិនបានទទួលពាក្យពីគាត់ទេ។

**ស៖** តើការណែនាំពាក់ព័ន្ធទៅនឹងការរៀបចំកម្លាំងពលកម្មហ្នឹងមានអ្វីខ្លះ? លោកស្រីថា លោកស្រីទៅ២, ៣ខែម្តងទៅភ្នំពេញហ្នឹង អ៊ីចឹងរៀងរាល់ពេលដែលលោកស្រីទៅហ្នឹង លោកស្រីតែងតែជួប នួន ជា ឬក៏លោកស្រីបានជួបមេដឹកនាំផ្សេងទៀត?

[១៥:៤៧:០៧]

**ឆ៖** ចាស ខ្ញុំមិន -- មេផ្សេងទៀតខ្ញុំមិនបានជួបទេ ជួបតែគាត់ច្រើនដងជាងគេ គឺគាត់ខាងអប់រំ ណែនាំដឹកនាំធ្វើខាងសហករណ៍។ ដូច្នេះការជួប វាមានកម្រិតរបស់ខ្ញុំ។ ធ្វើចំណារខាងស្រុកណែនាំខាងសហករណ៍ ហើយនិងធ្វើស្រែ១ឆ្នាំត្រូវធ្វើបានប៉ុន្មានដង គឺគិតគូរជីវភាពប្រជាជន។ ចាស សូមអស់ហើយ។

**ស៖** តើ នួន ជា មានសួរលោកស្រីអំពីស្ថានភាពនៅស្រុករបស់លោកស្រីទេ? ឧទាហរណ៍ដូច

ជាគាត់ចង់ដឹងថា តើនៅមូលដ្ឋានហ្នឹងមានអាហារហូបចុកគ្រប់គ្រាន់ទេ មានការត្អូញត្អែរ មានតវ៉ា រអ៊ូរទាំ ពាក់ព័ន្ធទៅនឹងទិន្នផលស្រូវដែលមិនបានគ្រប់តាមផែនការដែលបក្សចង់បាន។ គាត់មានបានសើបសួរលោកស្រីអំពីបញ្ហាហ្នឹងទេ?

**ឆ៖** ចាស គាត់បានសួរ ហើយគាត់ច្រើនតែសួរថា យើងរៀបចំសហករណ៍ ការរៀបចំជីវភាពបងប្អូនបានកម្រិតណា ហើយបងប្អូនយ៉ាងម៉េច សុខភាពយ៉ាងម៉េច។ គាត់បានសួរអ៊ីចឹង។

**ស៖** លោកស្រី នៅពេលដែលលោកស្រីនៅក្នុងគណៈស្រុក តើលោកស្រីមានធ្លាប់ទទួលបានការរអ៊ូរទាំពីមេសហករណ៍ ដែលថាទិន្នផលស្រូវហ្នឹងគឺមិនគ្រប់គ្រាន់ទេ ការប្រមូលផលហ្នឹងមិនគ្រប់គ្រាន់ទេ ធ្វើឲ្យមានបញ្ហាហូបចុក។ លោកស្រីធ្លាប់មានទទួលបានការរអ៊ូរទាំបែបហ្នឹង ពីមេសហករណ៍ទេ?

[១៥:៤៩:៤១]

**ឆ៖** ចាស អារឿងនៅស្រុកចំការលើ ខ្ញុំចង់ជម្រាបថា ការធ្វើបានផលច្រើន ជីវភាពគេក៏គួរសមដែរ។ មានខ្លះដែរ មានតិចតួច មិនមានច្រើន គ្រាន់តែថាធ្វើស្រែបានស្រូវ ដោយហេតុអីបងប្អូនមិនបានហូបបាយបីពេល អាហ្នឹងវាមាន មានអ៊ីចឹង។

**ស៖** លោកស្រីសាក្សី ខ្ញុំនឹងអានចម្លើយរបស់លោកស្រីនៅចំពោះមុខសហចៅក្រមស៊ើបអង្កេត គឺឯកសារ E3/5294 ERN ជាភាសាបារាំង 00367805ទៅដល់06, ជាភាសាអង់គ្លេស 00360113, ទៅដល់ 14, ជាភាសាខ្មែរគឺ 00348831។ "សួរ៖ តើលោកស្រីទទួលបានសំណើ ឬក៏ការតវ៉ាពីថ្នាក់ក្រោមទេ? ចម្លើយ៖ ខ្ញុំទទួលបាន ប្រធានសហករណ៍ និងប្រធានក្រុមបានតវ៉ាថា ការធ្វើស្រែហ្នឹងគឺមានទិន្នផលខ្ពស់ ក៏ប៉ុន្តែផ្ទុយទៅវិញ ប្រជាជនមិនបានហូបចុកគ្រប់គ្រាន់ទេ។ ខ្ញុំបានបញ្ជូនការប្តឹងផ្តល់នេះទៅគណៈស្រុក ហើយគណៈស្រុកក៏បញ្ជូនបន្តទៅថ្នាក់លើទៀត។ ហើយយើងមិនដែលទទួលបានចម្លើយចំពោះការតវ៉ាហ្នឹងទេ។ ស្រូវក៏ត្រូវបានគេនាំចេញទៅបរទេសទៀត។" អ៊ីចឹងលោកស្រីអាចឆ្លើយបញ្ជាក់ម្តងទៀតទេថា ការដែលលោកស្រីឆ្លើយនៅចំពោះមុខសហចៅក្រមស៊ើបអង្កេតហ្នឹង គឺពិតជាចម្លើយត្រឹមត្រូវ?

[១៥:៥២:០០]

**ឆ៖** ចាស ចម្លើយហ្នឹងគឺត្រឹមត្រូវហើយ ព្រោះខ្ញុំបានស្នើខាងលើ គឺថាបងប្អូនគេតាមសង្កាត់នីមួយៗ គេថាធ្វើស្រែបានផលច្រើនដែរ តែបងប្អូនជីវភាព បងប្អូនវាមិន -- ដូចថាហូបមិនគ្រប់គ្រាន់

ហើយវាមិនៗសម្បូរសប្បាយ ហើយគាត់ថាហួបវានៅការខ្វះខាតខ្លះ។ អ៊ីចឹងគេតាមសង្កាត់នីមួយៗ គេស្នើ ហើយក៏ស្នើទៅតាមស្រុក ទៅតាមតំបន់។ តាមតំបន់ ក៏មិនឃើញឆ្លើយតប។ ចាស អស់ហើយ។

**ស៖** លោកស្រីសាក្សី នៅពេលដែលប្រធានសហករណ៍តវ៉ា អំពីការខ្វះខាតស្បៀងអាហារ បើតាមគំនិតលោកស្រីផ្ទាល់ហ្នឹង គាត់និយាយការពិត ឬក៏កុហក?

**ឆ៖** ចាស សហករណ៍មិន -- ប្រធានសហករណ៍ គេមិនដែលនិយាយកុហកទេ គេនិយាយត្រង់។ គាត់ស្នើមកខាងលើដើម្បីដោះស្រាយ ប៉ុន្តែមិនមែនគ្រប់សង្កាត់ទេ វាមានកន្លែងខ្លះៗវាអត់ កន្លែងខ្លះវាសម្បូរ។ ដូច្នេះការដោះស្រាយ ខាងលើគឺពិនិត្យឃើញថា ស្រុកចំការលើនេះវាសម្បូរ ដូច្នេះស្រូវចង់ដកទៅកន្លែងណាផ្សេងទៀត ខ្ញុំមិនបានដឹងទេ។

**ស៖** ហេតុអ្វីបានជាថ្នាក់លើ មិនដែលបានឆ្លើយតបទៅនឹងការរាយកាណ៍ដែលលោកស្រីបញ្ជូនទៅនោះ?

[១៥:៥៤:២១]

**ឆ៖** ចាស ខ្ញុំក៏ជម្រាបទៅលោកថា ខ្ញុំក៏មិនដឹងដែរ ព្រោះវាបាត់ដំណឹងទៅ ឲ្យខ្ញុំនិយាយយ៉ាងម៉េច។

**ស៖** ហេតុអ្វីបានជាគេនាំស្រូវទៅបរទេសទៅវិញ បើប្រជាជនហួបមិនឆ្អែតផង?

**ឆ៖** ចាស ខ្ញុំក៏មិនយល់ដែរ មិនយល់ដូចថា រឿងអស់ទាំងនេះ កម្រិតខ្ញុំទាប ដូច្នេះខ្ញុំមិនប៉ានសួរដេញដោលទេ។ ខ្ញុំនិយាយខ្លី មិនប៉ានសួរដេញដោលទេ។ ដល់ខាងលើ ខាងក្រោមស្នើទៅ គាត់បញ្ជូនទៅដល់តំបន់ តំបន់បញ្ជូនទៀត តែក៏បាត់ទៅ។ ហើយរឿងហេតុអ្វីដែលថាត្រូវមិនតបមិនឆ្លើយអីចាស។ ចំណែកខ្ញុំក៏អត់យល់អត់ដឹងដែរ ចាស។

**ស៖** បើតាមគំនិតលោកស្រីនោះ តើអ្នកណាជាអ្នកសម្រេចថាទិន្នផលស្រូវប៉ុន្មានដែលត្រូវនាំចេញទៅ ស្រុក ឬក៏តំបន់ ឬក៏ថ្នាក់លើទៅទៀតដែលអ្នកសម្រេចអំពីរឿងទិន្នផលស្រូវដែលត្រូវនាំចេញទៅនោះ?

**ឆ៖** ចាស ខ្ញុំឆ្លើយនេះក៏ ដោយការដូចថាខ្ញុំមិនបានកាន់បញ្ជី ហើយដូច្នេះគ្រាន់តែខាងសង្កាត់គេប្រាប់ថា ឥឡូវគេរៀបចំ ដោះស្រាយមួយចំនួនទុកសហករណ៍ មួយចំនួនទៅរដ្ឋយកទៅក្រៅ មិនមែនទៅក្រៅទេ គឺថាយកទៅចិញ្ចឹមកងទ័ព។ អាហ្នឹងគេប្រាប់អ៊ីចឹង យកទៅចិញ្ចឹមកងទ័ព។ តែត្រង់ថាម៉េចទៀត ខ្ញុំអត់ដឹងទេ។

[១៥:៥៦:៤១]

**ស៖** តើស្ថានភាពហូបចុកនៅការដ្ឋានសាងសង់ទំនប់១មករាហ្នឹង មានស្ថានភាពប្រសើរជាងនៅតាមសហករណ៍មែនទេ?

**ឆ៖** ចាស កន្លែងហ្នឹងរដ្ឋផ្គត់ផ្គង់គ្រាន់បើជាង សហករណ៍ក៏មិនអត់ សហករណ៍ចំការលើក៏មិនអត់ មិនទៅខ្វះខាតអីដូច – ខ្ញុំមិនបានឃើញកន្លែងគេទេ ស្រុកគេផ្សេងៗខ្ញុំមិននិយាយទេ និយាយតែក្នុងខ្ញុំវង់ខ្ញុំដែលខ្ញុំក្នុងគណៈកម្មការស្រុកហ្នឹង គេចុះគ្រប់សង្កាត់ ខ្ញុំមិនបានចុះទេ។ ប៉ុន្តែក្នុងគណៈកម្មការស្រុកហ្នឹងគេបានចុះ។ ហើយសង្កាត់នីមួយៗក៏មកៗនិយាយប្រាប់ថា មិនអត់ទេបង គ្រប់គ្រាន់ អ៊ីចេះ។ អ៊ីចឹងអារឿងខ្វះខាតអ្វី មិនយល់ដែរខ្ញុំ ក្តាប់មិនបាន។

**ស៖** លោកស្រីខ្ញុំមិនយល់ទេ។ លោកស្រីនិយាយថា ប្រធានសហករណ៍មិនកុហកទេនៅពេលដែលពួកគាត់និយាយពីការខ្វះខាតស្បៀងអាហារនោះ។ ឥឡូវលោកស្រីនិយាយផ្ទុយទៅវិញថា លោកស្រីមិនយល់ដែរ។ លោកៗស្រីមិនយល់អ្វី លោកស្រីមិនយល់ថា ពួកគាត់ជាប្រធានសហករណ៍ហ្នឹងនិយាយការពិត ឬក៏និយាយកុហក?

**ឆ៖** ចាស ខ្ញុំចង់ជម្រាបអ៊ីចេះលោកប្រធាន ជម្រាបថា ដែលមិនយល់ហ្នឹងគឺ ថាស្រូវបានច្រើនហើយប្រមូលទៅខាងតំបន់គេយកទៅ ហើយបងប្អូនថាហូបគ្រប់គ្រាន់ -- ប្រធានសង្កេតគេថាគ្រប់គ្រាន់ ឯបងប្អូនគេថា អ្នកដែលធ្វើការណាជីកទំនប់ ជីកប្រឡាយ ថាហូបមិនគ្រប់គ្រាន់។ តែតាមសហករណ៍មួយៗ ដូចជាមិនអស់ទេស្រូវអង្ករ បើតាមខ្ញុំចុះទៅកន្លែងមួយៗឃើញអ៊ីចឹង ស្រូវអង្ករគេនៅមាន។

[១៥:៥៩:០៥]

**ស៖** អ៊ីចឹងមានន័យថា ប្រធានសហករណ៍ហ្នឹងកុហកហើយមែនទេ? ប្រសិនបើលោកស្រីនិយាយថា លោកស្រីចុះទៅផ្ទាល់ ហើយលោកស្រីឃើញមានស្រូវអង្ករ ហើយនៅពេលដែលលោកស្រីទទួលរបាយការណ៍ថាមានការខ្វះខាតស្បៀងអាហារហ្នឹង គឺមានន័យថាប្រធានសហករណ៍ហ្នឹងកុហកហើយ។ តើអ៊ីចឹងមែនទេ?

**ឆ៖** ចាវាមិនពិតដែរអាហ្នឹង រឿងថាគេចង់កាច់សហករណ៍មួយៗ។ ដូច្នេះវាមានអ៊ីចឹងដែរ ដូចថាកន្លែងខ្លះគ្នាច្រើនហូបមិនគ្រាន់ ដល់កន្លែងខ្លះសហករណ៍ខ្លះវាគ្នាតិច ហើយផលគេបានច្រើន អាហ្នឹងគេចែកតាមសហករណ៍ ចាស។ ដល់ពេលគេរាយការណ៍ថា អត់អ៊ីចេះអត់អ៊ីចុះ ខ្ញុំអត់ជឿ ប៉ុន្តែខ្ញុំមិន

បានចុះគ្រប់សហករណ៍ទេ ខ្ញុំចុះបានតែសហករណ៍ខ្លះ ពីរបីសហករណ៍ទៅ ខ្ញុំមិនបានចុះច្រើនទេ ចាស។

**ស៖** បើតាមលោកស្រីផ្ទាល់ តើអ្នកណាជាអ្នកផ្គត់ផ្គង់ស្រូវសម្រាប់ការហូបចុករបស់កម្មករនៅទំនប់១មករា? តើជាសហករណ៍ ឬក៏ជាថ្នាក់លើ ឬជាថ្នាក់ស្រុក ថ្នាក់តំបន់ ឬក៏ថ្នាក់ជាតិដែលជាអ្នកបញ្ជូនស្រូវអង្ករមកឱ្យកម្មករដែលធ្វើការនៅទំនប់១មករានោះ?

[១៦:០០:៤២]

**ឆ៖** ចាស ខ្ញុំក្តាប់បានខ្លះ គឺខាងលើបញ្ជូនយ៉ាងម៉េច ខ្ញុំមិនដឹងទេ ប៉ុន្តែខាងភូមិភាគត្រូវទទួលបន្ទុក ទទួលកម្លាំងនេះ ត្រូវការចាត់ចែងកម្លាំង ទទួលជីវភាពរៀបចំ ហ្នឹងខាងភូមិភាគ។ ខ្ញុំគ្រាន់តែដឹងខ្លះ តែមិនដឹងច្បាស់ថា ម៉េចឱ្យតែបានគ្រប់គ្រងនៅកន្លែងសហករណ៍ -- អ៊ូ! ទំនប់១មករា។ ខ្ញុំមិនបានទៅគ្រប់គ្រងទេ គ្រាន់តែដឹងថា ជីវភាពមានតែខាងភូមិភាគអ្នកគ្រប់គ្រង។ គ្រប់គ្រងទាំងកម្លាំង គ្រប់គ្រងទាំងជីវភាព គ្រប់គ្រងទាំងអ្នកជំងឺ។ ចាស សូមជម្រាបប៉ុណ្ណឹង។

**ស៖** សំណួរចុងក្រោយលោកស្រីសាក្សី។ តាមអ្វីដែលលោកស្រីបានសង្កេតឃើញផ្ទាល់ភ្នែកនៅទំនប់១មករា តើកម្មករបានហូបចុកគ្រប់គ្រាន់ទេ ហូបឆ្អែតទេ?

**ឆ៖** ចាស នៅ -- ដូចខ្ញុំជម្រាបថា ការមនុស្សរាប់ម៉ឺន បើចំណែកខ្ញុំទៅ វាត្រូវតែបានតែមួយជ្រុង មួយជ្រុងដូចថាវាប្រហែលជាបួនប្រាំពាន់ ឬ១០.០០០ហូបគ្រប់គ្រាន់។ ហើយខ្ញុំមិនបានដើរទៅសព្វអ៊ីចឹងទេ ប៉ុន្តែការគ្រប់គ្រង បើគ្រប់មួយក្រុមវាគ្រប់គ្រាន់ហើយ ទូទៅក៏គ្រប់គ្រាន់ដែរ។ ការត្រីសម្ល របត្រីងៀតបញ្ជូនពីទន្លេសាបទៅខ្វះអី គេហាលទាំងរានៗ។ ដូច្នេះមិនខ្វះទេជីវភាព បើថាត្រង់អង្ករស្តៅអី ពេលខ្ញុំទៅខ្ញុំឃើញគេហូបបាយ ខ្ញុំក៏ហូបជាមួយគេទៅ។ បើត្រង់ថាដើរទៅមើលសព្វគ្រប់អ៊ីចឹង ចាស អត់បានដើរទេ។ ខ្ញុំសូមចប់ប៉ុណ្ណឹង។

[១៦:០៣:១៤]

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

ខ្ញុំគិតថា ដោយសារតែពេលវេលា ខ្ញុំសូមបញ្ចប់ត្រឹមនេះចុះ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ សវនាការនៅថ្ងៃនេះ ដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះត្រឹមនេះ សវនាការលើកទៅបន្តធ្វើនៅថ្ងៃស្អែក ថ្ងៃសុក្រ ទី០៥ ខែ

មិថុនា ឆ្នាំ២០១៥ ចាប់ផ្ដើមពីម៉ោងប្រាំបួនព្រឹក។

សវនាការនៅថ្ងៃស្អែកនេះ អង្គជំនុំជម្រះនឹងធ្វើសវនាការបន្តស្ដាប់សក្ខីកម្មសាក្សី ស៊ូ សឿន សូមភាគីជ្រាប និងអញ្ជើញចូលរួមតាមពេលវេលាបានកំណត់នេះ។ ហើយអង្គជំនុំជម្រះអរគុណលោកស្រី ស៊ូ សឿន ដំណើរការសវនាការស្ដាប់សក្ខីកម្មរបស់លោកស្រីនៅក្នុងឋានៈជាសាក្សី នៅមិនទាន់ចប់នៅឡើយទេ អង្គជំនុំជម្រះកោះអញ្ជើញលោកស្រីឲ្យមកបន្តផ្ដល់សក្ខីកម្មនៅថ្ងៃស្អែកទៀត ដែលនឹងចាប់ផ្ដើមពីម៉ោងប្រាំបួនព្រឹកទៅ។ ហើយអង្គជំនុំជម្រះក៏សូមអរគុណដែរលោកស្រី ឆាយ ម៉ារីដែន បុគ្គលិកអង្គការ ធី.ភី.អូ ដែលបានជួយចូលរួម ហើយជួយអង្គុយក្បែរសាក្សីរូបនេះ ដើម្បីឲ្យមានស្មារតីរឹងប៉ឹងក្នុងការផ្ដល់សក្ខីកម្ម។ ហើយអង្គជំនុំជម្រះក៏សូមអញ្ជើញលោកស្រីមកចូលរួម និងផ្ដល់ -- បន្តការងាររបស់លោកស្រីនៅថ្ងៃស្អែកទៀត ដែលចាប់ផ្ដើមពីម៉ោងប្រាំបួនព្រឹកទៅ។

ហើយមន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងបុគ្គលិកនៃអង្គភាពគាំពារសាក្សី និងអ្នកជំនាញ ក្នុងការជូនលោកស្រី ស៊ូ សឿន វិលត្រឡប់ទៅកាន់ទីកន្លែងដែលគាត់ស្នាក់នៅវិញចុះ និងសូមឲ្យអញ្ជើញគាត់ ត្រឡប់មកកាន់កន្លែងផ្ដល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះវិញ នៅថ្ងៃស្អែកឲ្យបានមុនម៉ោងប្រាំបួនព្រឹក។

បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទទាំងពីររូប ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញចុះ និងបង្គាប់ឲ្យនាំខ្លួនគាត់ទាំងពីររូបត្រឡប់ចូលរួមសវនាការនៅថ្ងៃស្អែកឲ្យបានមុនម៉ោងប្រាំបួនព្រឹក។

សម្រាកចុះ៕

*(សវនាការផ្អាកនៅម៉ោង ១៦:០៥ នាទី)*